ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

អង្គជំនុំជម្រះសាលាដំបូង
Trial Chamber
Chambre de Premiere instance

# កំណត់ហេតុជាលាយលក្ខណ៍អក្សរ
# នៃកិច្ចដំណើរការនីតិវិធីជំនុំជម្រះក្តី "ឌុច"
# សាធារណៈ

សំណុំរឿងលេខ ០០១/១៨-០៧-២០០៧-អវតក/អជសដ

**ថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០០៩**
**សវនាការលើកទី៣៦**

**ចៅក្រមសាលាដំបូង៖**

លោក និល ណុន ជាប្រធាន
លោកស្រី ស៊ីលយ៉ា ខាតរ៉ាយថ៍
*(Judge Silvia Carwright)*
លោក យ៉ា សុខន
លោក ហ្សង់ម៉ាក ឡាវ៉ែន៍
*(Judge Jean-Marc Lavegne)*
លោក ធួ មណី
លោក យូរ ឧត្តរា
លោកស្រី ក្លូឌា ហ្វេនស៍ *(Judge Claudia Fenz)*

**ក្រឡាបញ្ជីសាលាដំបូង៖**

លោក លឹម ស៊ុយហុង
លោក ម៉ាតូ គ្រីស្ពារ
*(Mr. Matteo Crippa)*
លោកស្រី សែ កុលវុឌ្ឍី
កញ្ញា ណាចាក់ វិចស៊ែល
*(Ms. Natacha Wexels-Riser)*
លោក ឌុច ផារី

**ការិយាល័យសហព្រះរាជអាជ្ញា៖**

លោក វាលៀម ស្មីត *(Mr. William Smith)*

លោក តាន់ សេណារ៉ុង

លោក ពេជ្រ សម្បត្តិ

លោក ហ្សាឆិរី ឡាំប៉ែល (Zachery LAMPEL)

លោក ប៉ាក ច័ន្ទលីណូ (ក្រឡាបញ្ជី)

**មេធាវីការពារជនជាប់ចោទ កាំង ហ្គេក អ៊ាវ ៖**

លោក ការ សាវុត្ថ

លោកស្រី ម៉ារីប៉ូល កានីហ្សារ

*(Mr. Marie-Paule CANIZARES)*

លោកស្រី ហេឡឺន អ៊ុយណាក់

*(Ms. Heleyn UÑAC)*

**មេធាវីតំណាងដើមបណ្តឹងរដ្ឋប្បវេណី៖**

លោក ហុង គីមសួន

លោក គង់ ពិសី

លោក យ៉ុង ផានិត

លោក គឹម ម៉េងឃី

លោកស្រី ស៊ីលឃីស្ទូត ហ្សីនស្គី

*(Ms. Silke Studzinsky)*

លោកស្រី ម៉ាទីន ហ្សាកកាំង (ហ្សាកឃ្វីន)

*(Mrs. Martine JACQUIN)*

កញ្ញា ទី ស្រ៊ីនណា

លោក អាឡាំង វ៉ែនណឺ

*(Mr. Alain Werner)*

**ផ្នែកគ្រប់គ្រងតុលាការ៖**

លោក កូវ កែវរតនៈ

# ឧបសម្ព័ន្ធ

## សាក្សី

**សាក្សី ៖** លោក ជុំ ម៉ី (ជុំ ម៉ាញ)


សួរដោយ លោកប្រធានអង្គជំនុំពី......ទំព័រ ១
សួរដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយ៍ ផ្តើមពី......ទំព័រ ៣០
សួរដោយ ចៅក្រមហ្សង់ម៉ាក ឡាវែន៍ ផ្តើមពី......ទំព័រ ៣៥
សួរដោយ លោកតាន់ សេណារ៉ុង ផ្តើមពី......ទំព័រ ៤៣
សួរដោយ លោក វីលៀម ស្មីត ផ្តើមពី......ទំព័រ ៤៧
សួរដោយ លោក ហុង គីមសួន ផ្តើមពី......ទំព័រ ៥៤
សួរដោយ កញ្ញា ស៊ីលយី ស្ទូតហ្សីនស្គី ផ្តើមពី......ទំព័រ ៥៨
សួរដោយ លោកស្រី ម៉ាទីន ហ្សាកកាំង ផ្តើមពី......ទំព័រ ៦២
សួរដោយ កញ្ញា ទី ស្រ៊ីនណា ផ្តើមពី......ទំព័រ ៦៧
សួរដោយ លោក ការ សាវុត្ថ ផ្តើមពី......ទំព័រ ៧០
សួរបន្តដោយ ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយន៍ ផ្តើមពី......ទំព័រ ៧២

**បញ្ជីឈ្មោះ អ្នកនិយាយ៖**

ភាសា ដែលប្រើប្រាស់ លើកលែងតែបានកំណត់ជាក់លាក់នៅក្នុងប្រតិចារឹក

| **អ្នកនិយាយ** | **ភាសា** |
|---|---|
| លោកស្រី ម៉ារីប៉ូល កានីហ្សារ | បារាំង |
| ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍ | អង់គ្លេស |
| លោក ជុំ មុំ (សាក្សី) | ខ្មែរ |
| លោក ហុង គឹមសួន | ខ្មែរ |
| លោកស្រី ម៉ាទីន ហ្សាកកាំង | បារាំង |
| លោក ការ សាវុត្ថ | ខ្មែរ |
| ចៅក្រម ហ្សង់ម៉ាក ឡាវែរ័ | បារាំង |
| លោក វីលៀម ស្មីត | អង់គ្លេស |
| លោកស្រី ស៊ីលឃី ស្ទួតហ្សីនស្គី | អង់គ្លេស |
| លោក តាន់ សេណារ៉ុង | ខ្មែរ |
| ជនជាប់ចោទ | ខ្មែរ |
| ចៅក្រម និល ណុន (ប្រធានអង្គជំនុំជម្រះ) | ខ្មែរ |
| កញ្ញា ទី ស្រ៊ីនណា | ខ្មែរ |
| លោក អាឡាំង វ៉ែនណឺ | អង់គ្លេស |

# កិច្ចដំណើរការនីតិវិធី

*[ចៅក្រមចូលមកកាន់បន្ទប់សវនាការ]*

[០៩:00:00]

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីពិភាក្សាដេញដោល ។ ក្រឡាបញ្ជីឡើងរាយការណ៍អំពីស្ថានភាពវត្តមាន និងអវត្តមានភាគីនិងអ្នកដែលត្រូវចូលរួមនៅក្នុងនីតិវិធីពិភាក្សាដេញដោលនៅថ្ងៃនេះ។

**លោកស្រី សែ កុលវុឌ្ឍី៖**

សូមគោរពលោកប្រធាន ភាគីដែលបានចូលរួមនៅក្នុងកិច្ចដំណើរការនីតិវិធីសវនាការក្នុងថ្ងៃនេះមានវត្តមានគ្រប់ចំនួន ។ អ្នករស់រានមានជីវិតដែលជាដើមបណ្តឹងរដ្ឋប្បវេណី ហើយដែលត្រូវមកផ្តល់សក្ខីកម្មនៅក្នុងថ្ងៃនេះមានវត្តមានដែរ រង់ចាំការកោះហៅពីអង្គជំនុំជម្រះ។

**ប្រធានអង្គជំនុំ៖**

មន្រ្តីតុលាការអញ្ជើញដើមបណ្តឹងរដ្ឋប្បវេណី ជុំ ម៉ី ចូលកាន់បន្ទប់សវនាការ។

*[ដើមបណ្តឹងរដ្ឋប្បវេណីចូលកាន់កន្លែងផ្តល់សក្ខីកម្ម]*

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អ៊ំឈ្មោះអីដែរអ៊ំ?

**សាក្សី ជុំ ម៉ី៖**

**ឆ៖** បាទ ខ្ញុំបាទឈ្មោះ ជុំ ម៉ី លោកក្តួយ។

**ស៖** អ៊ំមានឈ្មោះហៅក្រៅផ្សេងទៀត ពីឈ្មោះ ម៉ី ដែរឬទេ?

**ឆ៖** ហៅ-- *(អត់ឮសំឡេង)*

**ស៖** អ៊ីចឹងឈ្មោះផ្លូវការរបស់អ៊ំ គឺឈ្មោះ ម៉ាញ ទេ មិនមែនឈ្មោះ ម៉ី ទេ បានន័យថាឈ្មោះផ្លូវការគឺ ជុំ ម៉ាញ ចំណែកឯ ឈ្មោះ ម៉ី គឺឈ្មោះហៅក្រៅទេ ពិតមែនទេ?

**ឆ៖** *(អត់ឮសំឡេង)*

**ស៖** អ៊ំមានអាយុ-- *(អត់ឮសំឡេង)*

**ឆ៖** ខ្ញុំសូមលើកដៃគោរពលោកប្រធាន ហើយសូមគោរពចៅក្រមទាំងអស់ ចៅក្រមជាតិ ចៅក្រមអន្តរជាតិព្រមទាំង មេធាវីទាំងអស់ ព្រមទាំងព្រះរាជអាជ្ញាទាំងអស់ ព្រមទាំងមេធាវីខាងដើមបណ្តឹងទាំងអស់ ។ ហើយក៏ខ្ញុំសូមមានគោរពសង្ឃ គោរពភ្ញៀវបរទេស គោរពភ្ញៀវជាតិទាំងអស់ បាទសូមលើកដៃគោរព ។

[០៩:០៥:៥០]

**ស៖** អ៊ំមានអាយុប៉ុន្មានឆ្នាំហើយអ៊ំ?

**ឆ៖** ៧៩ឆ្នាំហើយ ។

**ស៖** អ៊ំមានទីលំនៅសព្វថ្ងៃនៅឯណាដែរ?

**ឆ៖** សង្កាត់ស្ទឹងមានជ័យ ខណ្ឌស្ទឹងមានជ័យ ។

**ស៖** អ៊ំប្រកបមុខរបរអីដែរសព្វថ្ងៃនេះ?

**ឆ៖** បាទ, សព្វថ្ងៃខ្ញុំអត់មានប្រកបមុខរបរអីទេ ជម្រាបលោកប្រធាន។

**ស៖** នៅក្នុងរឿងក្តីនេះ តាមសំណុំរឿងគឺ អ៊ំបានដាក់ពាក្យប្តឹងសុំតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណី ។ សំណួរសួរថា តើអ៊ំប្តឹងទាមទារសំណងដោយខ្លួនឯង ឬក៏ទុកនាទីនេះជូនទៅមេធាវីអ្នកតំណាងឲ្យអ៊ំក្នុងការប្តឹងទាមទារសំណង?

**ឆ៖** បាទ, កាលខ្ញុំដាក់ពាក្យបណ្តឹងហ្នឹង ខ្ញុំប្រគល់បញ្ហាសំណងហ្នឹង ប្រគល់លើមេធាវីខ្ញុំទាំងអស់ឲ្យគាត់ជួយហ្នឹង ។

**ស៖** តើអ៊ំដែលបានតាំងខ្លួនជាដើមបណ្តឹងរដ្ឋប្បវេណីហ្នឹង អ៊ំមានទំនាក់ទំនងយ៉ាងដូចម្តេចទៅនឹងអង្គហេតុដែលបានចោទប្រកាន់ចំពោះជនជាប់ចោទ តើវាពាក់ព័ន្ធនឹងអង្គហេតុណាមួយ ដែលអ៊ំមានទំនាក់ទំនង?

**ឆ៖** បាទ, ខ្ញុំមានការទំនាក់ទំនងអង្គហេតុហ្នឹងគឺថា ខាងជនជាប់ចោទហ្នឹង គេចោទខ្ញុំថា ខ្ញុំនេះចូល សេអ៊ីអា, កាហ្សេបេ ហ្នឹង ។

**ស៖** បានន័យថា អង្គហេតុចោទប្រកាន់ទៅលើជនជាប់ចោទហ្នឹង គឺនៅក្នុងរឿងមន្ទីរសន្តិសុខ ស-២១ ឬក៏មន្ទីរសន្តិសុខ ឬក៏មន្ទីរអប់រំកែប្រែសាជាថ្មីព្រៃស?

**ឆ៖** នៅស-២១ គេហៅ “ទួលស្លែង” ទាន ។

**ស៖** ហើយទំនាក់ទំនងនេះ គឺជាទំនាក់ទំនងផ្ទាល់ ខ្លួនអ៊ំផ្ទាល់ដែលជាជនរងគ្រោះនៅទីនោះ ឬក៏ក្រុមគ្រួសារញាតិមិត្តរបស់អ៊ំ ឬក៏ទាំងពីរ ទាំងអ៊ំផង ទាំងញាតិសន្តានគ្រួសាររបស់អ៊ំផង?

**ឆ៖** បញ្ហានេះគឺថា ខ្ញុំមានការទំនាក់ទំនងជាមួយគ្រួសារសម្រេចនឹងឲ្យដាក់ពាក្យបណ្ដឹងព្រម ទាំងបងប្អូនខ្ញុំ ។

[០៩:០៩:១១]

**ស៖** ទទួលរង ។ ឧបមាថាអ៊ំទទួលរងឥទ្ធិពល ឬក៏ទទួលរងអំពីអំពើឧក្រិដ្ឋដែលចោទប្រកាន់ ទៅលើជនជាប់ចោទហ្នឹង គឺផ្ទាល់ខ្លួនអ៊ំ? អ៊ីចឹង?

**ឆ៖** *(អត់ឮសំឡេង)*

**ស៖** អ៊ំកាលពីឆ្នាំ-- មុនឆ្នាំមួយពាន់ប្រាំបួននៅចិត-- ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ អ៊ំរស់នៅទី កន្លែងណា? ហើយប្រកបមុខរបរអ្វីដែរ?

**ឆ៖** ខ្ញុំបាទមុនឆ្នាំ៧៥ ខ្ញុំធ្វើជាមេកានិក ធ្វើត្រាក់ទ័រ ធ្វើឡានធ្វើអីហ្នឹង ។

**ស៖** ហើយនៅឯណាដែរអ៊ំ?

**ឆ៖** ភ្នំពេញ ។

**ស៖** ចុះនៅក្នុងថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ ដែលកងទ័ពខ្មែរក្រហមបានចូលមកដល់ទីក្រុង ភ្នំពេញ តើអ៊ំនៅឯណា? ហើយធ្វើអ្វីដែរ?

**ឆ៖** ក្នុង៧៥ហ្នឹង គឺថាខ្ញុំនៅក្នុងទីក្រុងភ្នំពេញ ។

**ស៖** មន្ត្រីតុលាការទាញក្បាលមីក្រូរបស់គាត់មក បានអូខេ ។ អ៊ំសួរថាថ្ងៃទី ១៧ ខែមេសា ឆ្នាំ១៩៧៥ កាលមុនហ្នឹងអ៊ំបានឆ្លើយរួចហើយ ហើយតុលាការមិនចង់ដឹងប៉ុន្មានទេ ។ ចង់ដឹងហ្នឹង គឺ បញ្ហាសំខាន់រហូតដល់ពាក់ព័ន្ធជាមួយនឹងមន្ទីរសន្តិសុខស-២១ទេ ប៉ុន្តែដើម្បីឲ្យបានយល់ថាជីវភាពរបស់ អ៊ំហ្នឹងចាប់ពីថ្ងៃ១៧ ខែមេសា ឆ្នាំ១៩៧៥ហ្នឹង រហូតដល់ និយាយរួម គឺដល់ថ្ងៃទី៧ ខែមករា ឆ្នាំ ១៩៧៩ហ្នឹងវាមានការប្រែប្រួលយ៉ាងម៉េចខ្លះ? ប៉ុន្តែវាមានដំណាក់កាលៗដែលត្រូវសួរអ៊ំណា? តុលាការ ចង់ដឹង ។ អ៊ីចឹង ទីមួយថាតើ ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ហ្នឹងអ៊ំនៅទីណា? ហើយធ្វើអ្វីដែរ?

[០៩:១១:៥០]

**ឆ៖** គឺ៧៥ហ្នឹង គឺថាខ្ញុំនៅជាមួយព្រះអង្គម្ចាស់ ចន្ទ័រង្សី នៅច្បារមន កំពង់ស្ពឺ។ ហើយដល់ ពេលវេលាអ៊ីចឹងទៅ ៧៤ហ្នឹង ជិតដាច់៧៤ហ្នឹង ចន្ទ័រង្សី គាត់ឲ្យខ្ញុំមកទីក្រុងភ្នំពេញវិញ ។ យកអេលីកូ

ទៅយកខ្ញុំពីច្បារមន មកឲ្យមកនៅភ្នំពេញវិញ ហើយគាត់គ្រាន់តែផ្តាំថា ឥឡូវប្អូនឯងទៅផ្ទះសិនទៅចាំម៉ែចៗ ចាំបងទៅហៅ ។

**ស៖** ថ្ងៃ១៧អ៊ំ ថ្ងៃ១៧ មេសា ១៩៧៥ បាននន័យថាថ្ងៃខ្មែរក្រហមចូលមកដល់ក្រុងភ្នំពេញ តើអ៊ំនៅឯណា? ហើយកំពុងធ្វើអ្វី?

**ឆ៖** សុំបន្តបន្តិចទៀតបានដល់រឿងហ្នឹង ។ ពេលនុ៎ងគឺថា ខ្ញុំចូលមកទីក្រុងភ្នំពេញ គឺថាខ្មែរក្រហមគឺថាផ្តោងៗគ្រាប់ពីភ្នំប្រសិទ្ធមក ផ្តោងគ្រាប់ពីវិហារសួគ៌មក ផ្តោងគ្រាប់ពីយើងនៅខាងតាខ្មៅមកចូលទីក្រុងភ្នំពេញហ្នឹង គឺថាមកហ្នឹងគឺថាឆេះ ខាងក្រោយវត្តនាគវ័នហ្នឹងក៏ឆេះ ហើយខាងទឹកល្អក់ហ្នឹងក៏ឆេះ ផ្តោងមកចូលគ្រប់ទិសទីទាំងអស់តែម្តង ។ ហើយពេលនុ៎ង គឺថាខ្មែរក្រហមគេចូលមកម៉ោងប្រាំបីព្រឹក ។ ចូលមកម៉ោងប្រាំបីព្រឹកហ្នឹង ខ្ញុំនៅម្តុំយើងផ្សារដេប៉ូ ហើយខ្មែរក្រហមគេចូលមកហ្នឹង បាញ់ចូលមកហ្នឹង គេស្រើៗហ្នឹង គេមូរជើងខោម្ខាង ហើយមូរដៃអាវម្ខាងលីបេម្នាក់មួយៗ ចូលមក ។

[០៩:១៣:៤៨]

**ស៖** អ៊ីចឹងបាននន័យថា នៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ គឺអ៊ំនៅឯទីក្រុងភ្នំពេញ អ៊ីចឹង?

**ឆ៖** បាទ ។

**ស៖** តើអ៊ំត្រូវបានកម្លាំងខ្មែរក្រហមជម្លៀសអ៊ំចេញពីក្រុងភ្នំពេញនៅថ្ងៃខែឆ្នាំណា? ហើយគេជម្លៀសអ៊ំហ្នឹងឲ្យអ៊ំទៅទិសខាងណានៃទីក្រុងភ្នំពេញ? គឺទៅ សំដៅទៅគោលដៅកន្លែងណា?

**ឆ៖** ជម្រាបលោកប្រធាន! គឺពេលវាចូលមកហ្នឹង ទាំងគេទាំងខ្ញុំហ្នឹង គឺថាឃើញគេចូលមកពេញហ្នឹង ខំលើកទង់ជ័យស ហ្នឹងគេហ្នឹងឯង ជ័យយោៗ ហ្នឹងគេហ្នឹងឯង ទាំងគេទាំងខ្ញុំស្រែកអ៊ីចឹងទាំងអស់គ្នា ។ តែដល់នាវេលាពេលល្ងាចយើងម៉ោងប្រាំកន្លះអីហ្នឹង គេដើរប្រាប់តាមផ្ទះ គេថាឲ្យពុកម៉ែថយចេញពីទីក្រុងភ្នំពេញចម្ងាយប្រាំគីឡូម៉ែត ។ ហើយពុកម៉ែ មិនចេញ គឺថាអាមេរិកាំងវាទម្លាក់គ្រាប់បែកងាប់អស់ហើយ ឲ្យពុកម៉ែចេញសិន ចេញឲ្យផុតពីភ្នំពេញប្រហែលជាប្រាំគីឡូ ។

**ស៖** អ៊ីចឹងពួកខ្មែរក្រហមជម្លៀសអ៊ំទៅកាន់គោលដៅណា? ទីកន្លែងណាដែរ?

**លោក ជុំ ម៉ី៖**

**ឆ៖** កាលនោះ គឺថាខ្ញុំឃើញ-- ដល់នេះអ៊ីចឹងមានប្រជាជនខ្លះគាត់អត់ព្រមចេញ ដល់ហើយខ្មែរក្រហមគាត់រះអ៊ីចឹង មួយរ៉ាវអ៊ីចឹងទៅ ឃើញដួលពីរនាក់បីនាក់ ខ្ញុំភ័យពេក ខ្ញុំរត់ទៅហៅកូនប្រពន្ធអីឲ្យ

ទៅធ្វើដំណើរឡើងមកខាងពេទ្យលោកសង្ឃ ។ ដើររហូតមក ពេលម៉ោងប្រាំមួយ គឺថាដើររហូតមកតាមផ្លូវហ្នឹងគឺចង្អៀតមែនទែន អត់មានទូលាយដើរបានស្រួលទេ គឺថាញែកគ្នាដើរតែម្តង ដើរចេញមកមករហូតមកដល់ផ្សារទឹកថ្លាយើងនេះ គឺថាជិតយប់ហើយ ដល់ជិតយប់អ៊ីចឹងគឺថា ខ្ញុំក៏សម្រាកនៅយើងកប់ស្រូវហ្នឹងមួយយប់ ។ ហើយនិងបន្ទប់មកទៀត គឺថាខ្ញុំក៏ធ្វើដំណើរមកដល់យើងផ្សារព្រែកព្នៅ មកដល់ព្រែកព្នៅគឺថានៅពេលយប់ យប់ហើយខ្ញុំមិនដឹងទៅរកទឹកឯណាដាំបាយបាន គឺថាមើលគ្នាអត់ស្គាល់ទេ ក៏នាំកូននាំចៅនៅមាត់ទន្លេហ្នឹងក៏ចុះដងទឹក ។ ដល់ចុះទៅដងទឹកមាត់ទន្លេហ្នឹង ពេលហ្នឹងគឺថាខ្ញុំជាន់ទៅលើខ្មោចទៀតហើយ ខ្មោចនៅគរតាមមាត់ទន្លេហ្នឹង ។ ហើយពេលដែលដាំបាយអី ដាំអីហូបហើយក៏នាំកូនចៅហ្នឹងសម្រាក សម្រាកម៉ោងបួនភ្លឺហ្នឹងគេដេញទៀតហើយ ។ ថាឲ្យធ្វើដំណើរទៅក៏នាំគ្នាធ្វើដំណើរទៅ ។ ហើយធ្វើដំណើរទៅនឹង ខ្ញុំជម្រាបប្រសាសន៍លោក គឺថាអាខាងឆ្វេងដៃហ្នឹងគឺថាអាស្រះហ្នឹងគេចិញ្ចឹមត្រី គេចិញ្ចឹមត្រី ប៉ុន្តែពេលនុ៎ង ពេលត្រីវាអត់ចំណី ឃើញខ្មោចហើមស្ពឹងៗដូចខ្មោចផ្អែអ៊ីចឹងនៅក្នុងស្រះទឹកហ្នឹង ។ ហើយអាត្រីហ្នឹងវាចេះតែចឹកអាខ្មោចហ្នឹងវេចុះវេឡើងៗអ៊ីចឹងទៅ ។ ហើយចាប់តាំងពីព្រែកព្នៅរហូតទៅហ្នឹង គឺថាលើថ្នល់ដូចយើងៗសង្កត់ចេកចៀនអ៊ីចឹង ឃើញលលាដ៍ក្បាល ឃើញឆ្អឹងអីតាមហ្នឹងរហូតទាល់តែដល់វត្តគ្រួស ។

**ស៖** វត្តគ្រួសនៅឯណាទៅ? វត្តគ្រួស?

**ឆ៖** ព្រែកក្តាមហ្នឹង។ ហើយដល់អ៊ីចឹងធ្វើដំណើរទៅទៀត គេឲ្យខ្ញុំឆ្លងទៅត្រើយខាងកើតព្រែកក្តាម ឆ្លងទូក ឆ្លងទៅត្រើយខាងកើត ។ ដល់ពេលនុ៎ង យប់ហ្នុងភ្លៀង ដល់ភ្លៀវអ៊ីចឹងកូនខ្ញុំម្នាក់ហ្នឹង គឺថាវាក្តៅរាកៗ ។ អ៊ីចឹង ខ្ញុំអត់មានថ្នាំ គេឲ្យខ្ញុំទៅសុំថ្នាំពីអង្គការៗ ។ ហើយខ្ញុំបាទចេះតែដើរទៅ ដើររកអង្គការ អត់ឃើញអង្គការ ទៅសួរឯណោះទៅ គេថាឲ្យទៅសុំអង្គការ ទៅឯណោះគេថាឲ្យទៅសុំអង្គការ តែមិនដឹងអង្គការហ្នុងឈ្មោះអី ហើយមិនដឹងអ្នកណាមួយអង្គការ ទាល់តែស្លាប់កូនទៅទាន ។ ស្លាប់កូនហ្នឹង ខ្ញុំក៏កូនស្លាប់ហើយក៏សុំខ្ចីអាចបៗកាប់គេ កាន់ចិញ្ចើមថ្នល់ហ្នឹង កប់កូននៅកន្លែងហ្នឹង កូនអាយុប្រហែលជាពីរឆ្នាំ ។

ហើយក្រោយទៀត ក៏ធ្វើដំណើរទៅទៀត គឺថាទៅហ្នឹងវេទនាណាស់ទាន ទៅវាអត់មានម្លប់ជ្រកទេ គឺថាទៅដើរឈើណា គឺគេនៅណែន ដើមឈើណាគេនៅណែន ឲ្យតែមានម្លប់គឺថាមនុស្សណែនៗតែម្តង ។ ហើយខ្ញុំបាទក៏មាននៅតែហាលក្តៅហ្នឹង បានអាភួយដណ្តប់ហ្នឹងដាក់ចងឲ្យកូនជ្រកនៅហ្នឹង ។ អត់មានម្លប់ជ្រកទេ ។ រហូតធ្វើដំណើរមកដល់យើងជើងឆ្នុកៗ វាមកដល់ថ្នល់កែងហ្នឹង

មកដល់ជើងឆ្នុកគេលែងឲ្យទៅហើយពេលហ្នឹង ។ គេលែងឲ្យទៅ ខ្ញុំមិនដឹងធ្វើម៉េច គេឲ្យចូលទៅក្រោយវត្តៗជើងឆ្នុកហ្នឹង ខាងក្រោយវត្តជើងឆ្នុកហ្នឹង គេឲ្យនៅសម្រាកហ្នឹងសិន ។ គេឲ្យអត់ទៅហើយខ្ញុំបាទក៏នៅហ្នឹងទៅ វាយប៉ន្ទុងភ្លៀងនៅក្រោមផ្ទះគេហ្នឹង ។ នៅក្រោមផ្ទះគេហ្នឹង ដល់វេលាភ្លៀងភ្លឺឡើងវាំង ភ្លឺវាំងខ្ញុំក៏ដើររកលូកក្ដាម លូកអីតាមភ្លឺស្រែហ្នឹង លូកក្ដាម លូកអីមក ទទួលឡានៗក្រុងដូចឡានយើងរាល់ថ្ងៃហ្នឹងគេប្រកាស គេថាបងប្អូនណាចេះធ្វើម៉ាស៊ីនឡាន ម៉ាស៊ីនត្រាក់ទ័រអីហ្នឹងអង្គការឲ្យចូលធ្វើការវិញៗនៅភ្នំពេញវិញ ខ្ញុំក៏ទៅសុំគេថា ខ្ញុំសុំចូលទៅធ្វើការនៅភ្នំពេញវិញ គេក៏សរសេរលិខិតមួយឲ្យអ៊ីចឹង ។ ដល់ហើយអ៊ីចឹង ខ្ញុំយកមកបង្ហាញអ្នកដែលឃាត់ខ្ញុំហ្នឹង ដល់បង្ហាញគេទៅ គេថាមិត្តឯងកុំចេញទៅពេលថ្ងៃ ចេញទៅពេលយប់ទៅ ។ ដល់ព្រលប់ៗបានឲ្យខ្ញុំចេញ ។ ចេញមកដល់ព្រែកក្ដាមយកក្រដាសហ្នឹងទៅឲ្យប្រធានគេ មិនដឹងប្រធានអីគេទេ ហុចគេទៅ គេយកអាហ្នឹងទៅគេថានៅហ្នឹងសិនហើយ ចាំរកបានប្រាំពីរនាក់ អ្នកចេះម៉ាស៊ីនហ្នឹង បានប្រាំពីរប្រាំបីនាក់ទៅសឹមទៅ ។ ហើយដល់នេះអ៊ីចឹង គេប្រមូលគ្នាបានប្រាំពីរនាក់ហ្នឹង មានតាចឺន មានតាសឿន មានតាផេងមានអីៗហ្នឹង គឺថាបានប្រាំពីរនាក់ ។

បានប្រាំពីរនាក់អ៊ីចឹង គឺថាគេឲ្យឡើងមកភ្នំពេញវិញៗដល់ហើយអ៊ីចឹង ខ្ញុំសួរថា ចុះគ្រួសារខ្ញុំយ៉ាងម៉េច? ហើយដល់ហើយគេថាអត់អីទេ គ្រួសារនៅហ្នឹងហើយ អង្គការមើលហើយ ។ ដល់អ៊ីចឹងខ្ញុំក៏ចុះកាណូតទៅមកឡើងយើងត្រង់ឫស្សីកែវហ្នឹងជិតរោងចក្រទឹកដោះគោហ្នឹង យកក្រដាសហ្នឹងមកបង្ហាញ មិត្តស្រ៊ីៗ ហ្នឹងទទួលខុសត្រូវនៅកន្លែងធ្វើកាណូតធ្វើកប៉ាល់ហ្នឹង ។ ឡើងប្រាំពីរនាក់ហ្នឹងព្រលឹមឡើងបានគេឲ្យយើងជួសជុលកាណូតកប៉ាល់ហ្នឹង ជួលជុលបាន-- បើតាមខ្ញុំដឹងប្រហែលជាដប់គ្រឿងជាង ដប់គ្រឿងជាងហ្នឹង ។ ដល់ជួសជុលបើកសាកចុះឡើងចុះអីបានសព្វគ្រប់អស់ហើយ បានគេដាក់ទ័ពៗគេហ្នឹងដាក់ពេញកាណូតហ្នឹង ។ ដាក់ទ័ពហ្នឹងចុះកាណូតហ្នឹងទៅ គេយកទៅខាងក្រចេះ ។

[០៩:២១:៥២]

ដល់ពេលវេលានេះអ៊ីចឹងក្រោយមក បានគេសួរខ្ញុំបាទ ណាចេះធ្វើត្រាក់ទ័រ ចេះធ្វើឡានអីហ្នឹងនៅឯណា? ហើយខ្ញុំឆ្លើយថា ខ្ញុំចេះធ្វើត្រាក់ទ័រ ធ្វើអីអ៊ីចឹង ។ ដល់ហើយមិត្តស្រ៊ី សួរថាមិត្តឯងចេះបើកត្រាក់ទ័រ បើកឡានទេ? ខ្ញុំថាចេះ ដល់ហើយគេថាឲ្យខ្ញុំហ្នឹងចុះត្រាក់ទ័រ អាប៉ិលហ្នឹងចុះទៅក្នុងសាឡាងត្រាក់ទ័រមួយ អាឡូមួយ ឡានបែនមួយ ចូលទៅក្នុងសាឡាងហ្នឹង គឺថាគេយកត្រាក់ទ័រហ្នឹងទៅក្រចេះហ្នឹង យកទៅក្រចេះ ដល់ហើយគេឲ្យខ្ញុំចុះតាមសាឡាងហ្នឹងដើម្បីទៅឡើងត្រាក់ទ័រ ឡើងឡានអីឡើង

លើច្រាំងវិញ ។ ទៅដេកនៅនុ៎ងមួយយប់បានគេបញ្ជូនមកវិញ ចុះមកវិញ ។ ហើយមកវិញហ្នឹង គឺថា មកដល់កន្លែងចាស់ហ្នឹង គេស្នើទៀត គេស្នើថា មិត្តណាដែលចេះស្គាល់រឿងបញ្ចោះត្រាក់ទ័រ បញ្ចោះឡានអីហ្នឹង គេស្នើឲ្យខ្ញុំមកនៅអូរឫស្សី មកឲ្យនៅអូរឫស្សី គេលែងឲ្យនៅនុ៎ងហើយ ។ នៅកន្លែងឫស្សីកែវនុ៎ង គ្នាប្រាំមួយនាក់ៗ ។ មកដល់អូរឫស្សីហ្នឹង មកដល់ហ្នឹងគេថា ឥឡូវប្រមូលអីវ៉ាន់តាមផ្ទះៗហ្នឹង ប្រមូលដាក់ឃ្លាំងដាក់អីហើយ គេសួរខ្ញុំ មិត្តគុណ ហ្នឹងសួរខ្ញុំថា មិត្តឯងចេះធ្វើមីក្រូទេ? បាទខ្ញុំចេះ ចេះធ្វើមីក្រូ ក៏គេឲ្យជួសជុលនៅកណ្ដាលផ្សារអូរឫស្សីហ្នឹង ។ ជួសជុលហ្នឹងអស់ចិត្តអស់ចង់ទៅចំនួនប្រហែលជាយើងបីបួនខែទៅ គេថាឥឡូវយើងលែងប្រមូលសម្ភារៈហ្នឹងហើយៗ ។ យើងប្រមូលសម្ភារៈម៉ាស៊ីនដេរវិញ ព្រោះអង្គការត្រូវការដេរខោអាវខ្មៅៗ ប្រមូលម៉ាស៊ីនដេរប្រមូលអីសព្វគ្រប់អីចឹងម៉ាស៊ីនដេរហ្នឹងប្រមូលបានទាំងអស់មួយម៉ឺនប្រាំពីរពាន់ក្បាលក្លួយ (១៧០០០ក្បាល) ។

[០៩:២៤:០៧]

ដល់ប្រមូលបានអីចឹង បានឃើញប្រជាជនទៅ ស្រីហ្នឹងស្លៀកខ្មៅពាក់ខ្មៅទៅនៅអូរឫស្សីហ្នឹងដេរ រៀនដេរខោអាវខ្មៅហ្នឹង ប្រហែលជាមួយពាន់នាក់ នៅអូរឫស្សីហ្នឹងប្រហែលជាមួយពាន់នាក់ ។ ហើយប្រុសៗហ្នឹងប្រហែលជាពីររយនាក់អីប៉ុណ្ណឹងទេ ។ ហើយខ្ញុំបាទក៏ចាប់ផ្ដើមនៅធ្វើការនុ៎ងតាំងពីចិតប្រាំ ចិតប្រាំមួយ ចិតប្រាំពីរ រហូតមកចិតប្រាំបី បានគេឲ្យខ្ញុំ-- គឺនេះខ្ញុំនិយាយកាត់ខ្លះៗហើយ គេឲ្យខ្ញុំហ្នឹងទៅជួសជុលឡាននៅវៀតណាមៗ ។ ក៏ប៉ុន្តែ មុននឹងឲ្យខ្ញុំទៅជួយជុលជុលឡាននៅវៀតណាមហ្នឹង ប្រធានខ្ញុំ ប៊ិក គុណ ហ្នឹង គេចាប់បាត់ហើយៗ ឡើង តាឃុំ មួយទៀត បានប៉ុន្មានខែចាប់ តាឃុំហ្នឹងទៀត ។ ចាប់តាឃុំ បាត់ទៅ ឡើងមិត្តយ៉ុង ។ មិត្តយ៉ុង ហ្នឹងគឺថា-- អាហ្នឹងខ្ញុំមិនដឹងទេបើតាមសម្ដីលោក ឌុច ថាមិត្តយ៉ុង ហ្នឹងក៏មានការនៅទើបនឹងមិត្តយ៉ុង ក៏មិនដឹង ឬក៏មិត្តយ៉ុង ណាក៏មិនដឹងទេ ។ នៅទទួលខុសត្រូវនៅហ្នឹង ។ ក្រោយមកបាត់ មិត្តយ៉ុង ហ្នឹង បានលេចឡើងនារីមកពីខាងតាកែវ ឈ្មោះមិត្តវ៉ាន់ៗមកនៅកន្លែងគ-៩ ហ្នឹង ។ មកនៅគ-៩ ហ្នឹង មិត្តវ៉ាន់ ហ្នឹងក៏មានឃើញមានឃើញមិត្ត លីម មួយទៀត មិត្តលីម ជនជាតិភាគតិចហ្នឹង មកធ្វើការនៅហ្នឹង ។ ពេលនុ៎ងហើយគេហៅខ្ញុំមកប្រាប់ គេថាឥឡូវមិត្តឯងទៅជួយធ្វើឡានអង្គការ ព្រោះអង្គការវាយវៀតណាម ។ ហើយខ្ញុំក៏បីនាក់ហ្នឹង គឺថាមិនប្រកែកទេ គឺថាស័គ្រចិត្តមកហើយ ព្រលឹមឡើងក៏លីកែសសោហ្នឹងយកមកគ-៩ ហ្នឹងគ-៩ ហ្នឹងគឺមន្ទីរគេ ។ លីមកដាក់លើឡាំប៉ាតាហ្នឹង គេថាឥឡូវកែសហ្នឹងមិនបាច់យកទៅទេៗ ទៅតែខ្លួនបានហើយ ។ អីចឹងបីនាក់ហ្នឹងគឺថាខ្ញុំមកតែខ្លួនទេ ។ មកឡើងជិះឡាំប៉ាតាមកៗ ខ្ញុំអត់

ដឹងទេ កន្លែងដែលគេបាំងស័ង្កសីហ្នឹងគឺថា បាំងតាំងពីវត្តមហាមន្ត្រីរហូតមកដល់ពេទ្យចិន គឺបាំងលិចក្បាលតែម្តង មើលគ្នាអត់ឃើញទេ បាំងស័ង្កសីរហូត ។

[០៩:២៦:២១]

ដល់អ៊ីចឹងគេយកមកចូលទួលស្លែងហ្នឹង ខ្ញុំអត់ដឹងថាកន្លែងហ្នឹងគេហៅថា "ទួលស្លែង"ផង អត់ដឹងទេក្មួយ ។ ដល់ក្រោយមកអ៊ីចឹង ចូលក្នុងផ្ទះខាងមុខ ផ្ទះគេលក់អីវ៉ាន់ហ្នឹងចូលទៅក្នុងហ្នឹងចុះពីឡាំប៉ាតាហ្នឹង គឺគេចាប់គ្រឹបៗតែម្តង ចាប់គ្រឹមជាប់អ៊ីចឹង គេដាក់ខ្នោះដៃៗ ហើយក្រមាយើងនៅកហ្នឹង គេយកមកចងមុខៗ ។ ចងមុខហើយបានបណ្តើរចូលមកក្នុងហ្នឹង បណ្តើរដល់ពាក់កណ្តាលហ្នឹងខ្ញុំនិយាយប្រាប់គេ ខ្ញុំថាបងៗសូមជួយមើលគ្រួសារខ្ញុំផង ។ ដល់អ៊ីចឹងវាថា ដល់ហើយវាធាក់ចង្កេះខ្ញុំដួលនៅផ្កាប់មុខនៅកណ្តាលថ្នល់ហ្នឹង វានិយាយថា ស្មាទោសទាន ខ្ញុំនេះបន្តិចហើយ វាជេរខ្ញុំថា "កណ្តួយម៉ែអ្អែង" គឺអ្អែងផ្តាំអី អង្គការត្រូវការកម្ទេចអ្អែងទាំងអស់ហ្នឹងហើយ អ្អែងមិនបាច់ផ្តាំទេ ។ បានវាយកចូលទៅក្នុងបន្ទប់វាស់កម្ពស់ ហើយនិងថតរូបថតអីហ្នឹងទាន ។ អាហ្នឹងចំណុចហ្នឹង ពេលនុំងមែនថាត្រជាក់ទេ ដូចលោក ឌុច គាត់មានប្រសាសន៍ហ្នឹង គឺថាខ្ញុំអត់ពេលត្រជាក់ទេ គឺក្តៅរហូតតែម្តង អត់មានរឿងសួរអង្កៀម អត់មានសួរត្រជាក់ សួរអីទេ គឺក្តៅងុំាំងរហូតតែម្តង ។ ស្គាល់តែ អាម៉ឹងម្រ៉ាយ អីនៅជាប់នឹងមាត់តែម្តង ។

ពេលយកទៅដល់ហ្នឹង គេសួរថាៗ "មិត្តឯងស្រុកកំណើតនៅឯណា? អីឯណា?" ខ្ញុំបាទប្រាប់តាមដំណើរអ៊ីចឹងទៅ គឺថាខ្ញុំនៅឃុំល្វា ស្រុកកំពង់ត្របែក ខេត្តព្រៃវែង និយាយប្រាប់សព្វគ្រប់អ៊ីចឹងទៅបានគេថតខ្ញុំ ថតហើយបានគេដោះអាវចេញ ។ ដោះអាវចេញគេសម្រាតខោៗចេញនៅតែខោខ្លីទេ ដល់ហើយស្បែកជើងយើងពាក់ហ្នឹង ក៏គេអត់ឲ្យពាក់ដែរ ដោះស្បែកជើងចេញនៅតែខោខ្លីមួយទេ គេដាក់ខ្នោះដៃយើងវិញ ដាក់ខ្នោះដៃយើងវិញ គេចងមុខជិតអ៊ីចឹង បណ្តើរមកកន្លែងលោកចៅក្រមលោកដឹងហើយកន្លែងខ្ញុំហ្នឹង គឺថាចៅក្រមស៊ើបអង្កេតគាត់ទៅថតកន្លែងនៅកន្លែងខ្ញុំហ្នឹង អារៀបឥដ្ឋបន្ទប់រៀបឥដ្ឋហ្នឹង ។ គេដាក់នៅហ្នឹងហើយ គេដាក់ច្រវាក់ជើងៗ គេដោះខ្នោះដៃចេញទាន ។ ដោះខ្នោះដៃចេញបានគេស្រាយមុខៗចេញ ។ ស្រាយមុខចេញហើយ គេដាក់ក្រណាត់បាំងវិញ ដាក់ក្រណាត់បាំងមកក្រណាត់បាវបាំងអ៊ីចឹង គេចេញទៅក្រៅៗអ៊ីចឹងមានអ្នកដើរយាមចុះឡើងៗតាមហ្នឹង ហើយរហូតទាល់តែដល់យើងម៉ោងប្រហែលមួយ ម៉ោងមួយៗបានគេមកដាក់ខ្នោះដៃៗវិញ គេចងមុខៗអ៊ីចឹង គេដោះខ្នោះជើងចេញៗ គេចាប់ទាញស្លឹកត្រចៀកខ្ញុំ ទាញស្លឹកត្រចៀកឲ្យឡើង ឡើងឈរ ខ្ញុំក៏ឡើងឈរ

មក ។ មកដល់មាត់ជណ្ដើរចុះ វាទាញស្លឹកត្រចៀកខ្ញុំ ទាញស្លឹកត្រចៀកខ្ញុំឲ្យចុះ អ្អែង! ចុះជណ្ដើរ ចុះជណ្ដើរទាញស្លឹកត្រចៀកឲ្យចុះអ៊ីចឹង ។ បណ្ដើររហូតទៅដល់អគារខាងត្បូង អាន៎ុងពេលឡើងៗវាទាញស្លឹកត្រចៀកខ្ញុំចង់ហើបពីដី ។ អ្អែង! ឡើងជណ្ដើរ ឡើងជណ្ដើរអ៊ីចឹងរហូតទៅៗដល់បន្ទប់មួយហ្នឹង វាឲ្យអង្គុយចុះទៅ ។ អង្គុយចុះទៅ វាដាក់ខ្នោះជើងវិញ ដាក់ខ្នោះជើងវិញ វាដោះខ្នោះដៃចេញក្អួយ ។ ដោះខ្នោះដៃចេញស្រាយមុខ ។ ស្រាយមុខចេញអ៊ីចឹង ខ្ញុំមើលឃើញអាកន្លែងហ្នឹង អាកន្លែងខ្ញុំអង្គុយហ្នឹង ឃើញសុទ្ធតែឈាមស្រស់ៗ មិនដឹងឈាមពីណាគេ ខ្ញុំអត់ដឹងដែរក្អួយ ឃើញឈាមស្រស់ៗ ។

[០៩:៣០:១៣]

ក្រោយមកអ៊ីចឹង ខ្ញុំក៏វាចាប់ផ្ដើមសួរហើយ ។ សួរថា “មើល! អ្អែងនិយាយឲ្យត្រង់មើល! គ្នាអ្អែងប៉ុន្មាននាក់ ចូល *សេអ៊ីអា, កាហ្សេបេ* ហ្នឹងអាណាខ្លះនាំអ្អែងចូល?” ដល់ហើយខ្ញុំក៏លើកដៃសំពះគេៗហ្នឹងគឺថា គេអត់មាននេះអីទេ គឺថាគេចាប់ផ្ដើម “អ្អែងមិនបាច់សំពះអញទេ អញមិនមែនលោកទេ អ្អែងសំពះអញ” ដល់ហើយខ្ញុំថា លោកខ្ញុំអត់ស្គាល់អារឿង *សេអ៊ីអា, កាហ្សេបេ* ហ្នឹងផង ។

តាមការពិតខ្ញុំអត់ស្គាល់មែន គ្រាន់តែឮសួរគេថា អារឿង *សេអ៊ីអា, កាហ្សេបេ* ហ្នឹង ខ្ញុំឮសួរគេថាមែនតែមិនដឹងតួនាទីគេធ្វើអីទេទាន ។ អត់ដឹងទេបាទ ។ ដល់អ៊ីចឹងខ្ញុំអង្វរគេថា លោកខ្ញុំអត់ស្គាល់ *សេអ៊ីអា, កាហ្សេបេ* ហ្នឹងផង គ្រាន់តែហៅលោកហ្នឹងគេវ៉ៃខ្ញុំអស់ហាសិបរំពាត់ វ៉ៃខ្ញុំហាសិបរំពាត់ ដល់វេលាហៅមិត្តទៀតវ៉ៃហាសិបរំពាត់ទៀត ។ អ៊ីចឹងខ្ញុំអត់ដឹងឲ្យគេហៅអី? ទាល់តែខ្ញុំសួរគេទៅឲ្យហៅ “បង” ។ គ្រាន់តែរកនឹកហៅគេ “បង” ហ្នឹងអស់មួយរយរំពាត់ហើយក្អួយ ។

ហើយចាប់ពីថ្ងៃហ្នឹងទៅគឺថា ចាប់ផ្ដើមវ៉ៃរហូតសួរហើយ សួររហូតៗៗៗអ៊ីចឹងតែម្ដង ។ ថ្ងៃមួយវ៉ៃខ្លាំងពេកខ្ញុំក៏យកដៃរងអ៊ីចឹងវាឈឺពេក យកដៃរកក៏បាក់កូនដៃខ្ញុំបាទ ។ បាក់អាកូនដៃហ្នឹង ដល់វ៉ៃបាក់កូនដៃអ៊ីចឹង ថ្ងៃក្រោយឃើញយកអាដែកកាប់ហ្នឹងមកមួលអាក្រចកមេជើងខ្ញុំហ្នឹង មួល យកដែកកាប់មួលអ៊ីចឹងវាអត់ដាច់ ដល់ហើយវាកន្ត្រាក់ៗអ៊ីចឹងទៅ ហើយជើងខ្ញុំបាទញ័រតតាត់តែម្ដង ជើងបាទ ។

[០៩:៣១:៥៧]

ក្រោយមកទៀត បានយូរណាស់ បានចំនួនប្រហែលជិតដប់ថ្ងៃ ដាក់ខ្សែភ្លើងខ្ញុំ ។ ខ្សែភ្លើងហ្នឹងមិនមែនដូចលោក ឌុច គាត់មានប្រសាសន៍ទេ ។ ខ្សែភ្លើងអាខ្សែភ្លើងតាមជញ្ជាំងហ្នឹងតែម្ដង អត់មានវ៉េអ៊ីចឹងទេក្អួយ ខ្សែភ្លើងតាមជញ្ជាំង ខ្ញុំមើលខ្សែភ្លើងមួយកំភ្លួស ។ ដល់ហើយដាក់អាខ្សែភ្លើងខ្ញុំហ្នឹង ក៏វាខ្ញុំទៅ គឺសន្លប់អត់ដឹងខ្លួនទេ អាភ្នែកយើងនេះចេញមកសុទ្ធតែភ្លើងមកតែម្ដង ហើយត្រចៀក

យើងហ្នឹងឮសូរតែម៉ាស៊ីនឆេះ ឮគឹកៗៗ ក្នុងត្រចៀកយើងហ្នឹងបាទ ។

ហើយអ្នកវ៉ៃហ្នឹងគឺថា ឈ្មោះ វា សូមទោស! ឈ្មោះវា អាសេង ទាន ។ អាសេង, អាទិត, អាហ៊ ។ អាហ៊ ហ្នឹងសម្គាកផ្ទាល់នេះៗបាទ តែឥឡូវតាមដែលខ្ញុំស្រាវជ្រាវទៅថាបីនាក់ហ្នឹង ងាប់ទាំងបីនាក់ហ្នឹងបាទ ។ អាហ្នឹងបានជាខ្ញុំជម្រាបលោក ឌុច ចុះបញ្ហាហ្នឹង សំណាងឲ្យលោក ឌុច អត់វ៉ៃខ្ញុំ បើលោក ឌុច វ៉ៃខ្ញុំលោក ឌុច អត់មានឃើញពន្លឺថ្ងៃទេ! ហ្នឹងជម្រាបឲ្យត្រង់អ៊ីចឹងតែម្តង ។

[០៩:៣៣:១៥]

**ប្រធានអង្គជំនុំ៖**

សូមរៀបចំនៅអារម្មណ៍ឲ្យនឹងនរ ហើយធ្វើការនិយាយស្តីវាឲ្យមានគុណធម៌ល្អ ចៀសវាងការប៉ះពាល់ព្រោះទីនេះសវនាការ វាជារឿងមួយដែលយើងត្រូវជជែកវែកញែក សំខាន់គឺច្បាប់អង្គហេតុហើយនិងអង្គច្បាប់ដើម្បីយកមកពិភាក្សា អ៊ំផ្តល់យោបល់ជាសិទ្ធិរបស់អ៊ំ ក្នុងការបង្ហាញនូវទិដ្ឋភាពទាំងឡាយដែលអំពើរបស់កងកម្លាំងខ្មែរក្រហម ទាំងថ្នាក់ដឹកនាំទាំងបុគ្គលិកដែលបានប្រព្រឹត្តចំពោះអ៊ំទាំងរូបរាងកាយផ្ទាល់ ទាំងស្មារតី និងទាំងទិដ្ឋភាពផ្សេងទៀតដែលអ៊ំមានលទ្ធភាពអាចផ្តល់ព័ត៌មានដល់ តុលាការ ហើយទោះបីយ៉ាងណាយើងប្រើអាកប្បកិរិយាថ្លៃថ្នូរដើម្បីជជែកវែកញែកគ្នា ។ ហើយកំហុស ឬក៏ត្រូវ ឬក៏ការវិភាគបកស្រាយច្បាប់នុ៎ង អង្គជំនុំជម្រះនឹងយកព័ត៌មានទាំងអស់ទៅពិភាក្សាដើម្បីចេញសេចក្តីសម្រេចមួយសម្រាប់ការផ្តន្ទាទោស ។ អ៊ីចឹងគឺលទ្ធភាព គឺទុកលទ្ធភាពជូនមកខាងអង្គជំនុំជម្រះជាអ្នកដោះស្រាយចុះ ។

អ៊ីចឹងសូមបន្តទៅទៀត អ៊ំបន្តទៅទៀត រឿងរបស់អ៊ំ គឺអាចបន្តនូវទិដ្ឋភាពទាំងឡាយដែលអ៊ំបានជួបប្រទះនៅក្នុងអំឡុងពេលនោះរហូត ។ អ៊ំអាចនិយាយរហូតដល់ពេលរំដោះដោយកងទ័ពរណសិរ្សសាមគ្គីរំដោះជាតិខ្មែរ ដែលគាំទ្រដោយវៀតណាមចូលមករំដោះប្រជាពលរដ្ឋយើងឲ្យបានរស់រានមានជីវិតឡើងវិញ ។

អ៊ំអាចបន្តទៀតនូវទិដ្ឋភាពទាំងឡាយដែលអ៊ំបានជួបប្រទះនៅក្នុងអំឡុងពេលក្នុងគុកទួលស្លែង គុកស-២១ ក៏ដូចជា ក្នុងអំឡុងពេលដែលអ៊ំបានចាកចេញនៅថ្ងៃទី៧ រហូតដល់ពេលអ៊ំបានវិលត្រឡប់មកក្រុងភ្នំពេញវិញ ។ សូមអញ្ជើញ ។

[០៩:៣៥:០៣]

**លោក ជុំ ម៉ី៖**

ប្រសាសន៍លោកឲ្យបានជ្រាបថា អ្វីបើខ្ញុំបាទមិនឆ្លើយការពិត បើខ្ញុំបាទមិនធ្វើអ៊ីចឹង លោកប្រហែលជាអត់ដឹងអារឿងរ៉ាវហ្នឹងទេ ព្រោះអារឿងរ៉ាវហ្នឹង វាសុទ្ធតែពេលដែលចូលទៅហ្នឹងដែលខ្ញុំថាអត់មានធម៌ត្រជាក់ហ្នឹង វាអាមឹងរហូតបាទ ។ អាម៉ឹងរហូត ហើយម៉ាយគឺថា ជាប់រហូតតែម្តង ។ ម្រ៉ាយខ្ញុំ កណ្តួយម៉ែអ្អែង អ្អែងអត់ព្រមឆ្លើយ ហ្នឹង អាហ៊ែ អាផ្សេងប្រាប់ អាសេង ប្រាប់វាៗអាហ៊ែ ។ ហ៊ែ ហ្នឹងមួរដៃអាវអ៊ីចឹងតែម្តង មួរដៃអាវដាក់ខ្ញុំបាទផាំងៗៗបាក់អស់រំពាត់មួយយករំពាត់មួយទៀតវ៉ៃខ្ញុំទៀតផាំងៗៗទៀត វាគ្រវាត់រំពាត់ចោល ។ គ្រវាត់រំពាត់ចោលហ្នឹង ហ៊ែ ហ្នឹង! អាហ្នឹងគឺថាខ្ញុំជម្រាបប្រសាសន៍លោកចៅក្រមតាមដំណើរអ៊ីចឹងទេ អានេះគេការពិត ។ បាទបើខ្ញុំមិនឆ្លើយការពិតក៏វាមិននេះដែរទានបញ្ហាហ្នឹង ។

[០៩:៣៦:០៨]

**ប្រធានអង្គជំនុំ៖**

អរគុណណាស់ដែលអ៊ំបានផ្តល់ព័ត៌មានការពិតនេះ ។ ប៉ុន្តែ រំឭកអំមិញគឺមានការការនិយាយប៉ះពាល់ទៅដល់ជនជាប់ចោទ អំពីយើងថា ហាក់ដូចជា ការយើងផ្តន្ទា ឬក៏ថាគាត់នឹងៗទទួលអីៗអ៊ីចឹងបើសិនជាវ៉ៃអ៊ីចឹង! យើងចង់ថា ប្រើពាក្យថ្លៃថ្នូរកុំឲ្យវាមានការប៉ះពាល់ដូច្នេះ ។ យើងនិយាយនៅក្នុងក្របខ័ណ្ឌបច្ចេកទេស ហើយច្បាប់ ឬក៏ហេតុដែលកើតមានឡើងជាក់លាក់ដែលអ៊ំបានលើកឡើងសព្វគ្រប់គឺជាការត្រឹមត្រូវណាស់ ។ នេះជាព័ត៌មានដែលអង្គជំនុំជម្រះ ឬក៏អង្គសវនាការចង់បាន ប៉ុន្តែមិនចង់បានត្រង់ថា និយាយទៅប៉ះពាល់បុគ្គលណាមួយមានលក្ខណៈគេហៅថា វាមិនត្រឹមត្រូវ វាមិនត្រឹមត្រូវ មិនគួរនិយាយនូវពាក្យខ្លះគឺយើងមិនគួរនិយាយទេ នៅពេលនេះ ។ បានន័យថា យើងនិយាយនៅក្នុងពាក្យត្រឹមត្រូវ ។

បន្តទៀត អ៊ំបន្តទៀត ។

**លោក ជុំ ម៉ី៖**

**ឆ៖** ហើយបន្ទាប់មកទៀតហ្នឹង គឺថាគេវ៉ៃខ្ញុំ វ៉ៃដប់ពីរថ្ងៃ ដប់ពីរយប់ ។ វ៉ៃយប់ក៏វ៉ៃ ថ្ងៃក៏វ៉ៃ តែម៉ោងប្រាំពីរព្រឹកគេ យកទៅហើយ យកទៅអគារខាងត្បូងនុ៎ង យកទៅខាងលើ អាលើបំផុតហ្នឹងយកទៅកន្លែងនុ៎ង ។ ទៅបណ្តើរខ្ញុំបាទទៅដល់ អាត្រង់កន្លែងគេដាក់ម៉ាស៊ីនភ្លើងហ្នឹងវាមានគល់ឈើមួយនៅទទឹងផ្លូវហ្នឹង ដល់ហើយខ្ញុំដើរជល់អាគល់ឈើនឹង គេចាប់ទាញសក់ក្បាលខ្ញុំ គឺថា គេថា "អ្អែងដើរភ្លើទេ អ្អែងអត់មើលទេ" ហើយខ្ញុំបាទក៏មិនប៉ានតគេដែរ មើលម៉េចគេចងភ្នែកជិតទៅហើយ

បាទបញ្ហាហ្នឹង ។ ហើយទៅដល់អគារខាងត្បូងហ្នឹង ស្លឹកត្រចៀកហ្នឹងចង់ៗរយះអស់ហើយ ទាញឡើងរហូតអ៊ីចឹងដល់វិញទាញចុះរហូតអ៊ីចឹង គឺថា ពេលម៉ោងប្រាំពីរព្រឹកហ្នឹងរហូតដល់ម៉ោងដប់មួយថ្ងៃត្រង់ ។ ម៉ោងដប់មួយថ្ងៃត្រង់ហ្នឹង គឺគេឲ្យទឹកបបរៗមួយវែកទេក្លួយ អត់មានគ្រប់អង្ករទេ ។ ដល់វេលាម៉ោងមួយបានគេចាប់ផ្តើមទៅទៀត ។ ម៉ោងមួយជាងហ្នឹងគេមកយកទៅទៀត រាល់ថ្ងៃអ៊ីចឹងតែម្តងគឺថាគេដាក់ខ្នោះដៃ គេចងមុខស្អីហើយអ៊ីចឹងយកទៅអគារខាងត្បូងសួរអារឿង *សេអ៊ីអា, កាហ្សេបេ* ហើយខ្ញុំថា ខ្ញុំអត់ស្គាល់ផងហើយគេនៅតែសួរវើៗ អារឿងហ្នឹងដប់ពីរថ្ងៃ ដប់ពីរយប់ទាន ។

[០៩:៣៨:៤២]

បាទដល់ក្រោយមកអ៊ីចឹង គឺថាគ្រប់ដប់ពីរថ្ងៃដប់ពីរយប់ហ្នឹង បានមានពួកគេហ្នឹងម្នាក់មកប្រាប់ថា មិត្តឯងកាលណាដេកយប់អីបង្រះអ៊ីចឹងទៅសុំគេទៅ បងៗ ខ្ញុំសូមប្រែខ្លួន ។ បើយើងប្រែខ្លួនអត់បានសុំគេឮសួរអាច្រវាក់ហ្នឹងរ៉ឹងហ្នឹង គេថាយើងកាច់ច្រវាក់ហ្នឹង ម្លោះហើយគេវ៉ៃយើងពីរយរំពាត់ ។ កាច់ច្រវាក់ហ្នឹង ម្លោះហើយយើងគោរពតាមគេហ្នឹងតែម្តង យើងអត់ប៉ានធ្វើអីទេ រហូតដល់ទីបញ្ចប់គឺថាមាន មិត្តធី ។ ឈ្មោះមិត្ត ធី មកដល់សួរថា “អាណាមួយអ្អែងមកពីអូរឫស្សីហ្នឹង! អាណាអ្អែងមកពីអូរឫស្សីហ្នឹង អ្អែងចេះធ្វើម៉ាស៊ីនដេរ?” ហើយខ្ញុំឆ្លើយប្រាប់ថា បងខ្ញុំចេះបង ដល់ហើយថា “អាអ្អែងស្អែកចេញធ្វើម៉ាស៊ីនដេរ តែអ្អែងកុំរត់! តែរត់បាញ់អ្អែងចោល” ហើយខ្ញុំបាទក៏ថា “ខ្ញុំអត់រត់ទេបង” ។

ដល់នេះអ៊ីចឹង ព្រលឹមឡើងឃើញយកខោអាវខ្មៅៗហ្នឹងមកឲ្យខ្ញុំស្លៀកពាក់ ហើយបញ្ចេញទៅខាងក្រោយ បញ្ចេញទៅធ្វើការខាងក្រោយហ្នឹង ខាងក្រៅរបងហ្នឹង ។ អាកន្លែងខាងក្រៅរបងហ្នឹងមានគេបបរបាយ មានគេដាក់អាគំនរខោអាវខ្ពស់អ៊ីចឹង គំនរខោអាវហ្នឹង ហើយគេឲ្យខ្ញុំរុញអាភ្លើងបបរៗបាយហ្នឹងឲ្យខ្ញុំរុញ ថា “មិត្តឯងនៅជិតហ្នឹង រុញភ្លើងបបរផង” ហើយគេដួសបបរអស់ទៅនៅអាកាកៗហ្នឹងមិត្តឯងហូតទៅ ។ ហើយខ្ញុំក៏ធ្វើដំណើរតាម គេអ៊ីចឹង គេរុញភ្លើងបបរអីឲ្យគេអ៊ីចឹង ហើយនៅសល់កាកៗខ្ញុំឈូសអាក្តាំបបរហ្នឹងមកធ្វើម៉ាស៊ីនដេរផង ហូបផង ហើយវាប្រាប់ថា “កុំឲ្យបងៗឃើញអ្អែង! បងៗឃើញវ៉ៃអ្អែង” ដល់ហើយខ្ញុំឃើញគេមកអ៊ីចឹង ញាត់អាក្តាំបបរហ្នឹងទៅម៉ាស៊ីនដេរហ្នឹង ។ ហើយពេលនោះ ខ្ញុំជួបលោក ប៊ុច ទៀត ស្រាប់តែលោក ប៊ុច ដើរមកខ្ញុំថា លោក ប៊ុច តើ! ហើយលោក ប៊ុច នឹងគាត់ធ្វើការជាមួយគ្នាពីសង្គម ។ គាត់ក៏ម៉េកានីក ខ្ញុំក៏ម៉េកានិចដែរ ធ្វើការជាមួយគ្នា ។ ដល់នេះអ៊ីចឹងអត់ប៉ាននិយាយគ្នាទេក្លួយ អត់ប៉ាននិយាយរកគ្នាទេ ។ គ្រាន់តែថា នៅធ្វើម៉ាស៊ីនដេរហ្នឹង

ប្រហែលម៉ាស៊ីនដេរហ្នឹង ប្រហែលជាសាមសិបគ្រឿង ធ្វើហើយៗ គេសួរ អ្អែងចេះធ្វើម៉ាស៊ីន អង្គុលីលេខទេ? ខ្ញុំថា ខ្ញុំចេះបងៗ ខ្ញុំចេះតើ! បាទធ្វើអាម៉ាស៊ីនអង្គុលីលេខហ្នឹងឲ្យគេបានពីរគ្រឿង ។

[០៩:៤១:១២]

ក្រោយមកបានគេឲ្យទៅធ្វើម៉ាស៊ីនបូមទឹក ចេះធ្វើម៉ាស៊ីនបូមទឹកទេអ្អែង? ចេះ! ម៉ាស៊ីនបូមទឹកក៏ចេះ ម៉ាស៊ីនត្រាក់ទ័រក៏ចេះដែរ ឲ្យធ្វើអាម៉ាស៊ីនបូមទឹកហ្នឹង វាឲ្យខ្ញុំបានទៅបង្រៀននារីផង មាននារីពីរនាក់ បង្រៀន ។ ថ្ងៃមួយឮសូរអាកប៉ាល់ហោះមិនដឹង ឮសូរក្តុងៗបីដងក្អួយ បីដងអ៊ីចឹង ។ ដល់ហើយអ៊ីចឹងក៏បានប្រហែលជាបីថ្ងៃពួកនុ៎ងគេប្រែហើយ ពួកយាមពួកអីហ្នឹងគេប្រែអាទុសសៀអីនៅជុំវិញខ្លួនទាំងអស់ហ្នឹង ។ មុនដំបូងអត់មានក្រទុសសៀ អត់មានស្អីៗទេ គឺថាមានតែកាំភ្លើងយាមទេ ដល់ពេលហ្នឹងមានក្រទុសសៀអីយាមនៅតាមមាត់ទ្វារហ្នឹង ដល់ហើយអ៊ីចឹងខ្ញុំក៏នៅធ្វើម៉ាស៊ីនដេរ-- ធ្វើម៉ាស៊ីនបូមទឹកនៅនុ៎ង ។

[០៩:៤២:១២]

មានថ្ងៃមួយស្រាប់តែឮសូររថក្រោះមកពីច្បារអំពៅមក គឹកៗអ៊ីចឹងហើយអាកាំភ្លើងចេះតែបាញ់មកគ្រាំៗចូលមកភ្នំពេញហ្នឹង ហើយមានពួកគេនឹងម្នាក់នុ៎ងគឺថា គេជិះម៉ូតូមកគេប្រាប់នារីហ្នឹងថាអត់ស្រួលទេ នារី តោះទៅផ្ទះវិញ ។ គេហៅនារីនុ៎ងទៅ ទទួលខ្ញុំនៅឡេឡានុ៎ងអត់ដឹងទៅណា ពេលនុ៎ងពួកគេហ្នឹង លោក ប៊ិច អីគាត់ចូលក្នុងអាបន្ទាប់ វ៉ាន់ ណាត គូររូបហ្នឹង ចូលហ្នឹងអស់អ្នកដែលសេសសល់ទាំងប៉ុន្មាន ហើយខ្ញុំចូលមកក្រោយគេ ។ ចូលមកក្រោយគេហ្នឹង វាជេរថា អាចុយម្រ៉ាយអ្អែងក៏យឺតយ៉ាវម្ល៉េះបាញ់អ្អែងចោលចុយម្រ៉ាយឥឡូវ ប៉ុន្តែពេលនុ៎ងមានកូនក្មេងពីរនាក់នៅនុ៎ង ។ កូនក្មេងពីរនាក់តូចៗនៅនុ៎ង កូននុ៎ងខ្ញុំសួរអ្នកបបរនឹងថា មិត្តនារីកូននឹងកូនពីណាគេ នារីនុ៎ងឈ្មោះមិត្តសុខ ខ្ញុំសួរអ៊ីចឹងថា កូនហ្នឹងកូនអ្នកណាគេ? ហើយវាថា កូនលោកតា ចេង អន តែប៉ុណ្ណឹងខ្ញុំក៏-- អាក្មេងនុ៎ងវានេះនៅខាងក្រៅបងនោះទៅ ហើយខ្ញុំចូលមកក្នុងទៅ ។ ហើយដល់ចូលមកក្នុងអ៊ីចឹងវាឲ្យចូលក្នុងអាបន្ទប់គូរគំនូរហ្នឹងៗចូលក្នុងហ្នឹង ។ ខ្ញុំមិននឹងចូលនឹងឃើញពួកវាបួនប្រាំនាក់ដកគន្លឹះគ្រប់បែកកាន់ម្នាក់មួយៗនៅតាមអាមាត់បង្អួចហ្នឹង ដល់ហើយខ្ញុំចូលទៅខ្ញុំខ្លាចវាបោះគ្រប់បែកទៅ ខ្ញុំចូលក្រោមតុ ។ ចូលក្រោយតុបានប្រហែលជាយើងម៉ោងដប់មួយៗ បានចេញទៅ ។ បញ្ចេញពួកខ្ញុំនឹងទៅអារថក្រោះវាទៅខាងកើតផ្សារថ្មីអស់ហើយ ដល់បញ្ចេញពួកខ្ញុំទៅវាឲ្យទៅបណ្តើរភ្ជង់ជាប់រហូតអ៊ីចឹងតែម្តង គឺកាំភ្លើងភ្ជង់ជាប់អ្អែងកុំរត់ដើរឲ្យត្រង់ទៅ! កុំរត់ ដើរអ៊ីចឹងទៅដល់កាច់ជ្រុងអារឿងផ្លូវហ្នឹង ចូលក្នុងផ្ទះថ្មហ្នឹង

អាផ្ទះវីឡាហ្នឹង ចូលមួយសម្ទុះធំបានវាឲ្យធ្វើដំណើរទៅលើទូតចិនៗហើយទៅលើវត្តសន្សំកុសលៗហ្នឹងនៅអង្គុយនឹងទាល់តែយប់ ហើយអាហ្នឹងស្តាប់ឮសូរតែកាំភ្លើងគ្រាំៗអាកប៉ាល់ហោះអឺង៉ាវៗចុះង៉ាវឡើងៗពេញហ្នឹងតែទាំងអស់ហ្នឹង ។ ដល់នៅវត្តសន្សំកុសលឮនឹងទាល់តែព្រលប់មើលគ្នាអត់ស្គាល់បានបណ្តើរទៅតាមចម្ការដូងហ្នឹង ។

[០៩:៤៤:៤៥]

ទៅតាមចម្ការដូងហ្នឹង យប់ខ្ញុំមើលទៅបែបវង្វេងដែរ វាច្រឡំដែរ ប្រហែលទៅអង្គុយត្រង់បឹងជើងឯងហ្នឹងក៏មិនដឹងអីក៏មិនដឹងអង្គុយមួយសម្ទុះតែវាធុំក្លិនស្អុយទៅ បានមួយសម្ទុះធ្វើដំណើរទៅព្រៃស ដល់ទៅព្រៃសទៅអង្គុយនៅព្រៃសនោះអត់មានមនុស្សទេស្ងាត់ជ្រាប ។ អង្គុយហ្នឹងទៅ ដល់ហើយរៀបភ្លឺបានធ្វើដំណើរទៅទៀត ។ ធ្វើដំណើរទៅទៀតហ្នឹងគឺថា ទៅដល់អារឿងអង្គស្នួលហ្នឹងភ្លឺប្រហែលជាម៉ោងប្រាំពីរព្រឹកភ្លឺនៅហ្នឹង ស្រាប់តែឃើញគ្រួសារខ្ញុំនៅហ្នឹង ។ គ្រួសារខ្ញុំ ខ្ញុំអត់ដឹងគេចាប់គ្រួសារខ្ញុំមកអាព្រៃសទេ អត់ដឹងទេ ។ ឃើញគ្រួសារខ្ញុំនៅហ្នឹង ហើយនារីៗប្អូនប្រាំនាក់នៅអាកន្លែងចំការឪឡឹកហ្នឹង គឺថាដល់ឃើញអីចឹងខ្ញុំថា “បងៗខ្ញុំសុំជួយបីកូនខ្ញុំទៅផង” ដល់ហើយវាថា “អើ! ជួយបីកូនទៅផងទៅ” បានក៏នាំគ្នាទៅនារីអីហ្នឹងឆ្លងថ្នល់ទៅខាងជើងទៅ ។ ទទួលកំពុងតែឆ្លងហ្នឹងឡានវៀតណាម អា*សេអ៊ិនសេ* វៀតណាមពីរឡានមកដល់ហ្នឹងគឺថាវាបាញ់ផ្តាច់ត្រឹមហ្នឹងតែម្តង ។ ផ្តាច់មួយកំណាត់ថយក្រោយវិញ មួយកំណាត់ទៅឡើង ។ ខ្ញុំឡើងហួសហើយ ហើយមួយកំណាត់ដោយលោក ប៊ុច អីហ្នឹង, វ៉ាន់ ណាត អីហ្នឹង ត្រឡប់មកក្រោយវិញ ។ ខ្ញុំឡើងទៅហួស ឡើងទៅជាមួយតាតួន, ជាមួយ តាឌីផុន ពេទ្យធ្មេញ ហ្នឹង ឡើងទៅ គេឲ្យសំដៅទៅអមលាំង ។

ខ្ញុំក៏សំដៅទៅអមលាំងហ្នឹង តែគេរត់ចោលខ្ញុំអស់ហើយ អត់មាន ពួកអស់នុ៎ងអត់មានការពារខ្ញុំអីអត់ទេ គឺថារត់ចោលខ្ញុំអស់ នៅគ្នាបីនាក់ ។ គ្រួសារខ្ញុំហ្នឹងមួយ, តាអេង កំពង់ចាមហ្នឹងមួយ ហើយខ្ញុំមួយ បីនាក់ ។ ចេះតែដើរៗៗទៅតាមក្រោយគេហ្នឹង គេទៅៗៗយើងដើរតាមក្រោយគេទៅ ហើយយើងទៅដល់អាគេហៅវត្តមួយ គេហៅវត្តស្រះធុល ។ វត្តស្រះធុលហ្នឹងព្រលប់ៗខ្ញុំចូលទៅសុំអង្ករគេបបរបាយហូប ។ ដើរទៅដល់នុ៎ងចូលក្នុងវត្តហ្នឹងស្រាប់តែឃើញទាហានពួកខ្មែរក្រហមប្រហែលជា៥០នាក់នៅវត្តស្រះធុលហ្នឹង ដល់ហើយខ្ញុំចូលសុំអង្ករគេ គេសួរថា “មិត្តឯងមកពីណា?” ខ្ញុំថា “ខ្ញុំមកពីកន្លែងកាត់ដេរ” ដល់អីចឹង “ស្រុកកំណើតនៅឯណាអីនៅឯណា?” ខ្ញុំថា “នៅខាងបូព៌ា នៅខាងព្រៃវែង” ដល់អីចឹង “អើ! អីចឹងនៅហ្នឹងសិនហើយ ចាំសុំសំបុត្រពីអង្គការបានទៅ ចាំទៅ” ។ ខ្ញុំក៏នៅហ្នឹង នៅហ្នឹងគេ

ឲ្យអង្គុយគ្រែមួយនៅមុខសាលាលោកឆាន់ហ្នឹង នៅអង្គុយនឹងគ្រែហ្នឹង ដល់ហើយប្រហែលជាខ្ញុំប៉ាន់មើលប្រហែលជាយប់យើងម៉ោងដប់ពីរក៏មិនដឹងអីមិនដឹង ម៉ោងដប់ក៏មិនដឹង ទាហានចេញអស់ទៅៗ នៅឈ្លបម្នាក់ស្ពាយអាកាំភ្លើងការ៉ូប៊ីនហ្នឹង នៅដើរជុំវិញអាគ្រែខ្ញុំដេកហ្នឹង ។ ដល់ហើយម៉ោងដប់ពីរអ៊ីចឹង ស្រាប់តែឃើញគ្នាវាបីនាក់ទៀតចូលមកកាំភ្លើងអាកាគ្រប់ដៃតែម្ដង ។ សួរថា "ឯណាបីនាក់ដែលយកទៅវៃចោលហ្នឹង?" ហើយអាឈ្លបហ្នឹងវា "នេះនៅដេកលើគ្រែហ្នឹង" ដល់ដេកលើគ្រែហ្នឹង ខ្ញុំក៏ភ្ញាក់ឡើង ភ្ញាក់ឡើងទៅវាថា "ឥឡូវបានសំបុត្រពីអង្គការហើយ តោះវាជូនទៅ ជូនដំណើរទៅ" ដល់អ៊ីចឹងវាថា "មិត្តនារីដើរទៅមុនទៅ មិត្តនារីដើរយឺតណាស់ មិត្តនារីឯងដើរទៅមុនទៅ" ទៅគ្រួសារខ្ញុំហ្នឹងក៏បីអាកូនទើបនឹងកើតបានពីរខែហ្នឹងបីទៅជាមួយហ្នឹង គឺទៅដល់ប្រហែលជាទៅពីវត្តប្រហែលជាមួយគីឡូដី ខែភ្លឺ ដល់ហើយអ៊ីចឹងក៏ស្រាប់តែវាបាញ់ៗរះទៅលើគ្រួសារខ្ញុំហ្នឹង រ៉ាវៗៗ ខែភ្លឺហ្នឹង គ្រួសារខ្ញុំស្រែក "ប៉ាអាភាពអើយ រត់ទៅគេបាញ់ខ្ញុំហើយៗ" ដល់មួយបន្តិចបាត់មាត់ទៅ ។ បានបាញ់លើ តាអេង ហ្នឹងទៀត ។ តាអេង នៅពីមុខខ្ញុំហ្នឹង បាញ់រ៉ាវៗ តាអេង ដួសព្រួសទៅ ស្រែក "ម៉ី រត់ទៅគេសម្លាប់ហើយ ម៉ី ឯងនៅធ្វើអីរត់ទៅៗ" ខ្ញុំក៏រត់ទៅ ។

[០៩:៤៨:៤៥]

វាផ្ទុកខ្ញុំប្រហែលពីហ្នឹងទៅនុ៎ងដែរ វាបាញ់ អារះអស់មួយបង់អ៊ីចឹងទៅ ប្រហែលវាច្រកមួយបង់ទៀតក៏មិនដឹងអីមិនដឹង ហើយវាស្ងាត់ទៅ ខ្ញុំគេចក្នុងដំបូក ។ ដល់ហើយគេច ខ្ញុំអត់ចូលដំបូកទេ ខ្ញុំផ្ដួលខ្លួនលូនអែបភ្លឺស្រែអ៊ីចឹងតែម្ដងលូន ។ ខែភ្លឺទេ តែវាថាចូលដំបូកហ្នឹងម៉េញៗ តែវាបាញ់ក្នុងដំបូកហ្នឹងពេញដំបូកហ្នឹង ។ ការពិតខ្ញុំលូនទៅឆ្ងាយហើយ ហើយខ្ញុំឡើងរត់ទៅៗ ។ ជម្រាបប្រសាសន៍លោកមិនដឹងរត់ទៅឯណាទេ ព្រោះយើងវង្វេង ខ្ញុំមិនដឹងរត់ទៅណាទេ ។ រត់ទៅរៀបភ្លឺអ៊ីចឹងទៅយើងចូលព្រៃ ចូលព្រៃសំងំនៅព្រៃអ៊ីចឹងទៅ ដល់យប់មើលគ្នាអត់ស្គាល់ បានចេញរត់ទៀត ។ រត់អ៊ីចឹងទៅដល់ពេលអាដែងរៀបនេះហ្នឹង គឺថាយើងចូលព្រៃហើយ ចូលព្រៃអ៊ីចឹងដល់នេះអ៊ីចឹងយើងរត់ៗៗទៅរៀបភ្លឺយើងចូលព្រៃទៀត ។

បីយប់ បានអាយប់មួយនោះ ខ្ញុំរត់ៗៗទៅជួបនារីពីរនាក់ទូលអាល្អីស្រូវនោះ យកស្រូវទៅកិនកិនស្រូវអ៊ីចឹង សួរ "មិត្តនារី ជិតដល់នៅត្នោតពង?" វាថា "អេ! ត្នោតពងមកឯណាហ្នឹង ត្នោតពងនៅឯក្រោយនេះ នេះដល់អមលាំងហើយហ្នឹង" ។ ដល់អាអមលាំងហ្នឹង ខ្ញុំនឹងឃើញអាអមលាំងហ្នឹងគេឲ្យខ្ញុំសំដៅអាអមលាំង ដល់ហើយខ្ញុំនឹកឃើញ អ៊ីចឹងខ្ញុំរត់ត្រឡប់មកវិញ ។ រត់ត្រឡប់មកវិញ ឲ្យតែរៀបភ្លឺ

ខ្ញុំចូលព្រៃហើយៗ ចូលពួនគេ ។

តែពេលនុ៎ង ជម្រាបប្រសាសន៍លោក! អត់មានស្គាល់ទឹកមួយដំណក់ទេ និយាយពីមាត់ហ្នឹងខះ ដូចអាដែងនេះអ៊ីចឹង ។ រត់ត្រឹកៗៗៗដូចអាដែងឆ្កែបោលអ៊ីចឹង រត់រហូតអ៊ីចឹងមកដល់គេហៅថាភូមិធំ ជិតត្នោតពងហ្នឹង សួរគេទៅ ខ្ញុំសួរគេថា “មិត្តជិតដល់នៅត្នោតពង?” គេថា “អឺ! ត្នោតពងមើលទៅ ឃើញលឹមៗនោះ” អ៊ីចឹងខ្ញុំសំដៅទៅត្នោតពងនុ៎ង ព្រោះត្នោតពងពេលដែលខ្ញុំទៅៗតាមភូមិត្នោតពងហ្នឹង បើខ្ញុំរកភូមិត្នោតពងហ្នឹងឃើញ បានខ្ញុំរកផ្លូវឃើញត្រឡប់មកភ្នំពេញវិញ ។ ដល់ខ្ញុំដើរសំដៅមកត្នោតពង ហ្នឹងឃើញអាផ្លូវអាដែងកាលខ្ញុំទៅហ្នឹង ។

ដល់អ៊ីចឹងអាប្រជាជននៅតាមជើងភ្នំហ្នឹងវាកៀរទៅអស់រលីង អត់មានសល់ម្នាក់ណាទេ ។ ខ្ញុំ ចូលទៅខ្ទមមួយហ្នឹង ឃើញអាកាំបិតផ្គាក់មួយប្រវែងណេះ ខ្ញុំលីអាកាំបិតផ្គាល់ហ្នឹងលីៗៗដើរចូលទៅ អាខ្ទមមួយនោះ ឃើញគេដាំអំពៅដាំអីកាប់ដើមអំពៅគេហ្នឹងបានពីរដើម ។ កាប់អំពៅបានពីរដើមហ្នឹង ហូបអំពៅហ្នឹង ហូបនិយាយពីអត់ចង់ខ្ជាក់កាកចោលទេ ចង់ចង់លេបទាំងកាក ប៉ុន្តែខ្លាចស្លាក់ ចង់លេប ទាំងអស់តែម្តង ។ ហើយដើរផងអីផងលីអាកាំបិតហ្នឹងរហូតមកដល់អាគេហៅភូមិក្តាន់រយ ។ ដល់ភូមិ អាក្តាន់រយហ្នឹងជួបពួកវាដប់ប្រាំនាក់ទៀតកំពុងតែកៀរប្រជាជន ឲ្យប្រជាជនទឹមរទេះឲ្យទៅអមលាំង ។ ដល់មកដល់ហ្នឹងខ្ញុំថា ខ្ញុំអត់រត់ទេ ខ្ញុំអត់គេចទេ ដើរសំដៅវាតែម្តង ម៉េចកាប់គ្នាតែម្តង ។ ដល់ដើរ សំដៅវាសួរ “មិត្តឯងទៅណា?” ខ្ញុំថា “អើ ខ្ញុំទៅយកកូននៅសហករណ៍ស្នោ” “មកវិញទេ?” ខ្ញុំថា “មក វិញ ខ្ញុំត្រឡប់មកវិញ” ទៅដល់ស្នោអ៊ីចឹងខ្ញុំកុហកគេរហូតដល់ ទៅដល់ស្នោ ពួកស្នោគេសួរ “មិត្តឯង ទៅណានេះ?” “ខ្ញុំទៅយកកូននៅគ្រេល” បើតាមការពិត ខ្ញុំអត់មានកូននៅហ្នឹងទេៗ ចេះតែកុហក គេរហូត ។

ហើយរហូតមកដល់អាគ្រេលហ្នឹង គឺថាបានជួនគ្រួសាររស់ថ្ងៃនេះ វានៅដេរជាមួយគ្រួសារខ្ញុំ ដែរ ។ គ្រួសារខ្ញុំរស់ថ្ងៃហ្នឹង នៅដេរជាមួយគ្រួសារខ្ញុំដែលស្លាប់ទៅហ្នឹង នៅដេរជាមួយគ្នាហ្នឹង ក្រោយ មកបាននៅប្រមូលស្រូវប្រមូលអីដាក់ជង្រុកដាក់អ៊ីចឹងទៅ ដល់ហើយអ៊ីចឹងទៅឃើញវៀតណាម ខ្ញុំចូល អាស្បោងស្រូវគេនោះ ចូលស្បោងស្រូវសំងំនៅហ្នឹងស្បោងស្រូវ ដល់វៀតណាមចេញផុតទៅបានចេញ ទៅទៀត ។ ចេញធ្វើការនឹងគេនឹងឯងទៅ ។ ពេលនុ៎ងគឺថាខ្លាចវៀតណាមណាស់ ខ្ញុំខ្លាចណាស់ ។

ដល់មកនៅបែកចានហ្នឹង មកនៅបែកចានហ្នឹងយូរៗទៅដល់គេហៅប្រជុំៗ ខ្ញុំក៏ទៅប្រជុំជាមួយ គេដែរ ដល់ក្រោយមកខ្ញុំសុំថា “ឲ្យខ្ញុំចូលធ្វើទាហានផង” គេថា “អត់ឲ្យធ្វើទេបាទ” ។ ហើយដល់ពេល

នុំង ក៏ខ្ញុំបើសិនណាខ្ញុំបានបានធ្វើទាហាន ខ្ញុំទៅអារវត្តស្រះធុលហ្នឹងហើយ ប៉ុន្តែគេអត់ឲ្យធ្វើ ។

**ស៖** ពេលខ្មែរក្រហមបានជ្រើសរើសយកអ៊ំ មកធ្វើការនៅក្រុងភ្នំពេញ តើប្រពន្ធរបស់អ៊ំហ្នឹង ដែលថាអង្គការគេមើលថែឲ្យហ្នឹង គេបានបញ្ជូនឲ្យមកជួបជុំជាមួយអ៊ំនៅភ្នំពេញដែរឬទេ?

**ឆ៖** គេឲ្យមក មកអ៊ីចឹងគេឲ្យមកនៅម្តុំច្រាំងចំរេះ នៅបង្ករបង្កើតផលនៅច្រាំងចំរេះហ្នឹង ក្រោយមកទៅដល់វេលាខ្ញុំគេឲ្យមកអូរឫស្សី ។ ឲ្យមកអូរឫស្សីហ្នឹង ខ្ញុំក៏បានសំណូមពរសុំគេថា "ឲ្យសុំគ្រួសារខ្ញុំមកអូរឫស្សីហ្នឹង គ្រាន់ជួយដែរ ជួយគេអីហ្នឹងជិតគ្នា" ហើយគេក៏យកគ្រួសារខ្ញុំមកអូរឫស្សីហ្នឹង ។

[០៩:៥៤:៣៥]

**ស៖** អ៊ំដឹងទេ ថាអ្នកបុគ្គលណាមួយដែលសម្រេចចាប់ខ្លួនអ៊ំ? អ្នកចេញសេចក្តីសម្រេចចាប់ខ្លួនអ៊ំដឹងទេ អ្នកណាគេ?

**ឆ៖** តាមខ្ញុំយល់ ខ្ញុំមុននឹងចាប់ខ្ញុំនឹងមានលោក គុណ ហ្នឹង ។ គុណ ហ្នឹងជាប្រធានទទួលខុសត្រូវកន្លែងកាត់ដេរហ្នឹង ។ ពេលនុំងគេចាប់លោក គុណ បាត់ហើយ ចាប់លោក គុណ បាត់ទៅ បានឡើងអនុហ្នឹងឡើង តាឈុំ ឈ្មោះ ឈុំ ហ្នឹងឡើងប្រធាន ក្រោយមកចាប់ចាប់ឈុំហ្នឹងទៀតៗបានលេចមិត្តលីន អ៊ំ មិត្តយ៉ុង នោះ ។ មិត្តយ៉ុង ធ្វើប្រធានទៀត ។ ពេលនុំងមិត្តយ៉ុង និយាយប្រាប់ខ្ញុំថា "គាត់នៅរតនគីរីហ្នឹង គាត់មើលអាកូនដំរីឲ្យ ប៉ុល ពតៗ ហើយជំនាន់នោះ គាត់ដុតស្ពានទៅបរកែវៗ ហើយអាស្ពានទៅបរកែវហ្នឹង អាហ្នឹងខ្ញុំជួសជុល ខ្ញុំធ្វើ ម្លោះហើយវាដុតអាស្ពានហ្នឹង ។ ម្លោះហើយបានខ្ញុំពេលនោះខ្ញុំអត់ប៊ាននិយាយទេ ព្រោះវាមានការទាក់ទងគ្នាជាមួយមិត្តយ៉ុង ជាមួយ ប៉ុល ពត ហ្នឹងខ្ញុំអត់ប៊ាននិយាយ ខ្ញុំបំបាត់ត្រឹមហ្នឹងទៅ ។ ក្រោយមកគេចាប់ មិត្តយ៉ុង បាត់ទៅ ឃើញមិត្តនារីម្នាក់មកពីអាយើងនិរតីនោះ ខាងតាកែវឈ្មោះ មិត្តវ៉ាន់ៗ ស្រី រាងទាបខ្មៅមិត្តហ្នឹង ។ មិត្តវ៉ាន់ ហ្នឹង ពេលដែលមកកន្លែង គ-៩ ហ្នឹង ហើយពេលហ្នឹងមានមិត្តលីន ។ មិត្តលីន ហ្នឹងមករួមសហការជាមួយ មិត្តវ៉ាន់ហ្នឹង ។ ពេលនុំង មិត្តវ៉ាន់ ហើយនិង មិត្តលីន ហ្នឹងដែលចាប់ខ្ញុំមកយើងទួលស្លែងហ្នឹង ។

**ស៖** ពេលគេចាប់ខ្លួនអ៊ំហ្នឹង គេប្រាប់ថាអ៊ំមានកំហុសអ្វីទេនៅក្នុងរបបកម្ពុជាធិបតេយ្យនោះ?

**ឆ៖** អត់មានប្រាប់អត់មានអីទេ ។

**ស៖** ពេលមកដល់ភ្លាម អ៊ំគិតមើលថាតើគេជូនអ៊ំមកដល់ចូលនៅក្នុងមន្ទីរសន្តិសុខស-២១ តែម្តង ឬក៏បញ្ជូនមកទីស្នាក់ការ ទីកន្លែងមួយផ្សេងទៀតដែលត្រូវមានការប្រគល់ទទួលរវាងអ្នកបញ្ជូន

ហើយនិងអ្នកទទួលអ៊ំទេ មុននឹងបញ្ជូនចូលទៅក្នុងមន្ទីរសន្តិសុខព្រៃស ឬក៏បច្ចុប្បន្នគុកទួលស្លែងនោះ?

**ឆ៖** ថាអត់ចូលមកដល់កន្លែងហ្នឹង គឺថាអត់មានអ្នកទទួលទេទាន គឺថាគេចេញប្រិបពីក្នុងផ្ទះហ្នឹងមកគេដាក់ខ្នោះខ្ញុំតែម្តង រៃខ្នោះដៃខ្ញុំហ្នឹង គឺថាគេបញ្ជូនចូលមកទួលស្លែងហ្នឹងតែម្តង មកដល់ពាក់កណ្តាលផ្លូវខ្ញុំសុំឲ្យជួយមើលគ្រួសារខ្ញុំ គេធាក់ខ្ញុំដួលផ្កាប់មុខនៅកន្លែងហ្នឹងតែម្តង ។

[០៩:៥៧:៤៨]

**ស៖** អ៊ំបាននិយាយអំមិញថា កាលចាប់ខ្លួនមកជាមួយគ្នាហ្នឹងបីនាក់ ហើយពេលចូលដល់ភ្លាមគឺមានបែបបទមួយដោះមុខចេញ ហើយសួរអំពីសាវតារ អំពីជីវប្រវត្តិ កត់ត្រាជីវប្រវត្តិ រួចហើយគេថតរូបអ៊ីចឹង? ថតរូបរួចហើយ បានទើបដោះសម្លៀកបំពាក់ចេញ ហើយរុំមុខចងសេកបញ្ជូនឡើងទៅដាក់នៅក្នុងអគារឃុំខ្លួន ។ ចុះអ្នកផ្សេង អ្នកបីនាក់ផ្សេងទៀតហ្នឹងធ្វើ គេប្រព្រឹត្តិចំពោះគាត់ដូចអ៊ំដែរទេ?

**ឆ៖** ខ្ញុំដោយខ្លួន គេដោយខ្លួន ។

**ស៖** យើងចង់ដឹងពេលបញ្ជូនចូល បញ្ជូនចូលមកវាមានបីនាក់មែនទេ? អ៊ីចឹងពេលដែលថតរូបពេលដែរគេសួរជីវប្រវត្តិ ដោះសម្លៀកបំពាក់ ហើយនិងរៃខ្នោះ អាហ្នឹងគឺអ៊ំ ដឹងថាគេប្រព្រឹត្តដូចអ៊ំដែរទេ? ចំពោះអ្នកពីរនាក់ផ្សេងទៀត ដែលគេចាប់ខ្លួនមកជាមួយអ៊ំនោះ?

**ឆ៖** បាទ ។

[០៩:៥៩:០៣]

**ស៖** អ៊ំ ត្រូវគេ-- អ៊ំប្រយ័ត្នបន្តិច អ៊ំ ព្រោះកាលណាអ៊ំអត់និយាយដោយមិនបើកក្បាលមីក្រូហ្វូនសំឡេងអ៊ំអត់បានឮទៅដល់អ្នកបកប្រែទេ ។ អ៊ីចឹងអ្នកបកប្រែអត់អាចបកប្រែបានទេ យើងឮតែនៅទីនេះ អ្នកផ្សេងទៀតគេអត់ស្តាប់បានទេ ជាពិសេសជនជាតិបរទេស គាត់អត់ស្តាប់បានទេ ព្រោះអ្នកបកប្រែស្តាប់មិនបាន ។ អ៊ីចឹងអ៊ំត្រូវចងចាំ នៅពេលដែលអ៊ំឆ្លើយ មុននឹងឆ្លើយ អ៊ំចុចបើកមីក្រូហ្វូនសិន ។

អ៊ីចឹងអ៊ំ ពេលដែលគេបញ្ជូនអ៊ំហ្នឹងមានន័យថា អ៊ំត្រូវគេយកទៅដាក់ឃុំឃាំងនៅក្នុងបន្ទប់តូចដែលមានតែម្នាក់ឯងទេ ពិតមែនទេ?

**ឆ៖** បាទ,ជម្រាបប្រសាសន៍លោក! ពិតមែនហើយ ។

**ស៖** អ៊ំបាននិយាយច្រើនអំពីការដែល ការប្រព្រឹត្តិរបស់មន្ត្រី របស់បុគ្គលិកនៃមន្ទីរស-២១ ចំពោះអ៊ំ បានន័យថា ចាប់តាំងពីពេលដែលអ៊ំចូលទៅដល់មន្ទីរឃុំឃាំងនៃមន្ទីរសន្តិសុខស-២១ ការសួរចម្លើយដែលមានការធ្វើទារុណកម្ម ដោយគេហៅប្រភេទអ្នកក្តៅនោះជារឿងរាល់ថ្ងៃជាប់គ្នា ដប់ពីរថ្ងៃ ដប់ពីរយប់ អ៊ីចឹងមែនទេ?

**ផ៖** បាទ,ជម្រាបប្រសាសន៍លោក! ពិតមែនហើយ ។

**ស៖** អ៊ំបាននិយាយថា គេវាយអ៊ំនឹងរំពាត់នៅក្នុងអំឡុងពេលដែលគេសួរចម្លើយ ហើយអ៊ំនិយាយទៅកាន់ពួកគេដោយប្រើពាក្យដែលមិនធំ ដែលបំណងរបស់គេ គេឲ្យ-- តម្រូវឲ្យហៅបងនោះ ហើយយើងមិនប្រើពាក្យធំ គេវាយអ៊ំសរុបទៅមួយរយរំពាត់ ។ រំពាត់អីគេទៅរំពាត់ហ្នឹង ពាក្យថារំពាត់ហ្នឹង? វារាងយ៉ាងម៉េចទៅ? ហើយធ្វើអំពីអី? ហើយមានទ្រង់ទ្រាយយ៉ាងម៉េចទៅរំពាត់នោះ?

**ផ៖** បាទ,ជម្រាបប្រសាសន៍លោក! រំពាត់នុ៎ង គឺថា មានរំពាត់ឫស្សី មានអាយើងបន្ទះរនាប មានមែកឈើអីធំៗប៉ុនមេដៃ ហើយពេលនុ៎ង គឺថាខ្ញុំមើលទៅម្ខាងហ្នឹង គឺថាមួយបាច់ៗប៉ុណ្ណឹងតែម្តង រំពាត់សម្រាប់វ៉ៃខ្ញុំបាទហ្នឹង ។

**ស៖** ក្នុងខណៈគេដែលវាយអ៊ំនៅក្នុងអំឡុងពេលសួរចម្លើយហ្នឹង អ៊ំអង្គុយ ឬក៏គេឲ្យអ៊ំដេកផ្កាប់មុខទៅលើឥដ្ឋការ៉ូ?

**ផ៖** បាទ,ជម្រាបប្រសាសន៍លោក! គេឲ្យអង្គុយ ហើយគេដាក់ខ្នោះជើងឲ្យអង្គុយសណ្តូកជើងដាក់ខ្នោះជើង ។

**ស៖** គេឲ្យអង្គុយផ្ទាល់ឥដ្ឋ ឬក៏គេឲ្យអង្គុយលើកៅអី ឬក៏លើជើងម៉ាក្នុងអំឡុងពេលដែលគេចាត់តាំងសំណួរសួរដល់អ៊ំនោះ?

**ផ៖** គេឲ្យអង្គុយផ្ទាល់ឥដ្ឋហ្នឹង គឺថាសណ្តូកជើងផ្ទាល់ឥដ្ឋហ្នឹងតែម្តងទាន ។

[១០:០៣:៣៤]

**ស៖** ចុះក្រៅពីវាយនឹងរំពាត់ ដែលអ៊ំប្រើពាក្យរំពាត់ ព្រោះកាលពីឯកសារកំណត់ហេតុមុនប្រើដំបង នៅក្នុងពាក្យនិយមន័យនៃពាក្យដំបង វាមានលក្ខណៈខុសពីរំពាត់ ។ បើអ៊ំនិយាយអំមិញគឺរំពាត់បានន័យថា វាជារឿងទំហំនៃឈើ ឬក៏ប្រភេទរបស់ដែលប្រើប្រាស់ហ្នឹងវាតូចជាងដំបង ។ ហ្នឹងហើយ ដែលវាអាចកត់សម្គាល់ការបែងចែកសញ្ញាណនៃពាក្យថា “រំពាត់” និងពាក្យថា “ដំបង” ។ ប៉ុន្តែសំណួរសួរផ្សេងទៀតនោះ សួរថា ចុះទារុណកម្មក្រោយៗមកទៀតហ្នឹង គេប្រើអ្វីដើម្បីធ្វើទារុណកម្មអ៊ំ?

**ឆ៖** ជម្រាបប្រសាសន៍លោក! គេវ៉ៃខ្ញុំហ្នឹងមិនមែនវ៉ៃជាដំបងទេ វ៉ៃមួយមែកឫស្សីប៉ុនមេដៃ ប៉ុនមេជើងហ្នឹងទាន ។ កាលណាអស់ទៅ បាក់អស់ទៅ ឃើញគេយកមកទៀត ។

**ស៖** ប៉ុន្តែសួរក្រោយទៀតនេះថា ការវ៉ៃរបៀបនេះមានប៉ុន្មានដងទៅចំពោះអ៊ំដែលគេប្រើរំពាត់ក្នុងសួរៗ ទារុណកម្មក្នុងពេលសួរចម្លើយនេះ? ដោយឡែក គឺមានបញ្ហាផ្សេងទៀត គឺមានការដកក្រចកជើង ហើយនិងដក-- វាយឲ្យឆក់ខ្សែភ្លើង ខ្ញុំមិនទាន់សួរទេ ពីព្រោះដប់ពីរថ្ងៃ ។ អ៊ីចឹងកម្រិតនៃទារុណកម្មដែលប្រភេទប្រើប្រភេទរំពាត់ដូចដែលអ៊ំបានលើកឡើងអ៊ីចឹង ធ្វើបែបនេះប៉ុន្មានលើកប៉ុន្មានសា?

**ឆ៖** ជម្រាបប្រសាសន៍លោក! ប្រើរំពាត់នេះជារៀងរាល់ថ្ងៃតែម្តង គឺថាទៅឃើញគេមានរំពាត់ដាក់នៅកន្លែងហ្នឹងស្រាប់តែម្តង មួយបាច់ៗនៅកៀនតុគេហ្នឹង កូនតុគេហ្នឹងមានតុមួយនៅហ្នឹង ហើយគេមានដាក់អង្គុលីលេខនៅហ្នឹង ដាក់នៅកៀនតុហ្នឹង ។ តែគេសួរចម្លើយយើងមួយសន្ទុះហើយអ៊ីចឹង គេមកវ៉ៃអង្គុលីលេខហ្នឹង ។ បើយើងមិនឆ្លើយ អាហ្នឹងគេវ៉ៃទៀត បើយើងឆ្លើយទៅ គេមកវ៉ៃអង្គុលីលេខហ្នឹងតែម្តង ហើយរំពាត់ហ្នឹង គឺថាមានជារៀងរាល់ថ្ងៃ គឺថានៅកៀកអាតុដាក់អង្គុលីលេខហ្នឹង ។

**ស៖** ការដែលគេសួរចម្លើយហ្នឹង គេសួរឈ្លេចអ៊ំហ្នឹងអំពីបញ្ហាអ្វីដែលជាក់លាក់ទៅ ច្បាស់លាស់ដែលបំណងនៃការសួរហ្នឹងគេចង់បានអ្វី ដែលជាក់លាក់ ដែលច្បាស់លាស់នៅក្នុងអំឡុងពេលសួរចម្លើយនោះ?

**ឆ៖** ពេលនោះគឺថា គេសួរតែរឿង *សេអ៊ីអា, កាហ្សេបេ* ហ្នឹង គេអត់មានសួរអីទេ ហើយបើយើងឆ្លើយក្រៅពី *សេអ៊ីអា* ហ្នឹង គេវ៉ៃយើង គេឲ្យឆ្លើយតែរឿង *សេអ៊ីអា, កាហ្សេបេ* ហើយបើយើងនិយាយពាក់ព័ន្ធអារឿងកម្ពុជាក្រោមអី គឺក៏អត់បានទេ អាហ្នឹងគេវ៉ៃយើងហើយ ។

**ស៖** ចុះពេលដែល-- លើកទីប៉ុន្មានដែលគេសួរចម្លើយអ៊ំ ហើយបានដកក្រចកជើងអ៊ំនោះ? ថ្ងៃទីប៉ុន្មានដែរ?

**ឆ៖** ខ្ញុំមិនបានចាំថ្ងៃទេទាន ប៉ុន្តែបើនិយាយពីរឿងដកក្រចកប្រហែលជាមួយអាទិត្យហើយបានដកក្រចក ។

[១០:០៦:៥៥]

**ស៖** អ៊ីចឹងបានថា ពេលដែលអ៊ំចូលទៅហ្នឹង គេវាយធ្វើទារុណកម្មអ៊ំដើម្បីសួរចម្លើយហ្នឹងប្រហែលជាអំឡុងពេលមួយអាទិត្យ បានន័យថា នៅថ្ងៃទីប្រាំពីរ នៃថ្ងៃដែលអ៊ំចូលទៅដល់ទីនោះ ទើប

ទារុណកម្មហ្នឹងមានការវាយដកក្រចក ។ អ៊ំនិយាយឲ្យច្បាស់លាស់មើល អ៊ំមិញបានស្តាប់ម្តងហើយ ប៉ុន្តែការនិយាយឲ្យលម្អិតអំពីរបៀបនៃការដកក្រចកអ៊ំ វាយស្នូរចម្លើយ ហើយធ្វើទារុណកម្មដកក្រចកនេះ វាធ្វើយ៉ាងម៉េចឲ្យបានច្បាស់លាស់លើចំណុចនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោក! គឺថាអាការវ៉ៃហ្នឹង គឺរំពាត់ហ្នឹងមានប្រចាំថ្ងៃ គឺថាវាដាក់កៀនមួយកៀនហ្នឹងមួយបាច់ៗប្រចាំថ្ងៃតែម្តង ។ ដល់វ៉ៃអស់ចិត្តអស់ចង់-- វ៉ៃអ៊ីចឹងហើយ ខ្ញុំយកដែរងវាបាក់កូនដៃ បាក់កូនដៃ ហើយថ្ងៃក្រោយចេះតែវ៉ៃៗទៀត ដល់ខ្ញុំថា វាអត់-- ខ្ញុំអស់ស្គាល់រឿង *សេអ៊ីអា, កាហ្សេបេ* ខ្ញុំអត់ដែលស្គាល់ទេ អត់ដែលចូលទេ ។ ក្រោយមកវាយកដង្កាប់ហ្នឹងមួលក្រចកជើងអ៊ំហ្នឹង មួលហើយដល់វាអត់ដាច់ វាកន្ត្រាក់អ៊ីចេះ វាកន្ត្រាក់អ៊ីចឹងទៅ បានជើងខ្ញុំវាញ័រទទ្រើតនៅហ្នឹងតែម្តង ។

**ស៖** អ៊ីចឹងបានន័យថា វាអត់មានចាំបាច់ប្រើឧបករណ៍អីទេ ព្រោះជើងអ៊ំហ្នឹងជាប់ខ្នោះរួចហើយ ហើយវាយកដង្កាប់ហ្នឹង គឺច្របាច់ក្រចកមេជើងអ៊ំអ៊ីចឹងឲ្យបែកទៅបានទាញ ។ របូតទេ របូតទេក្រចកហ្នឹង ឬក៏គ្រាន់តែបែកទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! របូតដាច់ក្រចកហ្នឹងមកតែម្តង ដាច់ក្រចកហ្នឹងមក វាចាប់មួលដង្កាប់អ៊ីចឹងហើយ វាអត់ដាច់ ដល់អត់ដាច់ក្រចកហ្នឹង វាកន្ត្រាក់ទាញអ៊ីចេះមកតែម្តង បានដាច់មក ។

**ស៖** កន្ត្រាក់ទាញដាច់ហ្នឹង របូតហ្នឹងវារបូតទាំងគល់ក្រចកមកទាំងស្រុងតែម្តង ឬក៏វាដាច់តែផ្នែកណាមួយនៃក្រចកទេ ឬក៏វាទាញមករបូតទាំងឫសគល់ក្រចកហ្នឹងមកទាំងស្រុងអ៊ីចឹងតែម្តង?

**ឆ៖** ជម្រាបប្រសាសន៍លោក! មកក្រចកទាំងដុំហ្នឹងមកតែម្តង ។

**ស៖** ឥឡូវវាដុះវិញទេអ៊ំ ក្រចកហ្នឹងដុះវិញទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ដុះក៏អត់ដូចដើមដែរ ។ ដុះអត់ដូចដើម វាឡើងវៀចក្ងង់ទៅឯណោះនោះ ។

**ស៖** អ៊ំអាចអញ្ជើញចេញក្រោមកមើល បង្ហាញបន្តិចមើល! ចេញៗមកមុខអ៊ំចេញមកមុខ ។ ត្រង់ហ្នឹងហើយអ៊ំ ត្រង់ហ្នឹងហើយ ត្រង់ហ្នឹងចុះ ។ អ៊ំខិតទៅក្រោយបន្តិច ។

[១០:០៩:៥៥]

ទាំងពីរ? ទាំងសងខាង? តែមេជើងទេ?

កាមេរ៉ា ។ កាមេរ៉ាអាចបញ្ចាំងក្រចកជើងគាត់?

បានហើយ អ៊ំអញ្ជើញទៅក្រោយវិញចុះអ៊ំ ។

អ៊ីចឹងការដែលគេធ្វើទារុណកម្មដោយប្រើដង្កាប់ដើម្បីច្របាច់ ហើយដកក្រចកអ៊ំហ្នឹង គឺគេដកជើង-- ក្រចកមេជើងទាំងសងខាង តែមេជើងទេ ទាំងសងខាង គឺមេជើងទាំងពីរ អ៊ីចឹងមែនទេអ៊ំ?

**ធ៖** ពិតមែន ។

**ស៖** ការដែលគេដកក្រចកអ៊ំហ្នឹងក្នុងពេលតែមួយ ឬក៏ក្នុងសួរចម្លើយមួយលើកដកមួយចំហៀង ហើយសួរក្រោយមកទៀត ទើបដកមួយចំហៀងទៀត?

**ធ៖** ជម្រាបប្រសាសន៍លោក! មួយថ្ងៃដកមួយចំហៀងៗ ។

**ស៖** ចុះពេលដែលគេសួរចម្លើយដោយធ្វើទារុណកម្មឆក់ខ្សែភ្លើងហ្នឹង គេប្រើវិធីហ្នឹងប៉ុន្មានដងដែរចំពោះអ៊ំ?

**ធ៖** ជម្រាបប្រសាសន៍លោក! គឺគេឲ្យឆក់ហ្នឹង គឺថាឆក់ពីរដង សន្លប់ពីរដង ។

**ស៖** អ៊ំបានបញ្ជាក់ថា ការឆក់ខ្សែភ្លើងហ្នឹងគឺមិនដូចជនជាប់ចោទឆ្លើយទេ បានន័យថា ការឆក់ខ្សែភ្លើងហ្នឹងមិនប្រើ*ឌីណាម៉ូ* -- រវៃដោយ*ឌីណាម៉ូ* អ៊ីចឹងទេ គឺការឆក់ខ្សែភ្លើង គឺខ្សែភ្លើង២២០វ៉ុល ដែលប្រើប្រាស់នៅក្នុងប្រព័ន្ធចរន្តអគ្គីសនីដែលប្រើប្រាស់បម្រើបំភ្លឺនៅអគារហ្នឹង ហើយគេតខ្សែភ្លើងយកមកឆក់ ដោយចាប់ត្រចៀកអ៊ំអ៊ីចឹងទេ?

**ធ៖** ជម្រាបប្រសាសន៍! វាញ៉ុកក្នុងត្រចៀកអ៊ីចឹងតែម្ដង ញ៉ុកក្នុងត្រចៀកប្លួច ដល់យើងដួលសន្លប់ទៅ គឺថាវាដកចេញ ។

**ស៖** ជនជាប់ចោទបានឆ្លើយថា វិធីដែលកំណត់ ឬក៏អាចអនុញ្ញាតឲ្យប្រើប្រាស់ទារុណកម្មហ្នឹង គឺវិធីប្រើឆក់ខ្សែភ្លើងដោយរូបភាពនៃរវៃអ៊ីចឹង ប៉ុន្តែការអនុវត្តជាក់ស្ដែង គឺអ្នកដែលធ្វើទារុណកម្មសួរចម្លើយហ្នឹងបានប្រើប្រព័ន្ធនៃចរន្តអគ្គីសនីដែលមាននៅទីនោះ ប៉ុន្តែគាត់ទទួលស្គាល់ដោយសារគាត់អត់បានរារាំងនៅហ្នឹងទេ គំនិតដើម គឺត្រឹមតែរវៃទេ-- រវៃ*ឌីណាម៉ូ* ទេ ប៉ុន្តែក្រោយមកការប្រើប្រាស់កម្រិតខ្ពស់ជាងធម្មតា ប៉ុន្តែ អត្ថិភាពបញ្ហានេះគឺគាត់នៅស្ងៀមមិនធ្វើការកែប្រែ ឬក៏ដាក់ពិន័យដល់អ្នកដែលប្រព្រឹត្តអ៊ីចឹងទេ ។ អ៊ីចឹងវាអាចខុសគ្នាបន្តិចក្នុងការបញ្ជាក់ បើធៀបជាមួយនឹងចម្លើយរបស់គាត់ ។

សំណួរមួយទៀតសួរថា អំឡុងពេលដែលគេធ្វើទារុណកម្ម ដូចធ្ងន់ធ្ងរ អ៊ំដូចជារវៃច្រើនរំពាត់ ហើយដកក្រចកអ៊ីចឹង ឬក៏ឆក់ខ្សែភ្លើងរហូតដល់សន្លប់អ៊ីចឹង សួរថា នៅក្នុងអំឡុងពេលក្រោយមកទៀតភ្លាមៗហ្នឹង មានការព្យាបាលទេ? មានគ្រូពេទ្យ គេចាត់ឲ្យគ្រូពេទ្យទៅព្យាបាលរបួសអ៊ំដែរឬទេ?

[១០:១៣:៥២]

**ឆ៖** ជម្រាបប្រសាសន៍លោក! អត់មានពេទ្យណាមកមើលមកអីទេ គឺថាជើងហ្នឹងដើរអត់ចង់រួច ។

**ស៖** អ៊ំបាននិយាយថា នៅថ្ងៃទី០៧ ខែមករា ឆ្នាំ១៩៧៩ វេលាម៉ោងដប់មួយ ស្ថានភាពហ្នឹងមានការប្រែប្រួល ហើយក៏អ៊ំបានប្រមូលផ្ដុំជាមួយនឹងអ្នករស់រានមានជីវិតផ្សេងទៀតហ្នឹង ចាកចេញពីទីនោះ ដោយមានការគំរាមកំហែង ឬក៏ឲ្យតម្រង់ជួរដោយមានការភ្ជង់ដោយកាំភ្លើងពីមន្ត្រី ពីកងទ័ពកងកម្លាំងនៃមន្ទីរសន្តិសុខស-២១ ផង ។

សំណួរសួរថា ទីមួយមានចំនួនអ្នកដែលរស់រានមានជីវិត អ្នកទោស យើងនិយាយពាក្យសាមញ្ញថា អ្នកទោសដែលចាប់ទៅមន្ទីរស-២១ រស់រានមានជីវិត ហើយត្រូវគេភ្ជង់ឲ្យដើរចេញពីទីហ្នឹងទៅ--ធ្វើដំណើរចេញទៅតាមទួលទំពូងទៅព្រៃស រហូតដល់ដែលអ៊ំបានរៀបរាប់ពីប្រវត្តិរបស់អ៊ំអំមិញ មានចំនួនប៉ុន្មាននាក់ដែរ? ហើយគេដាក់ខ្នោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! បើតាមខ្ញុំមិនបានរាប់ឲ្យច្បាស់លាស់ទេប្រហែលដប់នាក់ជាងៗប៉ុណ្ណឹង ។ ហើយការដែលដាក់ខ្នោះ ដាក់អីហ្នឹង គឺគេអត់មានដាក់ខ្នោះ ដាក់អីទេ គឺឲ្យយើងដើរសេរីតែម្ដង តែគ្រាន់តែភ្ជង់យើងតាមក្រោយ ។

**ស៖** មានចំនួនប៉ុន្មាននាក់ដែរអ៊ំ?

**ឆ៖** បាទចំនួនប្រហែលដប់ប្រាំនាក់ទាន ។

**ស៖** ពេលអ៊ំធ្វើដំណើរចេញទៅហ្នឹង អ៊ំដែលបានជួបជនជាប់ចោទទេ? ចាប់ពីពេលអ៊ំចេញទៅរហូតដល់អ៊ំមាននៅក្នុងព្រៃអី វង្វេងចុះឡើងប៉ុន្មានយប់ ប៉ុន្មានថ្ងៃហ្នឹង អាហ្នឹងយើងមិននិយាយទេ ព្រោះអត់បានជួបមនុស្សទេ ប៉ុន្តែ អំឡុងពេលដែលធ្វើដំណើរទៅហ្នឹង មានបានជួបជាមួយជនជាប់ចោទទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំអត់បានជួបទេ បើទុកជាជួប ខ្ញុំអត់ស្គាល់គេផងហ្នឹង ។

**ស៖** អ៊ំចាំទេថា ថ្ងៃដែលឈ្មោះ ធី បានទៅរកអ៊ំ សួររកជាងជួសជុលម៉ាស៊ីនដេរហ្នឹង នៅថ្ងៃខែឆ្នាំណា?

**ឆ៖** ជម្រាបប្រសាសន៍លោក! ពេលដែល ធី ទៅសួរហ្នឹង គេឈប់សួរចម្លើយហើយអាហ្នឹងគឺថាគេឈប់សួរចម្លើយអីចឹង គេទៅរកខ្ញុំនៅកន្លែងឃុំឃាំងហ្នឹង ។

**ស៖** អ៊ីចឹងបានន័យថា គេសួរចម្លើយអ៊ំដប់ពីរថ្ងៃដប់ពីរយប់ បន្ទាប់មកគឺឈប់សួរ ហើយមូលហេតុនៃការឈប់សួរហ្នឹង យ៉ាងម៉េចបានគេឈប់សួរអ៊ំទៀត?

**ឆ៖** មូលហេតុដែលឈប់សួរខ្ញុំហ្នឹង ដោយសារខ្ញុំទទួលសារភាពថា ខ្ញុំចូល *សេអ៊ីអា* ចូល *កាហ្សេបេ* មែនខ្ញុំសារភាព ។

**ស៖** ហើយយ៉ាងម៉េចបានគេជឿ បើចម្លើយសារភាពនាំឲ្យគេជឿ ហើយចូល *កាហ្សេបេ* អ៊ីចឹង តើអ៊ំ មានដែលឆ្លើយដាក់អ្នកដទៃផ្សេងទៀតទេ? ពីព្រោះនៅក្នុងទម្រង់នៃរបៀបសួរចម្លើយ គឺចម្លើយអំពីជីវប្រវត្តិ អំពីសកម្មភាពរបស់បុគ្គលខ្លួនឯង ហើយនិងសកម្មភាពបក្សពួកខ្សែ ។ ខ្សែក្បត់ដែលត្រូវមានកំណត់ហេតុនៃការសួរចម្លើយមនុស្សម្នាក់ៗ តើប្រព័ន្ធនៃការកំណត់ហេតុសួរចម្លើយអ៊ំហ្នឹង មានគោលដៅរហូតដល់សកម្មភាពរបស់អ៊ំផ្ទាល់ ហើយនិងសកម្មភាពរបស់បក្សពួកអីអ៊ីចឹងដែរទេ?

[១០:១៨:២៧]

**ឆ៖** ជម្រាបប្រសាសន៍លោក! គឺថា ខ្ញុំឆ្លើយថា ចូល *សេអ៊ីអា*, *កាហ្សេបេ* មែន តែអារឿងដែលខ្ញុំឆ្លើយនេះ មិនមែនជាការពិត ដោយសារគេវ៉ៃខ្ញុំខ្លាំងពេក ម្ល៉ោះហើយខ្ញុំចេះឆ្លើយគេពេញទឹកពេញដីទៅ ។

**ស៖** យើងយល់ហើយបញ្ហាពិត មិនពិត យើងយល់ ក៏ប៉ុន្តែយើងចង់និយាយអំពីរបៀបទម្រង់នៃដែលបានចម្លើយ រហូតបានហើយគេលែងធ្វើទារុណកម្មអ៊ំទៀត ។ បានន័យថា លទ្ធផលគេចាត់ទុកជាបានការហើយនោះ ។ អ៊ីចឹង មានការសួរចម្លើយពីអ៊ំ អ៊ំបានឆ្លើយសារភាពដែលមិនមែនជារឿងកុហកនោះ គឺជារឿងកុហកមិនមែនជារឿងពិតទេ គឺចម្លើយថា ទទួលថាជាខ្សែរយៈ *សេអ៊ីអា* អីអ៊ីចឹងទៅ ហើយមានទាំងបណ្ដាញក្បត់ជាមួយអ៊ំហ្នឹង ប៉ុន្មាននាក់ៗអីអ៊ីចឹងទៅ ។ ប៉ុន្តែ ឈ្មោះអ្នកទាំងអស់ហ្នឹង គឺអ៊ំចេះតែឆ្លើយដាក់ទេ ឈ្មោះខ្មោច ខ្ចីឈ្មោះខ្មោចមកដាក់ទេ ឲ្យតែបានរួចផុតពីការដែលគេធ្វើទារុណកម្ម អ៊ីចឹងមែនទេ?

**ឆ៖** បាទ, ពិតមែនហើយលោកប្រធាន ។

**ស៖** អ៊ំចូលមកដល់មន្ទីរស-២១ ហ្នឹង ថ្ងៃខែឆ្នាំណាដែរ អ៊ំចាំទេ?

**ឆ៖** លោក ខ្ញុំចូលថ្ងៃ២៨ ខែ១០-[១៩]៧៨ ទាន ។

**ស៖** ក្នុងអំឡុងពេលពី២៨ ខែ១០-[១៩]៧៨ ក្រៅពីបទពិសោធអ្វីដែលអ៊ំបានជួបប្រទះនូវអំពើដោយបុគ្គលិកនៅមន្ទីរសន្តិសុខស-២១ បានប្រព្រឹត្តចំពោះអ៊ំ តើអ៊ំបានសង្កេតឃើញទិដ្ឋភាពផ្សេងទៀត

បានន័យថា ស្ថានភាពនៃការឃុំឃាំង នៃការទារុណកម្ម ឬក៏អំពើផ្សេងៗទៀតនៅនោះ ដែលអ៊ំកត់សម្គាល់ បានឃើញអ្វីដែរទេចំពោះអ្នកដទៃ ក្រៅពីអ៊ំផ្ទាល់?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោក! ក្រៅពីខ្ញុំបាទហ្នឹង អ្នកដទៃ គឺថា ខ្ញុំបាទមានពេលមួយ គឺថាកំពុងតែធ្វើម៉ាស៊ីនដេរហ្នឹងៗ មានគេសែងមនុស្សតាមក្រោយខ្នងខ្ញុំហ្នឹង ។ សែងមនុស្សបីនាក់ យកទៅកប់ក្រោមអំពិលបារាំងមួយធំនៅជិតទ្រុងមាន់ ទ្រុងទន្សាយហ្នឹង យកទៅកប់ជិតនុ៎ង ។

**ស៖** អ៊ំដែលឃើញគេធ្វើទារុណកម្មអ្នកដទៃ ដោយផ្ទាល់ភ្នែកទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! មិនដែលឃើញទេ ក៏ប៉ុន្តែ ឮសូរតែសំឡេងស្រែកទាន ។

[១០:២១:២០]

**ស៖** អ៊ំដែលឃើញជនជាប់ចោទ ធ្លាប់ធ្វើទារុណកម្មអ្នកដទៃដែរទេ ក្នុងអំឡុងពេលដែលអ៊ំទៅជាប់នៅទីនោះ?

**ឆ៖** អត់ដែលឃើញទេទាន មិនដែលឃើញទេទាន ។

**ស៖** ពីព្រោះអំមិញ អ៊ំបានឆ្លើយហើយថា អ៊ំអត់ដែលស្គាល់ផង ព្រោះអ៊ំចេញទៅរហូតដល់ថ្ងៃចេញអ៊ំអត់ស្គាល់គេទេ ។ ហើយចងមុខផង ។

អ៊ំពេលដែលគេដោះលែងអ៊ំ ឱ្យអ៊ំទៅជួសជុលម៉ាស៊ីនដេរ ។ ក្រៅពីជួសជុលម៉ាស៊ីន គេឱ្យជួសជុលម៉ាស៊ីនភ្លើងមួយទៀត-- ម៉ាស៊ីនបូមទឹក? បាទម៉ាស៊ីនបូមទឹកមួយទៀត ។ នៅក្នុងអំឡុងពេលដែលគេដោះលែងអ៊ំអីចឹង សួរថា អ៊ំពេលយប់-- ពេលដែលអ៊ំធ្វើការហ្នឹង មួយថ្ងៃប៉ុន្មានពេល?

**ឆ៖** ជម្រាបប្រសាសន៍លោក! ពេលធ្វើការហ្នឹង ធ្វើរហូតតែម្តង អត់មានពេលសម្រាកទេៗទាន ។

**ស៖** អត់មានពេលសម្រាកម៉េច? មនុស្សតែអត់សម្រាកតែរ៉ៃមួយអាទិត្យអីស្លាប់បាត់ទៅហើយព្រោះវាអត់ដេក អត់ពួន ធ្វើប៉ុន្មានពេល? អាចបីពេល ឬក៏ពីរពេល? ធ្វើព្រឹក ធ្វើល្ងាច ឬក៏ធ្វើទាំងពេលយប់ផងដែរ?

**ឆ៖** ពេលចេញទៅខាងក្រោយ វាបញ្ចេញឱ្យធ្វើការក្រោយហ្នឹង អាហ្នឹងធ្វើតែពីរពេលទេអាហ្នឹងធ្វើតែពីរពេលទេ តែធ្វើហ្នឹង គឺធ្វើព្រឹករហូតទល់ពេលល្ងាចតែម្តង លើកលែងតែពេលហូបបាយទេ ហូបបបរទេ ។

**ស៖** ចុះនៅពេលយប់គេឱ្យអ៊ំទៅសម្រាកនៅកន្លែងណា?

**ឆ៖** ពេលយប់គឺថា គេយកខ្ញុំទៅដាក់ខាងលើនោះ ជាន់ខាងលើបំផុតនុ៎ង យកទៅដាក់ខាងលើ ហ្នឹង គឺថា ដាក់អាខ្នោះវែងៗហ្នឹង វាឲ្យយើងដេកតម្រៀបគ្នានៅហ្នឹង វាដាក់ខ្នោះនៅហ្នឹងៗ ពេលនុ៎ង គឺថា ខ្ញុំដេកជាប់ជាមួយ តាតួន តាពេទ្យធ្មេញហ្នឹង ដេកជាប់គ្នា ។

**ស៖** អ៊ីចឹងបានន័យថា ទោះបីគេដោះលែងអ៊ំឲ្យមកធ្វើការជាជាងជួសជុលម៉ាស៊ីនដេរ ឬក៏ជួសជុលម៉ាស៊ីនបូមទឹកក៏ដោយ នៅពេលយប់ក្រោយពីអ៊ំចប់ការងារហូបអាហារពេលល្ងាចរួច គឺត្រូវគេបញ្ជូនអ៊ំទៅឡើងទៅជាន់ទីពីរ ទៅបន្ទប់រួមហ្នឹងហើយក៏ត្រូវគេដាក់ខ្នោះដែរ ដាក់ខ្នោះជើងដូចអ្នកជាប់ឃុំឃាំងទៀតដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ពិតមែនហើយ គេដាក់ខ្នោះជាប់រហូតទាល់ភ្លឺតែម្តង បានគេមកស្រាយឲ្យធ្វើការទៀត ។

[១០:២៥:០៨]

**ស៖** ចុះទិដ្ឋភាពផ្សេងទៀតដែលអ៊ំបាននិយាយអំមិញ កូនក្មេងពីរនាក់នេះ អំឡុងពេលដែលអ៊ំទៅធ្វើការងារនៅហ្នឹង អ៊ំឃើញកូនក្មេងនៅពីរនាក់ នៅទីនោះតែម្តង ឬក៏ទាល់តែថ្ងៃទី៧ ថ្ងៃចុងក្រោយថ្ងៃ៧ ខែមករាហ្នឹង ទើបបានអ៊ំឃើញក្មេងពីរនាក់នុ៎ង?

**ឆ៖** ជម្រាបប្រសាសន៍លោក! ក្មេងពីរនាក់ហ្នឹង បើតាមខ្ញុំប៉ាន់ស្មានប្រហែលជាមួយខែ វាទៅខាងក្រោយហ្នឹង ទៅរហូត តែពេលព្រឹកវាទៅនោះ ពេលព្រឹកទៅនោះហើយ ហើយដល់ហើយខ្ញុំចេះសម្លឹងមើលទៅខ្ញុំសួរមិត្តសុះ អ្នកបបរបាយហ្នឹង ខ្ញុំសួរមិត្តនារីកូនហ្នឹង កូននរណាគេ? ដល់ហើយគេថាកូនលោកតា ចេង អន ដល់អ៊ីចឹងខ្ញុំក៏ឈប់សួរទៅហ្នឹង ។

**ស៖** អ៊ំដឹងជោគវាសនារបស់កុមារពីរនាក់នុ៎ងយ៉ាងម៉េចទេ ក្រោយមក?

**ឆ៖** បាទ,ជម្រាបប្រសាសន៍លោក! ខ្ញុំអត់បានដឹងទេ ពេល-- ប៉ុន្តែពេលដែលខ្ញុំមកក្នុងហើយក្មេងហ្នឹង នៅខាងក្រៅរបង គេបិទរបងហើយក្មេងហ្នឹង នៅខាងក្រៅរបងនៅអាកន្លែងបបរបាយហ្នឹងទាន ។

**ស៖** មុនពេលអ៊ំចេញទៅ អ៊ំមានបានកត់សម្គាល់ថា នៅក្នុងបរិវេណនៃមន្ទីរសន្តិសុខស-២១ហ្នឹង មានសល់មនុស្សទេ មានសល់អ្នកទោសដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! បើតាមខ្ញុំប៉ាន់ស្មាន មិនមានសល់ទេ បើថាសល់តាមដែលខ្ញុំប៉ាន់ស្មានប្រហែលសល់ក្មេងនុ៎ង ។ ក្មេងនុ៎ងថ្ងៃក្រោយទៅ ឮសួរថាក្មេងហ្នឹងចូលក្នុងគំនរខោអាវហ្នឹងទាន។

**ស៖** យើងសួរអ្នកទោសផ្សេងទៀត បានន័យថា អ្នកទោសជាប់ឃុំឃាំងផ្សេងទៀតហ្នឹង មានសល់ទេ? អាចសល់ មានអ្នកសល់ ឮសំឡេង ឬក៏មានការកត់សម្គាល់អ្វីមួយដែលបញ្ជាក់ថា វាអាចមានសល់មនុស្សមុននឹងអ៊ំចាកចេញពីទីនោះ ឬក៏អត់មានដឹង អត់មានយល់បានពីបញ្ហានោះទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោក ខ្ញុំអត់បានដឹងទេ គឺថាចេញទៅចេញទៅតែម្តង ។

**ស៖** ពេលណាបានអ៊ំត្រឡប់ទៅដល់មន្ទីរសន្តិសុខព្រៃស សាជាថ្មីម្តងទៀត ក្រោយថ្ងៃរំដោះ៧ មករា ឆ្នាំ១៩៧៩?

[១០:២៧:៥២]

**ឆ៖** ជម្រាបប្រសាសន៍លោក! សុំសំណួរលោកម្តងទៀត ស្តាប់អត់ច្បាស់ ។

**ស៖** ក្រោយពេលដែលអ៊ំបានធ្វើដំណើរទៅអមលាំង វង្វេងផ្លូវអីចុះឡើងមក ហើយមករស់នៅជួបប្រពន្ធក្រោយរបស់អ៊ំ អំមិញដែលអ៊ំថាគេចពីវៀតណាមទៅចូលជង្រុកស្រូវអីៗហ្នឹង ។ ហើយសួរថា ពេលណាបានអ៊ំបានត្រឡប់ទៅទីកន្លែងទុំងសាជាថ្មីម្តងទៀត នៅកន្លែងមន្ទីរសន្តិសុខស-២១ ឬគុកទួលស្លែងនោះណា?

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំពេលនោះ ខ្ញុំនៅធ្វើការនៅខាងគមនាគមន៍ ចូលកន្លែងខ្ញុំចាស់វិញហ្នឹង គឺថានៅខាងអូដឹម ធ្វើការនៅអូដឹមហ្នឹង ប្រហែលជាច្រើនខែដែរហ្នឹង បានខាងលោក ប៊ុច នេះ អ៊ឹង ប៊ុច នេះ គាត់ហៅខ្ញុំឱ្យទៅថតរូប ។ ថតរូបហ្នឹង គឺថា រូបថតហ្នឹងប្រមូលអស់ហើយបានប្រាំពីរនាក់ទេទាន ហើយដល់ខ្ញុំសួរថា ម៉េចបានថតរូបធ្វើអី? បានថតរូបយកទៅឱ្យអង្គការអន្តរជាតិ យកទៅលើកមុន អាល្លឺម៉ង់យកទៅលើកមុន គឺថាអង្គការសហប្រជាជាតិហ្នឹង គេអត់ជឿៗថា កាប់សម្លាប់គ្នាអីចឹងគេអត់ជឿទេ ។ អីចឹងខាងអាល្លឺម៉ង់ហ្នឹង ត្រឡប់មកមួយសាទៀតប្រមូលបានប្រាំពីរនាក់ហ្នឹងបានថត ប្រាំពីរនាក់ទៅបានអង្គការសហប្រជាជាតិគេជឿ ។

**ប្រធានអង្គជំនុំ៖**

អរគុណអ៊ំ ហើយឥឡូវនេះដល់ម៉ោងសម្រាក ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទី ហើយរហូតដល់ដប់មួយខ្វះដប់នាទី សូមអញ្ជើញចូលវិញ ដើម្បីបន្តកិច្ចពិភាក្សាដេញដោលតទៅទៀត ។ មន្ត្រីតុលាការសម្របសម្រួលដល់អ្នករស់រានមានជីវិតរូបនេះ ដើម្បីឱ្យគាត់រកកន្លែងសម្រាកសមរម្យ ។

*[សវនាការសម្រាកពីម៉ោង ១០:៣០នាទី ដល់ម៉ោង ១០:៥២ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។

អង្គជំនុំជម្រះប្រកាសបន្ត កិច្ចដំណើរការនីតិវិធីសវនាការដេញដោលចំពោះអ្នករស់រានមានជីវិតពីមន្ទីរសន្តិសុខ ស-២១ ឈ្មោះ ជុំ ម៉ី តទៅទៀត ។ ហើយមុននឹងចាប់ផ្តើមបន្តនេះ ខ្ញុំសូមរំឭកដល់អ៊ំ ជុំ ម៉ី ថាអ៊ំមិនបាច់ប៉ះពាល់ទៅនឹងឧបករណ៍នៃមីក្រូហ្វូនទៀតទេ ដោយអង្គជំនុំជម្រះបានធ្វើការសម្រុបសម្រួលផ្នែកខាងបច្ចេកទេសនៃមីក្រូហ្វូនរួចហើយ ខាងបច្ចេកទេស គេនឹងបញ្ចោបើក ។ អ៊ីចឹងពេលដែលខ្ញុំសួរសំណួរ ឬក៏ចៅក្រម ឬក៏អ្នកឯទៀតសួរសំណួរដល់អ៊ំ ទីមួយអ៊ំអាចបង្អង់បន្តិចរហូតដល់ពេលមានភ្លើងសញ្ញាក្រហម ហើយអ៊ំ ទើបអ៊ំឆ្លើយ ហើយដោយសារបញ្ហាមីក្រូហ្វូនផង ដោយសារបញ្ហាការបកប្រែភាសាផង ដោយសារការបកប្រែភាសានេះ មានការទាមទារពេលវេលាមួយចំនួនដើម្បីឱ្យមានលទ្ធភាពក្នុងការបកប្រែទៅភាសាអង់គ្លេស ហើយនិងពីភាសាអង់គ្លេសទៅភាសាបារាំងទៀត ។ ហើយមន្ត្រីតុលាការដូចជាអាចទៅរៀបចំមីក្រូហ្វូនគាត់ ដាក់ឱ្យចំហៀងទៅ ដើម្បីឱ្យគាត់បានមើលនូវមីក្រូហ្វូននេះនូវសញ្ញាក្រហម ជាសញ្ញាថាគាត់អាចចាប់ផ្តើមនិយាយបាន បើដាក់ចំមុខអ៊ីចឹងប្រហែលជា គាត់មិនអាចមើលឃើញនូវសញ្ញាក្រហមបានទេ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អ៊ំម៉ី តើអ៊ំអាចនិយាយរៀបរាប់ជូនដល់អង្គសវនាការបានទេ អំពីស្ថានភាពព្យសនកម្មទាំងឡាយដែលអ៊ំបានទទួលរងដោយអំពើនៃកងកម្លាំងរបស់ខ្មែរក្រហមបានប្រព្រឹត្តចំពោះអ៊ំក្នុងអំឡុងពេលដែលអ៊ំបានជាប់មន្ទីរឃុំឃាំងស-២១ ឬក៏គុកទួលស្លែងនោះទាំងផ្នែកខាងរូប-- ផ្លូវរាងកាយ ទាំងខាងផ្លូវចិត្ត ដែលមានរហូតដល់បច្ចុប្បន្នចំពោះអ៊ំ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោក! គឺថាចំពោះគេធ្វើទារុណកម្មចំពោះខ្ញុំ គឺថាខ្ញុំដេកគិតកន្លងមក ខ្ញុំមើលទៅហាក់ដូចជា ដូចជាសត្វ ដូចជាធាតុ បញ្ហាហ្នឹងគឺថាខ្ញុំពិបាកមែនទែន ពេលដែលចូលទៅឃើញអាកែសគ្រាប់ហ្នឹង គឺថាវាសម្រាប់ឱ្យបត់ជើងធំ កែសគ្រាប់ហ្នឹង ។ ហើយអាកាដុងបួនលីត្រនោះឱ្យឈឺនោមនៅហ្នឹង ពេលនុំងគឺថាខ្ញុំនឹកឃើញថា រកអាស្អីក្រាលដេកក៏អត់មាន ដេកនៅនឹងឥដ្ឋៗហ្នឹងមានតែខោខ្លីមួយទេហ្នឹង មានតែខោខ្លីមួយ ដេកនៅនឹងឥដ្ឋហ្នឹងតែម្តង ខមាលទោស បត់ជើងធំក៏នៅហ្នឹង បត់ជើងតូចក៏នៅហ្នឹង ហើយធំស្អុយពេញហ្នឹងទាំងអស់ ។ ក្នុងរយៈពេលដប់ពីរថ្ងៃ ដប់ពីរយប់ហ្នឹង គេដះទឹកឱ្យខ្ញុំបានតែពីរដងទេទាន ។

[១០:៥៧:៣៨]

**សៈ** អង្គជំនុំជម្រះពិនិត្យឃើញស្ថានភាពអ៊ំហ្នឹង គឺមានការពិការនូវក្រចកទាំងសងខាងរបស់អ៊ំ ដោយសារការធ្វើទារុណកម្ម គឺយកដង្កាប់ច្របាច់ ហើយនិងដកក្រចកចេញហ្នឹងគឺទីមួយ ។ ទីពីរស្ថានភាពដូចជាការវាយនឹងរំពាត់ជាច្រើនលើកច្រើនសា ច្រើនរំពាត់ និងការដែលគេឆក់ខ្សែភ្លើងហ្នឹង វាមិនទាន់ អ៊ំ!មិនសំដែងឃើញជារូបភាពជាក់លាក់នៃស្ថានភាពរបួសពិការទេ តើស្ថានភាពខ្លួនរបស់អ៊ំនេះ ស្ថានភាពហ្នឹងតើយ៉ាងម៉េចទៅ? ទីពីរតើបញ្ហាអ៊ំយ៉ាងម៉េចដែរ បច្ចុប្បន្ននេះ?

(ម្តងទៀតអ៊ំៗកុំចុច កុំប៉ះ ចាំមានសញ្ញាភ្លើងក្រហមមកសឹមអ៊ំនិយាយ ដើម្បីទុកពន្យារពេលបន្តិច ទម្រាំតែរង់ចាំអ្នកបកប្រែភាសាហ្នឹង បកប្រែភាសាដែលខ្ញុំសួរសិន ។)

**ឆៈ** ពេលដែលគេធ្វើទារុណកម្មហ្នឹង ខ្ញុំហាក់បីដូចជាអាដែងហៅថា មិនមែនជាមនុស្ស ដូចសត្វអ៊ីចឹង រួចពេលមកឃើញអាកែសគ្រាប់នៅកន្លែងហ្នឹង បត់ជើងធំហ្នឹង ហើយកាដុងបត់ជើងតូចហ្នឹង ហើយគេ ឲ្យយើងដេកនៅនឹងឥដ្ឋហ្នឹង គឺថាមានលាមកក៏មាននៅហ្នឹង ទឹកនោមក៏មាននៅហ្នឹង ស្អុយឆ្អាបពេញ ហ្នឹង ហើយក្នុងរយៈពេលដប់ពីរថ្ងៃ ដប់ពីរយប់ហ្នឹង គេជះទឹកដាក់ខ្ញុំបានតែពីរដងទេ ។

**សៈ** អារម្មណ៍របស់អ៊ំឥឡូវម៉េចដែរ ព្រោះវាអាចមានប៉ះពាល់អីទេ ឬក៏អ៊ំស្មារតីអ៊ំនៅចងចាំធម្មតា ដូចជាស្ថានភាពធម្មតា ពីមុនដែលអ៊ំទទួលរងនៅក្នុងអំពើដែលប៉ះពាល់លើអ៊ំក្នុងរបបខ្មែរក្រហម ឬក៏មានការប្រែប្រួលយ៉ាងម៉េច?

**ឆៈ** ចំពោះខ្ញុំបាទហ្នឹង មានអារម្មណ៍ថា រាល់ថ្ងៃហ្នឹង គឺថាអារម្មណ៍របស់ខ្ញុំ គឺថាវាមានផ្តោតចំពោះមកលើតុលាការដើម្បីឲ្យតុលាការជួយរកយុត្តិធម៌ចំពោះរូបខ្ញុំ បារម្ភខ្ញុំរាល់ថ្ងៃ គឺថាអ៊ីចឹងតែម្តង ហើយកន្លងមក គឺថាខ្ញុំមកតុលាការហ្នឹងរហូតតាំងពីអើយមក ខ្ញុំមករហូត ដើម្បីចង់ស្តាប់ ចង់ដឹង ចង់ឮចំពោះលោកប្រធានចៅក្រម អារឿងកាត់ក្តីហ្នឹងយ៉ាងម៉េច អីយ៉ាងម៉េច ខ្ញុំតាមដានរហូតមកម្តង ។ ពេលនោះ គឺថាអារម្មណ៍របស់ខ្ញុំ គឺថាទឹកភ្នែកហូររាល់យប់ ។ ឲ្យតែឮគេនិយាយអារឿង ខ្មែរក្រហមហ្នឹងឡើង វានឹកដល់រឿងកូនប្រពន្ធ ម្ល៉េះហើយ *(សូរយំខ្សឹបខ្សួល)* រាល់ថ្ងៃហាក់ដូចជា មនុស្សឆ្កួតអ៊ីចឹង រាល់ថ្ងៃអារម្មណ៍របស់ខ្ញុំ គឺថានឹកឃើញប្រពន្ធគេយកទៅដាក់នៅព្រៃស ហើយខ្ញុំគេយកមកដាក់នៅ ស-២១ ទួលស្លែង ហើយពេលនុំងប្រពន្ធខ្ញុំទម្ងន់ផង ហើយការឆ្លងទន្លេ ហ្នឹងមិនដឹងជាយ៉ាងម៉េចទេ? ពេលថ្ងៃមួយឮសួរលោកចៅក្រមសួរពីរឿង អ៊ំៗ!នៅព្រៃស គេថាមាននារីៗពោះធំប្រាំបីនាក់ហ្នឹង គឺថាខ្ញុំទ្រាំអត់បានហូរទឹកភ្នែកមកឯងម្តង ។ ប្រាំបីនាក់ហ្នឹង តាមដំណាលមានគ្រួសារខ្ញុំដែរ ប្រហែលទេ ខ្ញុំគ្រាន់

តែប្រហែលទេ ។ ហើយដល់ទៅវេលាខ្ញុំធ្វើដំណើរទៅ ក៏ជួបគ្រួសារខ្ញុំថាឆ្លងទន្លេបានពីរខែហើយ ហើយធ្វើដំណើរសំដៅទៅអារឿងអមលាំងហ្នឹងទៀត ។ វាទេសកាលអីអាឃើញគេកើតកូននៅម្លប់ត្នោតនោះ គេកើតកូននៅម្លប់ត្នោតនុំងពេលហ្នឹង ហើយគ្រួសារខ្ញុំក៏បានឲ្យក្រមាគេមួយទៅ ហើយខ្ញុំក៏ធ្វើដំណើរទៅទៀតទៅ ។ អាបញ្ហាហ្នឹងហើយ ដែលខ្ញុំទប់ទល់កំហឹងរបស់ខ្ញុំអត់បាន ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីសួរដល់អ៊ំ ជុំ ម៉ី ដែរឬទេ? សូមអញ្ជើញលោកស្រីចៅក្រម ។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៌៖**

សូមអរគុណច្រើនលោក ជុំ ម៉ី ដែលលោកបានមកចូលរួមនៅក្នុងថ្ងៃនេះ ក្នុងកិច្ចដំណើរការនីតិវិធីរបស់យើង ។ ខ្ញុំមានសំណួរពីរ ឬក៏បីសំណួរតែប៉ុណ្ណោះ ដើម្បីសុំការបំភ្លឺ ។

**ស៖** មុននេះលោកប្រធានបានសួរលោកអ៊ំ ថាតើលោកអ៊ំបានដឹងថាគេចោទប្រកាន់អ៊ំអំពីអ្វីនៅពេលដែលគេចាប់ខ្លួនលោកអ៊ំ និង បញ្ជូនទៅស-២១ ប៉ុន្តែ យើងមិនបានឮការបកប្រែទៅលើចម្លើយរបស់លោកអ៊ំនោះទេ ។ ដូច្នេះ ខ្ញុំចង់សុំឲ្យ លោកអ៊ំឆ្លើយទៅលើចំណុចនៃមូលហេតុការចាប់ខ្លួនលោកអ៊ំ?

[១១:០៤:៣៣]

**ឆ៖** ជម្រាបប្រសាសន៍លោក! គឺថាពេលនោះ គឺថាគេចោទខ្ញុំថាខ្ញុំជា *សេអ៊ីអា* ជា *កាហ្សេបេ* អាបញ្ហាហ្នឹង គឺថាខ្ញុំបាទអត់ដែលស្គាល់អារឿង *សេអ៊ីអា, កាហ្សេបេ* ខ្ញុំអត់ដែលស្គាល់ទេ តែឮសួរតែគេនិយាយមែន តែរឿងតួនាទីគេ មិនដឹងជាគេធ្វើអីទេ ។ អាបញ្ហាហ្នឹងហើយ ដែលខ្ញុំរហូតមករាល់ថ្ងៃ ហ្នឹងដែលខ្ញុំចង់ដឹង តែរឿងខ្ញុំជា *សេអ៊ីអា, កាហ្សេបេ* តើវាចេញពីប្រភពណាមក? ដែលខ្ញុំចង់ដឹងថារឿងខ្ញុំជា *សេអ៊ីអា, កាហ្សេបេ* ហ្នឹង តើវាចេញពីប្រភពណាមួយ? ខ្ញុំចង់ដឹងនែ៎ ព្រោះខ្ញុំវាអត់ដឹងរឿង *សេអ៊ីអា, កាហ្សេបេ* ហ្នឹងសោះ ។

**ស៖** ដូច្នេះបុគ្គលដែលគេសំដៅទៅលើ *សេអ៊ីអា* ឬក៏ *កាហ្សេបេ* គឺអ្នកនោះអ្នកនោះហើយ ដែលគេចោទដូច្នោះ ហើយគេចាប់ខ្លួនលោកអ៊ំ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** ការណ៍ហ្នឹង វាត្រឹមត្រូវហើយ ជម្រាបប្រសាសន៍លោក ។ ក៏ប៉ុន្តែ អាបញ្ហា *សេអ៊ីអា, កាហ្សេបេ* ហ្នឹងលោកស្រីមើល ខ្ញុំអត់អស់ចិត្ត អត់អស់ចិត្តយ៉ាងម៉េច កូនខ្ញុំទើបតែបានពីរខែ គេយក

ទៅសម្លាប់ ហើយអាកូន ហើយនិងឧទាហរណ៍ថា នៅទួលស្លែងហ្នឹង គាត់លើកឡើងថា មានកុមារៗ ជាប់ពីរពាន់នាក់ ហើយខ្ញុំចូលមើលរូបថតហ្នឹង មានយាយខ្លះគាត់អស់ធ្មេញរលីង ប្រហែលជាអាយុ ៧០-៨០ សួរថាយាយហ្នឹងគាត់ចេះធ្វើ *សេអ៊ីអា, កាហ្សេបេ* ដែរយ៉ាងម៉េច ហើយក្មេងទើបតែបានពីរឆ្នាំ តើក្មេងហ្នឹងចេះធ្វើ *សេអ៊ីអា, កាហ្សេបេ* ដែរឬយ៉ាងម៉េច? អារឿងហ្នឹងហើយ ខ្ញុំចង់ដឹងតែអាបញ្ហាហ្នឹងតើ អាបញ្ហាហ្នឹង ខ្ញុំស្មានក្នុងចិត្តខ្ញុំទេ គឺថាការបំបាត់ពូជសាសន៍ហើយអាហ្នឹង ។ បាទ ជម្រាបលោកស្រី ។

**ស៖** នៅពេលដែលអ៊ំនិយាយថា ក្មេងពីរពាន់នាក់ត្រូវបានគេឃុំខ្លួន ហើយកូនពីរខែរបស់លោកត្រូវបានគេយកទៅឆ្ងាយ ។ លោកអ៊ំនិយាយអំពីព្រឹត្តិការណ៍នេះនៅព្រៃស ឬក៏និយាយអំពីព្រឹត្តិការណ៍នៅស-២១?

**ឆ៖** ជម្រាបប្រសាសន៍! គឺថាពេលដែលខ្ញុំចេញទៅហ្នឹង គឺគេថាខ្ញុំចេញពីជួបគ្រួសារខ្ញុំ នៅព្រៃស ជួបគ្រួសារនៅ-- ហួសពីព្រៃសទៅទៀត ទៅនៅគេហៅថា អង្គស្នួលនោះ ។ ជួបគ្រួសារខ្ញុំត្រង់ហ្នឹង គាត់ឆ្លងទន្លេបានពីរខែហើយ ។ ពេលនុ៎ង ខ្ញុំទៅជួប មាននារីបីបួននាក់នៅត្រង់អាអង្គស្នួលហ្នឹង ដល់ហើយអ៊ីចឹង ខ្ញុំសូមជួយបីកូនទៅផង ។ គេថា អើ!បីៗទៅ ។ ខ្ញុំក៏ជួយបីកូនទៅហ្នឹង គឺថានាំគ្នាឆ្លងកាត់ថ្នល់ទៅខាងជើង ។ ដល់ឆ្លងកាត់ថ្នល់ទៅខាងជើង គឺថាមានឡានវៀតណាម គឺថាពីរឡាន គឺឡាន *ហ្សេអឹមសេ* ពីរឡាន មកដល់វាបាញ់មួយកំណាត់ហ្នឹង មួយកំណាត់ត្រឡប់មកក្រោយវិញ មួយកំណាត់ឡើងមកហួសទៅ ហើយខ្ញុំបាទឡើងទៅជាមួយគ្រួសារខ្ញុំ ជាមួយតាអេង ហើយពួកតា ឌី ផុន អីហ្នឹងក៏ទៅតាមផ្លូវហ្នឹងដែរ មួយកំណាត់មកក្រោយ មួយកំណត់ទៅមុខ ។

[១១:០៨:០៣]

**ស៖** សូមអរគុណ ។ ប្រហែលជាបញ្ហានៃការបកប្រែ ប៉ុន្តែខ្ញុំសូមការបំភ្លឺពីលោកអ៊ំ ថាតើលោកអ៊ំពរ ឬក៏បីកូនពីរខែរបស់លោកអ៊ំដែរឬទេ ក្រោយពីជួបប្រពន្ធ និងស្ត្រីបីនាក់នោះ? ឬក៏លោកអ៊ំបីកូនអ្នកដទៃ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! បីហ្នឹង គឺបីកូនខ្ញុំបាទ កូនខ្ញុំបាទហ្នឹង កូនប្រុសទៀត បាទ កូនប្រុស ។ បីកូនខ្ញុំហ្នឹង ដល់ហើយក៏ឆ្លងកាត់ថ្នល់ ទៅខាងជើងថ្នល់ ។ ទៅឆ្លងទៅហ្នឹង គឺថាវៀត-ណាមបាញ់ផ្តាច់មួយកំណាត់ហ្នឹងត្រឡប់មកក្រោយវិញ មួយកំណាត់ឡើងហួសទៅ អាហ្នឹងកូនខ្ញុំបាទ ខ្ញុំបានឃើញមុខកូនតែពីម៉ោងប្រាំពីរព្រឹក រហូតដល់ម៉ោងដប់ពីរយប់ គឺបែកគ្នាហ្នុ៎ង ។

**ស៖** ដូច្នេះ ប្រពន្ធនិងកូនប្រុសរបស់លោក ត្រូវបានគេសម្លាប់ចោលនៅអំឡុងពេលហ្នឹង នៅពេលដែលវៀតណាម គេបាញ់សំដៅមកលើក្រុមរបស់លោកអ៊ំ ឬយ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ពេលហ្នឹង មិនមែនស្លាប់នៅពេលហ្នឹងទេ ពេលវៀតណាមបាញ់ហ្នឹងហើយ ខ្ញុំក៏ធ្វើដំណើរជាមួយប្រពន្ធទៅរហូត ទៅជិតដល់ស្រះធុលហ្នឹង ឃើញគេសម្រាលកូនម្នាក់នៅម្លប់ត្នោត ឃើញគេសម្រាលកូននៅម្លប់ត្នោតហ្នឹង ហើយគ្រួសារខ្ញុំក៏បានឱ្យក្រមាគេមួយៗ បានធ្វើដំណើរទៅទៀត ធ្វើដំណើររហូតទៅដល់វត្តស្រះធុលហ្នឹង យើងចូលទៅដល់វត្តហ្នឹងរកសុំអង្ករគេៗ បបរបាយហូប ។ ហើយយើងមើលឃើញនៅហ្នឹង ទិដ្ឋភាពនៅហ្នឹងមានឃើញទាហានៗនេះប្រហែលជា៥០នាក់នៅនឹងវត្តហ្នឹង ។ ដល់ហើយគេថាមិត្តឯងមកពីណាមក? ខ្ញុំថា មកពីកន្លែងកាត់ដេរ ហើយស្រុកកំណើតនៅឯណា? ខ្ញុំថា នៅបូព៌ា ។ ដល់អ៊ីចឹងគេថា ឱ្យខ្ញុំនៅហ្នឹងហើយ ចាំបានសំបុត្រពីអង្គការ អាហ្នឹងចាំធ្វើដំណើរទៅទៀត បានសំបុត្រ បានអង្កររហូបហើយ ។ ហើយគេដាក់ខ្ញុំនៅមុខសាលាឆាន់ហ្នឹង នៅលើគ្រែហ្នឹង ឱ្យដេកនៅលើគ្រែហ្នឹង ។ ដល់ពេលអាម៉ោង តាមខ្ញុំប៉ាន់ស្មានទេ ខ្ញុំអត់មានម៉ោងទេ ខ្ញុំប៉ាន់ស្មានប្រហែលជាម៉ោងជិតដប់ពីរហ្នឹង ទាហានអស់ហ្នឹងទៅបាត់អស់ទៅ នៅសល់អាឈ្លបម្នាក់ នៅដើរយាមជុំវិញគ្រែហ្នឹងៗ រហូតប្រហែលជាម៉ោងដប់ពីរ ខែភ្លឺទេ ស្រាប់តែឃើញបីនាក់មក កាំភ្លើងគ្រប់ដៃហ្នុង កាំភ្លើងគ្រប់ដៃ ។ មកដល់សួរអាអ្នកឈ្លបយាមហ្នឹង សួរថា ឯណាបីនាក់ ដែលយកទៅវៃចោលហ្នឹង វាថានេះ នៅដេកលើគ្រែហ្នឹង ដល់អ៊ីចឹងខ្ញុំភ្ញាក់ខ្លួនឡើងៗ កេះគ្រួសារឱ្យឡើង ហើយកេះតាអេងហ្នឹងឱ្យឡើង ។ ដល់ហើយគាត់ថា បានសំបុត្រពីអង្គការហើយ តោះវាជូនដំណើរទៅ ។ ដល់ហើយវាប្រាប់គ្រួសារខ្ញុំថា “មិត្តនារីដើរទៅមុន មិត្តនារីដើរយឺតណាស់” ដល់ដើរយឺតអ៊ីចឹងហើយ ទទួលវាឱ្យដើរផុតពីវត្តហ្នឹងប្រហែលជាមួយគីឡូដីៗខែភ្លឺហ្នឹង ស្រាប់តែឮបាញ់កាំភ្លើងរ៉ាវអ៊ីចឹងទៅ គ្រួសារខ្ញុំស្រែកប្រាប់ “ប៉ាអាភាព អើយ!រត់ទៅៗ គេសម្លាប់ខ្ញុំហើយ” ។ រួចបន្ទាប់មក វាបាញ់តាអេងពីមុខខ្ញុំហ្នឹងទៀត ប្រហែលពីហ្នឹងទៅនុ៎ង ប្រហែលប្រាំម៉ែត្រ-ប្រាំមួយម៉ែត្រហ្នឹងបាញ់ តាអេង ដួលប្រួសនៅពីមុខខ្ញុំហ្នឹង បានខ្ញុំរត់ រត់ទៅ វាបាញ់ខ្ញុំពីក្រោយៗ អស់ប្រហែលជាមួយបង់អ៊ីចឹងទៅ ខ្ញុំរត់គេចនឹងដំបូក គេចដំបូក ។ ប៉ុន្តែ ខ្ញុំអត់ចូលដំបូកហ្នឹងទេ ខ្ញុំផ្តួលខ្លួនលូនអែបភ្លឺស្រែអ៊ីចឹងហ្នុង លូនអែបអ៊ីចឹងទៅ វាថា “ចូលក្នុងដំបូកហ្នឹងអំមិញៗ” ដល់ហើយវារកបាញ់ក្នុងដំបូកហ្នឹង តែពេលនោះខ្ញុំលូនទៅឆ្ងាយ ខ្ញុំចាប់រត់ហើយពេលហ្នឹង ។ ហើយរត់ហ្នឹងជម្រាបប្រសាសន៍លោកស្រីចៅក្រម ជម្រាបប្រសាសន៍ថា មិនដឹងរត់ទៅណា អីណា ខ្ញុំបាទវង្វេង ចេះតែរត់ រត់អ៊ីចឹងរហូត ត្រឹកៗ

អ៊ីចឹងទៅ ដល់រៀបភ្លឺអ៊ីចឹង ចូលពួនក្នុងព្រៃៗហើយ ដល់ព្រលប់ៗយើងចេញមករត់ទៀត ត្រឹកៗ ចេះតែរត់ មិនដឹងរត់ទៅណាទេ រហូតដល់បីយប់ ។ បានអាយប់ទីបីហ្នឹង បានខ្ញុំជួបនារីពីនាក់គេទួលអាល្អីស្រូវៗទៅសួរ ថាមិត្តនារីជិតដល់នៅ ន៎ែ ត្នោតពង ។ វាថាអ៊ំា ត្នោតពង ឯណាមកអាហ្នឹង អាហ្នឹងដល់អមលាំង ហើយ ។ ដល់ហើយគេថា ត្នោតពង នៅឯក្រោយណ៎! ដល់ហើយខ្ញុំក៏រត់ត្រឡប់មកក្រោយវិញ ដល់រត់មកក្រោយអ៊ីចឹងរៀបភ្លឺអ៊ីចឹងទៅ យើងចូលពួននៅក្នុងព្រៃទៅ ។ ពេលយប់យើងមើលគ្នាអត់ស្គាល់ យើងចេញមករត់ទៀត ត្រឹកៗរហូត ។ ដល់មកដល់ជិតអាយើងភ្នំត្នោតពង គេហៅ ភូមិធំ នោះមកដល់សួរគេទៅ គេថានោះភ្នំត្នោតពង មើលឃើញលឹមៗ អាហ្នឹងប្រហែលជាម៉ោងបួនភ្លឺ ម៉ោងប្រាំភ្លឺហ្នឹង ។ ដល់អ៊ីចឹងខ្ញុំសំដៅភ្នំត្នោតពងហ្នឹងៗ ទៅដល់អាជើងភ្នំត្នោតពងហ្នឹង អង្កាល់ខ្ញុំទៅប្រជាជននៅជួរតាមភ្នំត្នោតពងហ្នឹង ដល់ខ្ញុំទៅដល់អាពេលនេះ គឺថាអស់ប្រជាជនរលីង ។

ដល់អ៊ីចឹងខ្ញុំចូលទៅដល់អាខ្ទមមួយ ខ្ញុំបានអាកាំបិតផ្គាក់មួយប្រវែងនេះ ខ្ញុំលីកាំបិតផ្គាក់ហ្នឹងដើរបានបន្តិចមក ខ្ញុំឃ្លានពេក ខ្ញុំចូលទៅអាផ្ទះមួយ អាខ្ទមមួយនោះ ទៅកាប់ដើមអំពៅគេ បានពីរដើមក្អួយកាប់បានពីរដើម ពេលហ្នឹងខ្ញុំហូបអត់ចង់ខ្ជាក់ចោលទេក្អួយ ពេលហ្នឹងវាឃ្លានពេក ចង់លេបទាំងកាកហ្នឹង ។ ចេះតែដើរ តាមផ្លូវដែលយើងទៅមុន ដើរតាមផ្លូវហ្នឹងត្រឡប់មកក្រោយវិញ ។ មកដល់យើងហៅថា ភូមិក្តាន់រយ ហ្នឹង គឺថាជួបពួកគេដប់ប្រាំនាក់ទៀត កំពុងតែឲ្យប្រជាជនទឹមរទេះ ឲ្យសំដៅទៅអមលាំង ។ ហើយគេ សួរខ្ញុំថា មិត្តឯងទៅណា? ខ្ញុំថា ខ្ញុំទៅយកកូននៅសហករណ៍ស្នោរ ។ សួរថាមកវិញទេ? ខ្ញុំថាមកវិញ ខ្ញុំប្រញាប់មកវិញ ។ ដល់មកដល់ស្នោរហ្នឹង សួរថាមិត្តឯងមកពីណាមក? ខ្ញុំថា ខ្ញុំទៅយកកូនទៅ គ្រែល ។ ពេលនុំងមកដល់គ្រែលហ្នឹង ជួបអាគ្រួសារខ្ញុំវាល់ថ្ងៃនេះ វានៅដេកជាមួយប្រពន្ធខ្ញុំដែរ ជួបនៅហ្នឹងបាននាំគ្នានៅផ្ទះហ្នឹង ប្រមូលស្រូវអង្ករអីៗ សព្វគ្រប់អ៊ីចឹងទៅ ដល់ពេលនុំង ពេលអាឡាន អូតូប្តង់ដេ ឡានវៀតណាម វាបើកតាមអាកន្លែងនេះ ឃើញអ៊ីចឹង ខ្ញុំរត់ ដល់រត់គេថាកុំរត់ ប្រយ័ត្នវា បាញ់ ដល់ហើយខ្ញុំពួនគល់ត្នោតទៅ ។

[១១:១៥:១៥]

ក្រោយមកបាននេះៗ បានខាងបែកចាន នេះគេមកភូមិស្រុកគេដែរ ខ្ញុំថាអ៊ីចឹងខ្ញុំសូមទៅដែរ ទៅបែកចានហ្នឹង ទៅនៅបែកចាន រោងចក្របែកចានហ្នឹង ។ នៅរោងចក្របែកចានហ្នឹង នៅតែខ្លាចវៀត-ណាមទៀត ខ្ញុំអត់ហ៊ានឲ្យជួបវៀតណាមទេ ។ ឲ្យតែឃើញវៀតណាមដើរមក ខ្ញុំចូលពួននៅជម្រុកស្រូវហើយ ចូលពួនអស់ពីរថ្ងៃ ក្រោយមកបានចេញ ។ ឲ្យតែឃើញវៀតណាមមកចូលពួនជម្រុកស្រូវៗ

ហើយអត់ប៉ានចេញក្រៅទេ ។

**ស៖** ខ្ញុំសូមនិយាយត្រឡប់ទៅវិញ នៅពេលដែលឈ្លបបានបាញ់ទៅលើប្រពន្ធរបស់លោកអ៊ំខ្ញុំយល់នូវអ្វីដែលលោកអ៊ំ បានរៀបរាប់ ។ ប៉ុន្តែខ្ញុំត្រូវការបំភ្លឺ នៅពេលដែលប្រពន្ធរបស់គេត្រូវបានគេសម្លាប់ហើយនិងនៅពេលដែលកូនរបស់លោកត្រូវបានគេសម្លាប់នោះ តើវានៅពេលនោះមែនទេ ដែលឈ្លបនោះបាញ់?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ពេលហ្នឹងគឺថាកូនហ្នឹងនៅនុំង យំនៅនុំង តែខ្ញុំរត់ចេញទៅឆ្ងាយទៅ វាមិនដឹង វានៅយំទៀតអីក៏មិនដឹង ខ្ញុំក្តាប់អត់បានដែរ ។

**ស៖** សូមអរគុណ ។ ហើយខ្ញុំនឹងត្រឡប់ដោយខ្លីៗឡើងវិញ ទាក់ទងទៅនឹង សេអ៊ីអា និង កាហ្សេបេ លោកអ៊ំបានប្រាប់ថា លោកអ៊ំបានឮពាក្យហ្នឹងពីមុន ប៉ុន្តែលោកអ៊ំអត់ដែលយល់ថា តើវាមានន័យយ៉ាងម៉េចនោះទេចំពោះពាក្យ សេអ៊ីអា និង កាហ្សេបេ នោះ តើត្រឹមត្រូវដែរឬទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកស្រី! ពិតមែនទាន ។

**ស៖** សូមអរគុណ ។ ហើយចំណុចចុងក្រោយលោកអ៊ំ បាននិយាយថា ឃើញក្មេងពីរនាក់នៅពេលដែលលោកអ៊ំចេញពីស-២១ ហើយលោកអ៊ំបានដឹងថា ជាកូនរបស់មនុស្សម្នាក់ តើលោកអ៊ំស្គាល់ឪពុកម្តាយរបស់កូនក្មេងទាំងពីរនាក់នោះដែរឬទេ? តើឪពុកម្តាយទាំងពីរត្រូវបានគេឃុំនៅ ស-២១ ដែរឬទេ? ឬក៏ថាតើលោកអ៊ំដឹងឈ្មោះឪពុកម្តាយនោះតាមរបៀបណា?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ក្មេងនោះ គឺថាខ្ញុំបាទមិនដឹងជារស់នៅរបៀបណាទេ តែពេលដែលខ្ញុំទៅធ្វើការនៅក្រោយហ្នឹង ក្មេងហ្នឹងវាតែងតែចេញទៅរាល់ថ្ងៃអ៊ីចឹង ចេញទៅរកបបរហូបនៅក្រោយហ្នឹង គឺថាពេលយប់មិនដឹងវាដេកពួននៅឯណាទេ? អាហ្នឹងខ្ញុំបាទអត់ដឹងទេ ។ ប៉ុន្តែ ពេលខ្លះគឺថាទៅហើយ ម៉ោងប្រាំបីព្រឹកអីហ្នឹង វាទៅរាល់ថ្ងៃអ៊ីចឹង តែដល់នេះខ្ញុំសួរអ្នកបបរហ្នឹង ឈ្មោះមិត្តសុះ ៗហ្នឹង អ្នកបបរបាយហ្នឹង សួរថា មិត្តនារី កូនពីណាទេហ្នឹង? ហើយវានិយាយប្រាប់ថាកូនហ្នឹងហើយ កូនលោកតា ចេង អន នោះ វាប្រាប់ខ្ញុំអ៊ីចឹង ។

**ស៖** ថាតើតា ចេង អន គឺជាសមាជិកនៃបុគ្គលិកនៅទីនោះ ឬក៏គាត់ហ្នឹងជាអ្នកទោសនៅ ស-២១ ដែរ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកស្រី! ខ្ញុំបាទ អត់បានដឹង ចេង អន ហ្នឹងជាស្អីទេ? ខ្ញុំអត់បានដឹងទេទាន ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយច៍៖**

សូមអរគុណច្រើន ។ លោកប្រធានខ្ញុំអត់មានសំណួរអីទៀតទេ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រមមានសំណួរទេ! សូមអញ្ជើញលោកចៅក្រម ហ្សង់ម៉ាក់ ។

**សួរដោយចៅក្រម ហ្សង់ម៉ាក ឡាវែន៖**

**ស៖** សូមជម្រាបសួរលោក ជុំ ម៉ី លោកសាក្សី ។ ប្រសិនបើខ្ញុំយល់ច្បាស់អំពីចម្លើយរបស់លោក លោកបាននិយាយថា លោកមិនបានដឹង លោកមិនស្គាល់ជនជាប់ចោទទេ នៅពេលដែលលោកត្រូវបានជាប់ឃុំឃាំងនៅ ស-២១ ។

តើនេះជាសម្ដីពិត ដែលលោកបានបញ្ជាក់មែនឬទេ? តើលោកបានជួបជនជាប់ចោទទេនៅពេលនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំអត់បានជួបជនជាប់ចោទណាទេ ខ្ញុំអត់ដែលបានជួប អត់បានស្គាល់ទេ គ្រាន់តែដឹងឮតាមខ្ញុំសួរ មិត្តសុះ ហ្នឹងថាកូនពីណា? ថាកូនលោកតា ចេង អន គ្រាន់តែប៉ុណ្ណឹងទេ ។ ហើយដល់ពេលយើងបែកទួលស្លែងហើយហ្នឹង អាក្មេងហ្នឹងវានៅក្រៅរបង ក្មេងហ្នឹង គេបិទរបងទៅ ក្មេងហ្នឹងនៅក្រៅរបងនៅកន្លែងបបរបាយហ្នឹង ។ តែថ្ងៃក្រោយទៅ ខ្ញុំសួរស៊ើបសួរទៅគេថាកូនហ្នឹងចូលក្នុងគំនរខោអាវ ។ ខ្ញុំបានដឹងតែប៉ុណ្ណឹងទេ ជម្រាបលោកចៅក្រម ។

**ស៖** ខ្ញុំក៏បានយល់ដែរថា លោកបាននិយាយថា នៅពេលដែលគេចាប់ខ្លួនលោក ភ្លាមនោះគេបានប្រព្រឹត្តមិនល្អមកលើរូបលោក ហើយគេបានថតរូបលោក ហើយគេសុំឲ្យលោកធ្វើប្រវត្តិរូប ហើយបន្ទាប់មកគេនាំចូលទៅក្នុងកន្លែងឃុំខ្លួនម្នាក់ៗតូច ។ តើនេះជាចំណុចដែលលោកបានបញ្ជាក់ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! មុនគេយកទៅកន្លែងឃុំឃាំងហ្នឹង គឺថាគេសម្រាតខោអាវអស់ហើយនៅតែខោខ្លីទេ ។ គេយកទៅដាក់កន្លែងមន្ទីរឃុំឃាំង គេរៀបឥដ្ឋហ្នឹងទាន ។ ពេលនុំងគេយកទៅដាក់អាកន្លែងរៀបឥដ្ឋហ្នឹង ពេលហ្នឹងដាក់ច្រវាក់នៅហ្នឹង ដាក់ច្រវាក់នៅហ្នឹងហើយបានគេដោះខ្នោះដៃចេញ ដោះខ្នោះដៃចេញបានគេស្រាយមុខចេញ ។

**ស៖** តើលោកអាចជម្រាបតុលាការបានទេ ថាតើមានសេចក្ដីសង្ខេបរៀបរាប់ដោយសង្ខេបអំពីកន្លែងឃុំខ្លួនបន្ទប់ឃុំខ្លួនត្រឹមម្នាក់ឯង ថាតើលោកអាចទម្រេតដេកបាន? ថាតើមានអ្នកជាប់ឃុំនៅជិតលោកដែរឬទេ? តើលោកអាចរៀបរាប់អំពីទីតាំង ឬកន្លែងឃុំខ្លួនតូចហ្នឹង ឲ្យតុលាការជ្រាបបានទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! គឺថាក្នុងកន្លែងទីតាំងហ្នឹង គឺថាពេលគេនេះយើង ដាក់យើងនៅហ្នឹង គឺថាគេឲ្យដេកខ្លួនទទេ នៅនឹងឥដ្ឋហ្នឹងតែម្តង ឲ្យដេកនៅនឹងឥដ្ឋហ្នឹង ។ ហើយគេប្រាប់យើងថា អាកែសគ្រាប់ហ្នឹងសម្រាប់បត់ជើងធំ ហើយកាដុងគេឲ្យយើងបត់ជើងតូចនៅកន្លែងហ្នឹង ។ ហើយពេលនៅក្នុងហ្នឹង គេមិនឲ្យយើងនិយាយឡូឡាអីទេ យើងសួរអ្នកជិតខាងបន្ទប់ជាប់គ្នាហ្នឹង ក៏អត់ឲ្យមានការនិយាយស្តីរកគ្នាដែរ ។ ហើយពេលអាគេដាក់ច្រវាក់ជើងយើងហ្នឹង គេប្រាប់យើងថា បើកាលណាប្រែខ្លួនឲ្យសុំគេ បើយើងអត់បានសុំគេវ៉ៃយើងពីររយរំពាត់ ។

[១១:២៣:៤៣]

**ស៖** លោកបានស្ថិតនៅក្នុងបន្ទប់ឃុំខ្លួនតូចហ្នឹង គឺថានៅពេលដែលគេសួរចម្លើយលោកទាំងអស់នោះឬទេ? តើពេលដែលសួរចម្លើយនោះ គេយកទៅដាក់ក្នុងបន្ទប់ឃុំខ្លួនរួម ឬក៏នៅក្នុងបន្ទប់សម្រាប់ម្នាក់ៗនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ពេលនោះគឺថាគេយកមកដាក់ អាបន្ទប់ម្នាក់ៗហ្នឹង ពេលកំពុងសួរចម្លើយហ្នឹង គេយកមកដាក់តែបន្ទប់ម្នាក់មួយៗហ្នឹងទេ ។ ដល់សួរចម្លើយចប់ទៅបានគេយកទៅដាក់ឯលើ ជាន់ឯលើហ្នឹង អាហ្នឹងបន្ទប់រួម អាហ្នឹងគឺថាខ្នោះវែងៗហ្នឹង គេដាក់រួមនៅហ្នឹងដាក់ជើងទាំងអស់គ្នាហ្នឹង ។ ពេលនុ៎ងគឺថា លោកតា ឌី ផុន ពេទ្យធ្មេញ គាត់នៅជាប់ជាមួយខ្ញុំដែរ ពីរនាក់លោកតា ឌី ផុន ហ្នឹង ។

**ស៖** នៅពេលដែលលោកនៅក្នុង ឃុំនៅក្នុងបន្ទប់រួមដែលគេមកសួរ ថាតើមានជាង អ្នកណាចេះធ្វើជាងទេ? តើគេសួរអ្វីទៀតមុនពេលដែលគេ មុនពេលដែលទៅសួរនៅបន្ទប់រួមតើមានគេសួរអ្វីដែរទេមុនហ្នឹង?

**ឆ៖** ជម្រាបប្រសាសន៍លោក! មុនគេយកទៅដាក់អាបន្ទប់រួមហ្នឹង គឺថាខ្ញុំអង្គាល់ពីមុននៅបន្ទប់តែម្នាក់ឯងទេ ដល់គេសួរចប់ចម្លើយហ្នឹងទៅ បានគេសួរថា អាណាអ្អែងមកពីកន្លែងកាត់ដេរហ្នឹង អ្អែងចេះធ្វើម៉ាស៊ីនដេរទេ? ហើយខ្ញុំឆ្លើយថា ខ្ញុំចេះបង ។ ដល់ហើយ មិត្តធី ហ្នឹងថាអើ អ្អែង ស្អែកហ្នឹង អ្អែងចេញធ្វើការណ៎ា អញយកខោអាវឲ្យអ្អែងស្លៀកពាក់ ។ ក៏ប៉ុន្តែអ្អែងកុំរត់ អ្អែងតែរត់បាញ់ចោលហើយ ។ អ៊ីចឹង ខ្ញុំប្រាប់ថា ខ្ញុំអត់រត់ទេបង ។ ព្រលឹមឡើង គេយកខោអាវមកឲ្យស្លៀកពាក់មែន ។

**ស៖** តើលោកអាចជម្រាបយើងបានទេ (សុំទោស)នៅក្នុងបន្ទប់ឃុំខ្លួនរួមនៅជាន់ទីពីរ ឬជាន់ទីបីនៃអគារ តើបន្ទប់រួមនោះនៅជាន់ខាងលើឬ តើស្ថិតនៅកន្លែងណា? គឺនៅជាន់ទីប៉ុន្មាននៅក្នុងអគារនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោក! គឺថាគេយកទៅដាក់ជាន់លើបំផុតនោះ អាជាន់ទីបី គេយកទៅដាក់ជាន់លើបំផុត ។ អាជាន់ទីមួយ មានអាបន្ទប់រៀបឥដ្ឋហ្នឹង ហើយអាជាន់ទីពីរ មានអាបន្ទប់ឈើ បាទមានអាបន្ទប់ឈើ គេវៃបន្ទប់ឈើអ៊ីចឹង ។ ហើយអាជាន់ទីលើបំផុត អាហ្នឹងអត់មានទេ អាហ្នឹងគេដាក់រួម ដាក់ខ្នោះវែងៗ គេដាក់ខ្នោះរួមតែម្តង ។

**ស៖** នៅក្នុងបន្ទប់ឃុំខ្លួនរួមនោះ តើមានក្តារខៀនដែលមានសរសេរវិន័យ ឬក៏ការណែនាំអី ដែលថាអ្នកទោសត្រូវតែគោរពដែរឬទេ?

[១១:២៧:៤២]

**ឆ៖** ជម្រាបប្រសាសន៍លោក! ដាក់អាបន្ទប់រួមហ្នឹងអត់មានក្តារខៀនអីទេ អត់មានទេ ។

**ស៖** ថាតើអ្នកជាប់ឃុំទាំងអស់ ដែលនៅក្នុងបន្ទប់រួម តើគេស្ថិតនៅក្នុងលក្ខខណ្ឌដូចគ្នានឹងរូបលោកដែរឬទេ? ដែលថាគេអាចនឹងត្រូវចេញទៅធ្វើការ ដូចរូបលោកសម្រាប់ឱ្យស-២១ ឬពួកគេអ្នកនៅក្នុងបន្ទប់រួមនោះ សុទ្ធតែជាអ្នកជាប់ឃុំ គឺត្រូវតែជាប់ខ្នោះនៅទីហ្នឹងរហូត?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ខ្ញុំមិនបានដឹងថាគេនៅហ្នឹងរហូត ឬក៏យ៉ាងណាទេ ។ ក៏ប៉ុន្តែដល់យើងចូលមកពេលល្ងាចហ្នឹង គឺថាឃើញមកជុំគ្នាអ៊ីចឹង ជាប់ខ្នោះជើងហ្នឹងទាំងអស់គ្នាហ្នឹង បាទ ។ ហើយអាពេលជាប់ខ្នោះនៅហ្នឹងទាំងអស់គ្នាហ្នឹង ដល់ហើយខ្ញុំមានលួចសួរអ្នកនៅជាប់ជាមួយគ្នាហ្នឹង សួរថាម៉េចឡានហ្នឹងមកធ្វើអីពេលថ្មើរហ្នឹង? ហើយគេខ្សឹបប្រាប់ថា កុំមាត់ ឡានហ្នឹងមកយកពួកយើងទៅវៃនៅព្រៃស យកទៅសម្លាប់នៅ អ៎!នែ បឹងជើងឯក យកទៅសម្លាប់នៅបឹងជើងឯកហើយ កុំមាត់ ។ គេគ្រាន់តែប្រាប់ខ្ញុំប៉ុណ្ណឹងទេ ។ យកទៅបឹងជើងឯកហ្នឹង គឺថាខ្ញុំបានស្តាប់តាមអ្នកជាប់ឃុំឃាំងជាមួយគ្នានៅហ្នឹង ។

**ស៖** គេបានឃុំខ្លួនលោកនៅក្នុងបន្ទប់រួមនោះ រហូតទាល់តែគេដោះចេញពីស-២១ ឬក៏លោកមានទទួលការឃុំខ្លួន ឬក៏របបឃុំខ្លួនណាមួយផ្សេងពីកន្លែងហ្នឹងដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! អត់មានកន្លែងណាខុសពីកន្លែងហ្នឹងទៀតទេបាទ ។

**ស៖** នៅក្នុងអំឡុងពេលដែលគេឃុំខ្លួនលោកជាច្រើនខែនោះ តើលោកអាចឱ្យពន្យល់ដល់យើងថាតើនៅក្នុងបន្ទប់រួមហ្នឹងលក្ខខណ្ឌដូចម្តេច? ថាតើលោកកត់សម្គាល់ឃើញថាអ្នកទោសទាំងឡាយត្រូវបានគេយកចេញទៅដោយអ្នកយាម ដោយមានជាប់ច្រវាក់ផង ឬក៏អ្នកទោសដដែលៗនៅជាមួយលោកនៅកន្លែងហ្នឹងក្នុងរយៈពេលដែលលោកនៅនោះ?

**ឆ៖** បាទ, នៅពេលនោះគឺថា អត់មាននេះទេ គឺថាអ្នកដែលនេះហ្នឹងគឺថាប្លែកៗគ្នាតែម្តង អត់មានដាក់នៅហ្នឹងរួមទេ មួយយប់អ៊ីចឹង ឃើញអ្នកនោះផ្សេងទៅ មួយយប់ឃើញអ្នកនោះផ្សេងទៅ ។ ពេលគេយកមកដាក់អាបន្ទប់រួមហ្នឹង ពេលហ្នឹងនៅភ្លឺនៅឡើយទេ តែខ្ញុំមើលទៅគេទើបយកមកហ្នឹងគឺថាខោអាវគាត់ប្រឡាក់ភក់ទាំងអស់តែម្តង សុទ្ធតែភក់យកមកដាក់នៅជិតខ្ញុំហ្នឹង ។

**ស៖** តើលោកដឹងដែរឬទេថាតើអ្នកដែលជាប់ឃុំរួមជាមួយលោក តើគេមានរឿងអ្វីកើតឡើងចំពោះគេមុនពេលដែលចប់ប្រតិបត្តិការនៅស-២១។ តើអ្នកទាំងអស់ហ្នឹងចាកចេញទៅដោយសុវត្ថិភាព ឬក៏តើក្នុងចំណោមអ្នកដែលជាប់ឃុំរួមជាមួយនឹងលោកហ្នឹង តើជោគវាសនារបស់ពួកគេនេះយ៉ាងដូចម្តេច តើលោកដឹងទេ?

[១១:៣២:០១]

**ឆ៖** បាទ,ជម្រាបប្រសាសន៍លោក! គឺថាពេលទៅហ្នឹង គឺថាទៅខ្លះក៏បានត្រលប់មកក្រោយវិញខ្លះក៏បានទៅរហូតទៅដល់អមលាំងហ្នឹង ។ អ្នកដែលខ្ញុំដឹងច្បាស់ហ្នឹង គឺថា តាតួន ជាងធ្វើនាឡិកាហ្នឹងគឺថាស្លាប់ហើយ ។ ហើយតា ឌី ផុន ដែលនេះហ្នឹង ក៏គាត់ស្លាប់ដែរ ។ តា ឌី ផុន ដែលធ្វើធ្មេញហ្នឹងក៏គាត់ស្លាប់ដែរ ។

**ស៖** នៅពេលដែលលោកនិយាយថា ពួកគេបានស្លាប់នោះ តើពួកគាត់ស្លាប់នៅស-២១ ឬក៏ស្លាប់ក្រោយពេលហ្នឹងទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកថា ស្លាប់ទៅខាងអមលាំង ។ តាមខ្ញុំដឹងខាងជនជាប់ចោទហ្នឹងក៏គាត់មានលើកឡើងដែរ ម៉្យណោះហ្នឹងគឺថាតា ឌី ផុន ហ្នឹងគាត់ស្លាប់ហើយ ស្លាប់ដោយជំងឺ ។

**ស៖** តើលោកគិតថា តើមានមនុស្សចំនួនប៉ុន្មាននៅក្នុងកន្លែងឃុំខ្លួន ដែលនៅដែលគេឃុំខ្លួននៅក្នុងបន្ទប់រួមហ្នឹង តើមានចំនួនប៉ុន្មាននាក់?

**ឆ៖** នៅក្នុងបន្ទប់រួមហ្នឹង បើតាមខ្ញុំមើលប៉ាន់ស្មានប្រហែលជាសែសិបនាក់ទាន នៅក្នុងបន្ទប់រួមហ្នឹងប្រហែលសែសិបនាក់ ។

**ស៖** តើលោកអាចជម្រាបតុលាការបានទេ ថាតើរោងជាងដែលលោកធ្វើការជួសជុលនោះស្ថិតនៅកន្លែងណាដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! រោងជាង ដែលខ្ញុំនៅជួសជុលនោះ នៅក្នុងក្រោយនេះហ្នឹងទៀត នៅខាងក្រៅរបង ព្រោះអាអង្គាល់មុនហ្នឹង មានរបងស្កាត់មួយកន្លែងហ្នឹងនៅខាងក្រោយ

ហ្នឹង ។ ហើយដល់រោងជាងហ្នឹង នៅខាងក្រោយហ្នឹងមានដីវាលធំ ហើយប្រក់ស័ង្កសីពីលើ ក៏ប៉ុន្តែអត់មានជញ្ជាំង អត់មានអីទេ គឺថាមានកន្លែងគេដាក់ខោអាវ ដែលគេយកអ្នកទោសទៅវ៉ៃនៅបឹងជើងឯកហើយ អាខោអាវហ្នឹង គេយកមកវិញ ។

ហើយដល់នេះអ៊ីចឹងទៅ មានបន្តមកទៀត មានកន្លែងបបរបាយ មានខ្ទះធំៗបបរបាយ ។ ហើយបន្ទាប់មកគឺថាកន្លែងខ្ញុំជួសជុលម៉ាស៊ីន ។ ហើយបន្ទាប់មកទៀត កន្លែងតា គង់ នេះគាត់ តាគង់ហ្នឹង គាត់ជាងឈើៗ ។ គាត់ជួសជុលឈើកៅអី ធ្វើអីៗ នៅជិតហ្នឹង។

ហើយបន្ទាប់មក ទៀតមានកន្លែងគេចិញ្ចឹមទន្សាយ ចិញ្ចឹមមាន់ចិញ្ចឹមជ្រូកស៊ីៗ គេតែងតែយកបាយជ្រូកឱ្យជ្រូកស៊ីហ្នឹង ។ ហើយខ្ញុំបាទចេះតែអង្គុយ ធ្វើម៉ាស៊ីនដេរនៅខាងជិតហ្នឹងដែរហ្នឹង ឃើញគេសែងមនុស្សយកទៅកប់ ក្រោមដើមអំពិលបារាំង នៅជិតកន្លែងហ្នឹងដែរ ។ សែងទៅហ្នឹងអត់មានដាក់អា*ហ្វ្រង់កា* អត់ មានស្អីទេ គេយកស័ង្កសី គេវ៉ៃជាប់គ្នាទៅ ដល់ហើយគេសែងធ្វើដូច*ហ្វ្រង់កា* អ៊ីចឹង យកទៅកប់ក្រោម ដើមអំពិលបារាំងហ្នឹង ហើយក្រោមដើមអំពិលបារាំងហ្នឹង នៅពីមុខខ្ញុំធ្វើម៉ាស៊ីនដេរហ្នឹង ។

**ស៖** ដូច្នេះបើសិនជាខ្ញុំយល់ការពន្យល់របស់លោកហ្នឹងគឺថា អ៊ីចឹងកន្លែងរោងជាងហ្នឹងមិនស្ថិតនៅក្នុងបរិវេណធំនៃស-២១ គឺនៅខាងក្រោយបរិវេណដែលមានអគារនោះ ។ អ៊ីចឹងលោកបានបញ្ជាក់ថា មិនមានជញ្ជាំងទេ មានតែដំបូលកន្លែងរោងជាងហ្នឹង ?

**ឆ៖** ពិតអ៊ីចឹងមែនហើយលោកចៅក្រម! អត់មានដំបូលទេ-- អត់មានជញ្ជាំងទេ ខមាទោស អត់មានជញ្ជាំងទេ។

**ស៖** នៅពេលដែលលោកធ្វើការនៅកន្លែងរោងជាងនោះ តើលោក តើមានអ្នកយាម យាមជាប្រចាំដើម្បីមើលលោកធ្វើការទេ? ឬលោក តើមានការផ្លាស់ប្តូរអ្នកយាម? តើគេចាត់វិធានការអ្វីចំពោះលោក? តើលោកមានសេរីភាពអ្វីខ្លះទ ដូចជាសេរីភាពដើរឬក៏និយាយអីបន្តិចបន្តួចនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! យើងអត់មានដើរហើរបានទេពេលហ្នឹង គឺថាយើងនៅកន្លែងណា ធ្វើការកន្លែងហ្នឹងតែម្តង អត់មានដើរ អើដើរបត់ជើងតូចអីបាន ដើរចុះឡើងតិចតួចជិតៗហ្នឹង ហើយមានគេយាមនៅហ្នឹង មានឈ្មោះ មិត្តចាប នៅយាមនៅហ្នឹង។

**ស៖** តើមានមនុស្សប៉ុន្មាននាក់ធ្វើការជាមួយលោកនៅកន្លែងរោងជាងនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! នៅនុ៎ងមាន តាប៊ិច ហើយតាគង់ ខ្ញុំបាទ ហើយនិងតាឌីផុន ហ្នឹង។ មានប្អូននាក់ ប្រាំនាក់មិនដឹង? មានប្អូននាក់ មើលលោកប៊ិច, តាឌីផុន, តាគង់, ខ្ញុំ, ប្អូននាក់ទាន ។

[១១:៣៨:៥២]

**ស៖** ដូច្នេះ តើអ្នកទោសទាំងនោះទទួលជោគវាសនាដូចម្តេច? តើនៅពេលដែលគេរំដោះ ស-២១ តើគេទៅណា? តើគេនៅទីហ្នឹងរហូតដល់ពេលដែលបិទស-២១ ឬយ៉ាងដូចម្តេច?

**ឆ៖** ជម្រាបលោកចៅក្រម! ពេលនុ៎ងគឺថា អ្នកពីរនាក់ពេលនុ៎ងត្រឡប់មកវិញ ។ ហើយចំពោះរឿងតាតួនហ្នឹង ហើយនិងតាឌីផុន ហ្នឹងអត់ឃើញត្រឡប់មកវិញទេ ។ នៅសល់ពីរនាក់ នៅសល់លោកប៊ិច ហើយនិង តាគង់ ត្រឡប់មកវិញទាន ។ តែឥឡូវហ្នឹងគាត់ តាគង់ ហើយនិងលោក ប៊ិច គាត់ស្លាប់បាត់អស់ហើយ ទើបស្លាប់ក្រោយហ្នឹងទេទាន ។

**ស៖** នៅពេលដែលលោកនិយាយថា អ្នកទោសពីរនាក់ដែលមិនបានត្រឡប់មកវិញនោះ តើលោកមានន័យថា គេបាត់ខ្លួនដោយសារតែគេយកចេញទៅដោយពួកអ្នកយាមស-២១ ឬក៏ពួកគេរស់នៅកន្លែងណាមួយមិនបានត្រឡប់វិញ ដោយសារថាលោកមិនដឹងដំណឹងពីគេ ហើយក៏ថាមិនបានត្រឡប់មកវិញនោះ ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំអត់បានដំណឹងពីអ្នកណាទេ តែខ្ញុំឮសួរជនជាប់ចោទគាត់ប្រាប់ថា តាឌីផុន គាត់ស្លាប់ហើយ ។ ហើយនិង តាតួន នេះ គឺថាខ្ញុំសួរអ្នកវិលត្រឡប់មកវិញហ្នឹង គឺថាស្លាប់អស់ដែរ ។

**ស៖** លោកអ៊ំបានជម្រាបជូនយើងខ្ញុំថា លោកអ៊ំអាចរកផ្លូវទៅតាមព្រៃស ។ នៅក្នុងពេលដែលលោកអ៊ំនៅស-២១ តើលោកអ៊ំទទួលបានព័ត៌មានផ្សេងៗ ទាក់ទងទៅនឹងអំពីប្រពន្ធរបស់លោក និងគ្រួសាររបស់លោកអ៊ំដែរឬទេ? ហើយថាតើលោកអ៊ំពិតជាបានស្វែងរក និងរកឃើញនូវគ្រួសាររបស់លោកអ៊ំវិញ ដែលមានការរស់រានមានជីវិតនៅពេលនោះ ឬយ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! ពេលនោះគឺថា ខ្ញុំបាទអត់បានទំនាក់ទំនងអីជាមួយនឹងគ្រួសារដែលគេយកទៅដាក់គុកនៅព្រៃសហ្នឹងទេ អត់បានទំនាក់ទំនងគ្នាទេ លុះត្រាតែយើងចេញពីទួលស្លែងទៅហ្នឹង គឺថាជួបដោយចៃដន្យត្រង់ម្តុំចម្ការឪឡឹក ពេលដែលវៀតណាមបាញ់ផ្តាច់ហើយនឹងគឺថាជួបនៅនុ៎ង ។

**ស៖** ខ្ញុំដឹងថា លោកអ៊ំត្រូវបានសួរសំណួរច្រើន ហើយមានការឈឺចាប់ណាស់ ប៉ុន្តែខ្ញុំសូមឲ្យធ្វើការបំភ្លឺនៅក្នុងចំណុចនេះ ។ លោកអ៊ំជួបប្រពន្ធនិងកូនសាជាថ្មី ហើយមានការបាញ់និងការវាយប្រហារកើតឡើងនៅពេលដែលលោកអ៊ំជួបនោះ គឺមានការវាយប្រហារកើតឡើងពីឡានរបស់វៀតណាម ហើយនៅពេលនោះលោកអ៊ំ ត្រូវបានបំបែកចេញពីប្រពន្ធរបស់លោកអ៊ំ ហើយមិនទទួលបានដំណឹងពី មិនដែលទទួលបានដំណឹងអំពីប្រពន្ធ និងកូននោះទេ ។ ថាតើលោកអ៊ំជួបប្រពន្ធរបស់លោកអ៊ំ ក្រោយពីការមានបាញ់បោះពីវៀតណាមឡើងវិញ ឬក៏យ៉ាងម៉េច?

[១១:៤៣:២៥]

**ឆ៖** ជម្រាបប្រសាសន៍លោកចៅក្រម! គឺថាពេលដែលខ្ញុំចេញៗ ពីទួលស្លែងទៅហ្នឹងគឺថាពេលហ្នឹងចេញដំណើរទៅហ្នឹងស្រាប់តែទៅនៅព្រៃស មួយសន្ទុះធំទៀបភ្លឺបានធ្វើដំណើរទៅទៀត ។ ធ្វើដំណើរទៅស្រាប់តែដើរទៅភ្លឺនៅអង្គស្នួល ។ ទៅដល់អង្គស្នួលហ្នឹង គឺថាជួបគ្រួសារខ្ញុំនៅនុ៎ងៗ គឺថាទើបនឹងឆ្លងទន្លេបានពីរខែៗ ព្រោះគ្រួសារខ្ញុំហ្នឹង ក៏គេឲ្យធ្វើដំណើរទៅអមលាំងដែរមានស្រីៗប្អូនប្រាំនាក់ ឲ្យធ្វើដំណើរទៅអមលាំងហ្នឹងគឺថា ក៏ខ្ញុំសុំគេជួយបីកូនទៅគេថា អើ!ជួយបីកូនទៅ ក៏ធ្វើដំណើរឆ្លងកាត់ថ្នល់ ឆ្លងកាត់ថ្នល់ទៅខាងជើងហ្នឹង ត្រង់កន្លែងអង្គស្នួលហ្នឹងកំពុងតែឆ្លងកាត់ថ្នល់ស្រាប់តែឃើញឡានវៀតណាមពីរឡានមក ឡានអា*ហ្សេអឹមសេ* សុទ្ធតែទាហាន ។ ដល់ហើយក៏បាញ់គ្នាជាមួយពួកខ្មែរក្រហមទៅ បាញ់គ្នាព្រុសប្រាសៗទៅ ដល់ហើយមួយកំណាត់ត្រឡប់មកក្រោយវិញ មួយកំណាត់ឡើងទៅហួសទៅ ហើយវាស្រែកថា មកពួកយើងទេៗ ហើយក៏ខ្ញុំនាំប្រពន្ធខ្ញុំដើរ ចេះតែដើរទៅ ហើយវៀតណាមចេះតែបាញ់ទៅ ។ ហើយពួកអស់នោះដល់ឃើញវៀតណាមបាញ់អ៊ីចឹង ក៏នាំគ្នារត់ទីណាត់ទីណែងអស់ទៅ គេរត់ទៅបាត់អស់ទៅខ្ញុំនៅជាមួយគ្រួសារខ្ញុំ ហើយតាអេង បីនាក់ហ្នឹងចេះតែដើរកុបៗ ទៅគេឲ្យទៅសំដៅទៅអមលាំង មិនដឹងអមលាំងនៅឯណាផង ចេះតែដើរទៅហ្នឹង ។

**ស៖** តើលោកអ៊ំអាចជម្រាបយើងខ្ញុំបានដែរឬទេ ថាចំនួនគ្រួសារពីសមាជិក ចំនួនសមាជិកគ្រួសាររបស់លោកអ៊ំ ដែលបានស្លាប់នៅក្នុងសម័យកម្ពុជាប្រជាធិបតេយ្យ? លោកអ៊ំនិយាយអំពីកូនប្រុសដែលស្លាប់ក្នុងពេលដែលជម្លៀសភ្នំពេញ ហើយថាតើសមាជិករបស់លោកអ៊ំផ្សេងទៀតបានស្លាប់ក្នុងពេលជន្លៀសនោះដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! កូនខ្ញុំបាន ខ្ញុំបានតែកូនមួយមុនដំបូងដែលកប់នៅព្រៃកក្តាមមួយ ហើយៗនៅកូនបងពីរនាក់ កូនស្រីបងពីរនាក់ ។ ដល់ក្រោយមកបានមកធ្វើការ នៅអូរឫស្សីហ្នឹងគឺថា

កូនស្រីហ្នឹងគេឲ្យរៀនដេរ រៀនអីនៅអូរឫស្សីហ្នឹង កូនស្រីពីរនាក់ហ្នឹង ។ ដល់វេលាបែកភ្នំពេញហ្នឹងទៅ វៀតណាមចូលមកទៅ ស្រាប់តែកូនស្រីហ្នឹងទៅបាត់ទៅ ខ្ញុំអត់ដឹងថាទៅណាមកណាទេ ។ អ៊ីចឹងកូន ខ្ញុំប្អូននាក់ហ្នឹង គឺខ្ញុំនឹកថា គឺថាបាត់បង់ជីវិតអស់ហើយអត់មាននៅរស់ទេ កូនប្អូននាក់ហ្នឹងព្រមទាំង ប្រពន្ធមួយទៀត ។ គ្រួសារខ្ញុំប្រាំនាក់ហ្នឹងអស់រលីង ។ ហើយបើនិយាយពីអារឿងគ្រួសារ នៅឯស្រុក វិញ ខ្ញុំពេលនោះខ្ញុំទៅដល់ស្រុក គឺថាបីគ្រួសារហ្នឹងគឺថាទៅខាងពោធិសាត់ហ្នឹង បីគ្រួសារ ត្រឡប់មក វិញបានតែពីរនាក់ទេ គឺថាអស់រលីងហើយនេះ ។

**ស៖** សូមអរគុណលោកអ៊ំ ជុំ ម៉ី ច្រើននូវអ្វីដែលលោកអ៊ំបានផ្តល់ចម្លើយ ។ ខ្ញុំអត់មានសំណួរ ផ្សេងទៀតនោះទេ ។ សូមអរគុណ។

**ប្រធានអង្គជំនុំ៖**

អស់លោកចៅក្រមផ្សេងទៀត តើមានសំណួរអ្វីត្រូវសួរដល់អ៊ំ ជុំ ម៉ី ដែរឬទេ? បើមានសូម អញ្ជើញ ។ បើមិនមានទេ អង្គជំនុំជម្រះ ដោយសារដល់ពេលត្រូវសម្រាកពិសាអាហារថ្ងៃត្រង់ហើយ អង្គជំនុំជម្រះប្រកាសសម្រាក ដើម្បីពិសារអាហារថ្ងៃត្រង់ ហើយអង្គជំនុំជម្រះនឹងបន្តដំណើរការ សវនាការនៅវេលាម៉ោងមួយកន្លះរសៀលនេះ ។

មន្ត្រីតុលាការសម្របសម្រួលដល់អ៊ំ ជុំ ម៉ី ដើម្បីឲ្យគាត់បានកន្លែងសម្រាកសមរម្យ ។ ហើយ បង្គាប់ទៅអនុរក្សមន្ទីរឃុំឃាំង ឲ្យនាំជនជាប់ចោទ ទៅកាន់បន្ទប់រង់ចាំ ហើយឲ្យនាំគាត់ត្រឡប់មកកាន់ សាលសវនាការវិញនៅរសៀលនេះ ឲ្យបានមុនម៉ោងមួយនិងសាមសិបនាទី ។

*[សវនាការសម្រាកពីម៉ោង ១១:៥០ នាទី ដល់ម៉ោង ១៣:៣២ នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការ ។

មុននឹងប្រគល់វេទិកានេះជូនទៅតំណាងសហព្រះរាជអាជ្ញា អង្គជំនុំជម្រះសូមជម្រាបជូនដំណឹង ដល់ភាគីថា ដោយមានការផ្លាស់អំពីកាលវិភាគក្នុងការស្តាប់សាក្សីដែលត្រូវមកធ្វើសក្ខីកម្មចំពោះមុខអង្គ ជំនុំជម្រះពីភាគីមួយចំនួននោះ គឺអង្គជំនុំជម្រះសូមជម្រាបថា អង្គជំនុំជម្រះមានផែនការដាក់លាក់នៅ ក្នុងការធ្វើកាលវិភាគសម្រាប់ដំណើរការសវនាការចាប់ពីសប្តាហ៍ទីពីរនៃខែកក្កដានោះ យើងនឹងរៀប

រយជាក់លាក់ ។ យើងមានការរង់ចាំក្នុងការសម្រេចជ្រើសរើសយកសាក្សីដែលត្រូវមកស្តាប់ ផ្តល់សក្ខីកម្មនៅចំពោះមុខអង្គជំនុំជម្រះ នៅក្នុងនោះយើងបានសម្រេចរួចហើយ នៅតែសាក្សីKW-24 ប៉ុណ្ណោះ។ ដោយកាលពីម្សិលមិញ អង្គជំនុំជម្រះបានជម្រាបទុកលទ្ធភាពជូនខាងតំណាងសហព្រះរាជអាជ្ញា ដើម្បីលោកធ្វើការកត់សម្គាល់អំពីការប៉ុនប៉ងរបស់អង្គជំនុំជម្រះក្នុងការដកចេញនូវសាក្សី KW-24 នេះមួយទៀត ។ អ៊ីចឹង បើសម្រេចលើសាក្សីរូបនោះហើយ អង្គជំនុំជម្រះនឹងចេញនូវកាលវិភាគជាក់លាក់ជាលាយលក្ខណ៍អក្សរដូចសព្វដងជូនដល់ភាគី និងសាធារណជនបានយល់អំពីដំណើរការហើយ ។ ហើយអង្គជំនុំជម្រះយល់ថាមិនយឺតទេ ព្រោះនៅសប្តាហ៍នេះនិងសប្តាហ៍ក្រោយយើងធ្វើសវនាការលើចំពោះអ្នកដែលរស់រានមានជីវិតពីមន្ទីរស-២១ ។

ជាកិច្ចបន្តនេះ អង្គជំនុំជម្រះសូមប្រគល់នូវវេទិកានេះជូនទៅតំណាងសហព្រះរាជអាជ្ញា ដើម្បីសួរសំណួរដល់អ៊ំ ជុំ ម៉ី ។ ហើយតំណាងសហព្រះរាជអាជ្ញាមានពេលវេលាសាមសិបនាទី ក្នុងការសួរនេះ គឺរហូតដល់ម៉ោងពីរប្រាំនាទី ។ សូមអញ្ជើញ តំណាងសហព្រះរាជអាជ្ញា ។

[១៣:៣៤:៤៣]

**សួរដោយលោក តាន់ សេណារ៉ុង៖**

**ស៖** អរគុណលោកប្រធានអង្គជំនុំជម្រះ ។ ដោយមានពេលវេលាខ្លី អ៊ីចឹងខ្ញុំតំណាងឲ្យសហព្រះរាជអាជ្ញានឹងសួរទៅសំណួរជូនលោក ជុំ ម៉ី តែម្តង ។ លោក ជុំ ម៉ី តើនៅក្នុងរយៈកាលដែលគេចាប់ខ្លួនលោកទៅមន្ទីរស-២១នុ៎ង តើលោកដែលធ្លាប់ឃើញ និងស្គាល់កម្មាភិបាលណាច្បាស់លាស់ទេនៅទីនោះលោក?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកៗព្រះរាជអាជ្ញា! ខ្ញុំមិនបានទទួលមើលអ្នកទាំងអស់នោះច្បាស់លាស់នោះទេ ព្រោះពេលមិនទាន់ទាំងចូលក្នុងគុកឡូលស្លែងផង គេចងមុខខ្ញុំជាប់ទៅហើយ ។

**ស៖** សំណួរបន្តទៀតជូនលោក តើនៅពេលគេធ្វើទារុណកម្មលើរូបលោកនោះ តើនឹងសួរចម្លើយពេលធ្វើទារុណកម្មនិងសួរចម្លើយ ។ តើអ្នកសួរចម្លើយនៅលើរូបលោកម្តងប៉ុន្មាននាក់ដែរ? ក្នុងរយៈពេលដប់ពីរយប់ ដប់ពីរថ្ងៃហ្នឹង គេបានសួរចម្លើយលើរូប តើក្នុងរយៈពេលម្តងៗនោះ អ្នកសួរចម្លើយមានប៉ុន្មាននាក់? ហើយគេមានផ្លាស់អ្នកសួរចម្លើយៗលើរូបលោកទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ព្រោះពេលនុ៎ង គឺថាគេសួរហ្នឹងមែនសួរចំពោះតែសេង នុ៎ងម្នាក់ទេ វាមាន ទិត ក៏សួរ ហើយ សេង ហ្នឹងក៏សួរ តែ ហ៊ា មិនបានសួរទេ ។ ហ៊ា ហ្នឹងបានតែ

វាយខ្ញុំទេ ។

**ស៖** សូមទោស។ នៅពេលដែលគេធ្វើទារុណកម្មវាយលើដងខ្លួនរបស់លោកដូចលោកបានជម្រាបអង្គជំនុំជម្រះហើយថា តើគេវាយផ្នែកណានៃដងខ្លួនលោក?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា គឺថាគេវាយ គឺថាពេលនោះ គឺខ្ញុំរកទប់ទល់ម៉េចអត់កើតទេ គឺថាពេលនុំងគេដាក់ខ្ញុំនៅនឹងឥដ្ឋហ្នឹង ហើយឲ្យសន្ទោកជើងគេដាក់ខ្នោះជើងទាំងពីរហ្នឹង ពេលគេវាយមក ខ្ញុំចេះតែយកដៃរងអ៊ីចឹងចុះឡើងៗ អ៊ីចឹងវាឈើខ្លាំងពេកក៏ត្រូវបាក់កូនដៃខ្ញុំហ្នឹង ។

**ស៖** អ៊ីចឹង បានន័យថាការធ្វើទារុណកម្មភាគច្រើន គឺវាយទៅលើដងខ្លួនរបស់លោកមិនអ៊ីចឹង?

**ឆ៖** បាទ ។

**ស៖** ចុះនៅលើដងខ្លួនរបស់លោកហ្នឹង មានស្លាកស្នាមដែលសេសសល់ទេ?

**ឆ៖** រឿងដៃហើយនិងក្រចកជើងប៉ុណ្ណឹងទេ ។ រឿងដៃវាយបាក់កូនដៃ ហើយនិងក្រចកជើងដក ។

[១៣:៣៨:០០]

**ប្រធានអង្គជំនុំ៖**

អ៊ំៗ ម៉ី រំឭកម្តងទៀត អ៊ំនៅចាំៗពេលមានសញ្ញាភ្លើង ចាំអ៊ំឆ្លើយ ចាំអ៊ំនិយាយ ។ ខំអ៊ំនិយាយទៅ ខាងនោះអត់ឮទេ ស្តាប់អត់បានទេ ។ អ៊ីចឹង សម្តីរបស់អ៊ំនិយាយទៅ ដូចវាអត់បានភាគី ជាពិសេសខាងអន្តរជាតិស្តាប់អត់បានទេ ហើយអ្នកចូលរួមច្រើនណាស់ ដើម្បីឲ្យបានស្តាប់យល់សម្តីរបស់អ៊ំ ។ ហើយខាងមន្ត្រីតុលាការទាញក្បាលមីក្រូឲ្យគាត់មកខាងកើតបន្តិច ។ អ៊ំទាញមកកើត ទាញទាំងតួវាមកកើត តិចទៀតៗ អ៊ំតិចទៀត អាឮទេ បានៗ អូខេ ។ បានខ្ញុំអាចមើលឃើញផង ។ សូមអញ្ជើញបន្ត ។

**សួរដោយ លោក តាន់ សេណារ៉ុង៖**

**ស៖** ខ្ញុំគ្រាន់តែសូមបញ្ជាក់ឡើងថា មនុស្សបីនាក់ដែលមាន សេង, ទិត, ហ៊ា ហ្នឹងគឺមានវត្តមានទាំងបីនាក់ៗហ្នឹងរាល់ពេលសួរចម្លើយទាំងដប់ពីរថ្ងៃ ដប់ពីរយប់ហ្នឹងលោក?

**ឆ៖** ជម្រាបប្រសាសន៍លោក! គឺថាជួនកាលឃើញ មិត្តទិត មកវាយពីរថ្ងៃទៅ ជួនកាល សេងហ្នឹងមកវាយបួនប្រាំថ្ងៃអីអ៊ីចឹង ផ្លាស់ប្តូរគ្នា ។ ប៉ុន្តែ មិត្តហ៊ា នោះ មកវាយខ្ញុំតែម្តងទេ មួរដៃអាវអ៊ីចឹងហើយនិងវាយបាក់រំពាត់អស់មួយ ហើយយករំពាត់មួយមកទៀតវាយ ។

**ស៖** ចុះនៅពេលនោះ តើអ្នកណាអ្នកកត់ត្រា? ហើយពេលដែលគេកត់ត្រារួច គេឲ្យលោកមានចុះហត្ថលេខា និងផ្តិតមេដៃទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ពេលនោះគឺថា សេង ហ្នឹងគឺថាគេមានអង្គុលីលេខមួយនៅនឹងតុអ៊ីចឹងតែម្តង កាលណាគេសួរយើងហើយ អីហើយអ៊ីចឹង យើងអត់ឆ្លើយ គេវាយយើង ។ វាយយើងអស់ចិត្ត អស់ចង់អ៊ីចឹង គេមកវាយអង្គុលីលេខហ្នឹងតែម្តង ។

**ស៖** អ៊ីចឹងបានន័យថា គេបានសួរលោកតែម្នាក់ទេ ហើយមានអ្នកវាយអង្គុលីលេខម្នាក់ ។ សំណួរបន្តទៀត-- *(គ្មានឮសំឡេង)*

**ឆ៖** វាយម្នាក់ វាយខ្ញុំម្នាក់ទេ គឺតែម្នាក់ទេក៏ប៉ុន្តែវាវាយអស់ចិត្តអស់ចង់ទៅ វាមកវាយអង្គុលីលេខ ។ វ៉ៃអស់ចិត្ត អស់ចង់ វាមកវាយអង្គុលីលេខហ្នឹង ។ វាផ្លាស់គ្នា មួយថ្ងៃ-- ពីរបីថ្ងៃអ្នកនោះទៅពីរបីថ្ងៃអ្នកនេះទៅ តែពីរនាក់ទេ សេង ហើយនិង ទិត តែ ហ៊ា នោះមកវាយខ្ញុំតែម្តងទេ ហ៊ា នោះ ។

[១៣:៤០:៣៧]

**ស៖** ចុះការឆក់ខ្សែភ្លើងរបស់លោកហ្នឹង ដែលគេបានឆក់ខ្សែភ្លើងហ្នឹង តើគេឆក់នៅថ្ងៃណានៃថ្ងៃការសួរចម្លើយដប់ពីរថ្ងៃ ដប់ពីរយប់ មកលើរូបនោះ ឬក៏ឆក់ថ្ងៃចុងក្រោយនៃថ្ងៃសួរចម្លើយ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោក គឺថាដាក់ឆក់ខ្សែភ្លើងនុ៎ង ដល់ខ្ញុំស្មានមិនត្រូវទេ ប្រហែលជាថ្ងៃ៨ ថ្ងៃ៩ ។

**ស៖** ចុះនៅពេលដែលគេដោះលែងលោកឲ្យធ្វើជាជាងជួសជុលម៉ាស៊ីនដេរនុ៎ង តើកន្លែងជួសជុលម៉ាស៊ីនដេរ និងកន្លែងរោងគូរគំនូររបស់លោក វ៉ាន់ ណាត នុ៎ង នៅជិតគ្នាទេ?

**ឆ៖** នៅឆ្ងាយពីគ្នាណាស់ មែននៅជិតគ្នាទេ ។ វ៉ាន់ ណាត គាត់គូរក្នុងបន្ទប់ហ្នឹង តែខ្ញុំចេញទៅក្រៅរបង ទៅក្រៅរបងខាងណោះ ទៅកន្លែងរោងគេបបរបាយអីហ្នឹង ហើយរោងចិញ្ចឹមជ្រូក ទៅធ្វើខាងនុ៎ង ។

**ស៖** អរគុណលោក ។ លោកដែលធ្លាប់បានឮសូរសម្រែកក្មេងស្រែកយំនិងមនុស្សដែលនៅក្នុងមន្ទីរឃុំឃាំងហ្នឹងស្រែកទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ពេលនោះគឺថា រកស្តាប់អីអត់ឮទេ គឺទ្រហឹងអឺអាប់ពេញនុ៎ងតែម្តង ។ ខ្ញុំនៅទីនោះ អាកូនយំផង ស្រីៗក៏យំ អាមនុស្សប្រុសហ្នឹងក៏ស្រែកដេរពេញទឹកពេញដី ។ ខ្ញុំមិនប៉ានសួរបញ្ចេញទេ គឺថាដេរម្រ៉ាយគ្នាទៅវិញទៅមកអ៊ីចឹងក្អួយ ។

**ស៖** អរគុណលោក ។ នៅក្នុងរយៈពេលដែលលោកជាប់ឃុំឃាំងនៅទីនោះ តើដូចជនជាប់ចោទក្តី លោក វ៉ាន់ ណាត ក្តី គាត់ធ្លាប់បានបញ្ជាក់ដែលថា ខោដែលគេឲ្យលោកស្លៀកហ្នឹង គឺជាខោអត់មានខ្សែរឹតទេ ។ តើលោកនៅពេលនុ៎ង គេឲ្យខោលោកស្លៀកហ្នឹង ខោហ្នឹងមានខ្សែរឹតកៅស៊ូដែរ ឬទេ?

**ឆ៖** បាទ, ខោខ្ញុំស្លៀកហ្នឹងគឺថាមានខ្សែកៅស៊ូទេ មិនមែនខ្សែរឹតអំបោះទេ ខ្សែកៅស៊ូ ។ យើងកាលណានេះ យើងទាញមកវាយឺតអ៊ីចឹង ។ ខោហ្នឹង កាលដែលខ្ញុំមិនទាន់បានខោហ្នឹងស្លៀកហ្នឹង មិនទាន់ចូលស-២១ ហ្នឹង ខ្ញុំកាត់កង់កៅស៊ូឡាននោះ ធ្វើខ្សែយឺតដាក់ខោហ្នឹង ។

**ស៖** អរគុណលោក ។ នៅថ្ងៃ៧ មករា ឆ្នាំ១៩៧៩ នៅពេលដែលលោកត្រូវបានគេប្រមូលយកមកដាក់នៅកន្លែងបន្ទប់ជាងគំនូររបស់លោក វ៉ាន់ ណាត នុ៎ង នៅពេលនោះ លោកបានបញ្ជាក់ថា ដូចគ្នា ១៥នាក់ អ៊ីចឹង មែនទេលោក?

[១៣:៤៣:៣៩]

**ឆ៖** ខ្ញុំអត់ចាំទេ ១៥នាក់ *(សំឡេងក្រៅមីក្រូហ្វូន)* ។

**ប្រធានអង្គជំនុំ៖**

អ៊ំៗ ទីមួយអ៊ំស្តាប់សំណួរសិន ទីពីរអ៊ំចាំដល់ពេលមានភ្លើងចាំអ៊ំឆ្លើយ ពីព្រោះបច្ចេកទេសគឺឲ្យអ្នកសួរហ្នឹង សួររួច ដើម្បីឲ្យអ្នកបច្ចេកទេសខាងណោះអង់បន្តិច ដើម្បីឲ្យការបកប្រែហ្នឹងបកទាន់បាន គេបើកភ្លើង ។ អ៊ីចឹង អ៊ំចាំមើលឃើញភ្លើង ចាំអ៊ំឆ្លើយ អ៊ំណ៎ា ។

**សួរដោយ លោក តាន់ សេណារ៉ុង៖**

**ស៖** នៅពេលដែលគេៗដែលគេបានប្រមូលលោកមកដាក់ (សូមទោស) លោកមកដាក់នៅបន្ទប់គំនូរនោះ លោកបានបញ្ជាក់ថា មានចំនួនដប់ប្រាំនាក់ អ៊ីចឹងមែនទេ?

**ឆ៖** បាទ អាហ្នឹងជាការពិតហើយលោក ។

**ស៖** តើនៅពេលនោះ អ៊ំឃើញមានស្ត្រីនៅជាមួយទេ? មានស្ត្រីនៅប្រមូលផ្តុំនៅក្នុងរោងជាងនោះដែរ ឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោក! មិនបានឃើញស្ត្រីនៅហ្នឹងទេ ។

**ស៖** ចុះនៅពេលដែលលោករត់ចេញពីមន្ទីរឃុំឃាំងហ្នឹងទៅព្រៃស ជាជំហានដំបូង តើលោកមានឃើញស្ត្រីនុ៎ងរត់ទៅជាមួយទេ ពីព្រោះជនជាប់ចោទក្តីបានឆ្លើយប្រាប់អង្គសវនាការថា ក្មួយរបស់

នួន ជា ម្នាក់ ឈ្មោះ ឡាច ដារ៉ា ដែលជាគ្រូពេទ្យហ្នឹង បានរត់ចេញពីមន្ទីរឃុំឃាំងហ្នឹង បានៗជម្លៀសចេញនៅថ្ងៃ៧ មករា ហ្នឹង ចេញទៅជាមួយនឹងពួកដែលគេត្រូវជម្លៀសចេញពីក្នុងមន្ទីរហ្នឹង នៅពេលដែលកងទ័ពវៀតណាមចូលនុ៎ង ។ តើលោកមានបានជួបស្ត្រីនុ៎ង ធ្វើដំណើរទៅជាមួយនឹងព្រៃសជាមួយលោកទេ?

**ឆ៖** គឺថាខ្ញុំអត់មានឃើញស្ត្រីណាទៅជាមួយទេ ព្រោះថាចេញទៅពីទួលស្លែងហ្នឹង វាឈប់ត្រង់កាច់ជ្រុងនោះមួយកន្លែង តែអត់មានឃើញស្ត្រីទេ ។ ដល់វេលាខ្ញុំទៅដល់កន្លែងវត្តអី វត្តសន្សំកុសលហ្នឹង ទៅនៅនុ៎ងរហូតទាល់យប់ទៀត ក៏អត់ឃើញមានស្ត្រីដែរ ។ ហើយទទួលយប់ហើយចេញដំណើរពីហ្នឹងរហូតទៅដល់ព្រៃសហ្នឹង ទៅនៅព្រៃសហ្នឹងក៏អត់មានឃើញស្ត្រីដែរ ។ ហើយនៅព្រៃសហ្នឹងជិតភ្លឺបានធ្វើដំណើរទៅទៀត ទៅរហូតទៅដល់ទៅភ្លឺជិត យើងហៅ អង្គស្នួលនោះ ។ គេហៅថា ជិតចម្ការឪឡឹកហ្នឹង ទៅដល់នុ៎ងបានមានឃើញស្ត្រីបួនប្រាំនាក់នៅនោះ ជួបទាំងគ្រួសារខ្ញុំនៅនុ៎ងទៀត ។

**លោក តាន់ សេណារ៉ុង៖**

សូមអរគុណលោក ជុំ ម៉ី ដែលបានឆ្លើយនឹងសំណួរខ្ញុំរបស់ខ្ញុំ ។ ខ្ញុំជូននាទីបន្ទាប់នេះទៅសហការីរបស់ខ្ញុំ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញសហព្រះរាជអាជ្ញាអន្តរជាតិ ។

**សួរដោយលោក វីលៀម ស្មីត៖**

ស៖ សូមគោរពលោកប្រធាន លោកចៅក្រម ហើយនិងជម្រាបសួរលោកសាក្សី លោក ជុំ ម៉ី ខ្ញុំមានសំណួរមួយចំនួនតូចទាក់ទងទៅនឹងសក្ខីកម្មដែលលោកបានបញ្ជាក់ព្រឹកមិញ ។ សំណួរទីមួយ នៅពេលដែលលោកបានចាកចេញពីភ្នំពេញក្នុងឆ្នាំ១៩៧៥ ថ្ងៃទី១៧ មេសា ហើយគេបាន-- ខ្មែរក្រហមជាអ្នកជំរុញឲ្យប្រជាជនចេញ តើមែនឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកព្រះរាជអាជ្ញា! ពិតមែនហើយអារឿងហ្នឹង ។

[១៣:៤៧:២៤]

**ស៖** ហើយតាមផ្លូវដែលចេញពីភ្នំពេញ ហើយលោកមានប្រសាសន៍ថា គឺនៅតាមផ្លូវមានមនុស្សពាសពេញ ហើយមានមនុស្សបីនាក់ត្រូវបានគេបាញ់សម្លាប់ ។ តើលោកអាចប្រាប់តុលាការបានទេ អ្នកដែលគេបាញ់ស្លាប់បីនាក់នុ៎ងជាជនស៊ីវិល ឬក៏ទាហាន ហើយក៏ជម្រាបតុលាការផងដែរ អ្នក

ណាជាអ្នកបាញ់សម្លាប់អ្នកទាំងអស់ហ្នឹង តាមផ្លូវចេញពីភ្នំពេញទៅនោះ?

[១៣:៤៧:៥៨]

**ឆ៖** ជម្រាបប្រសាសន៍លោក! ខ្ញុំដូចស្តាប់មិនបានទេ សំណួរហ្នឹង ។ ខ្ញុំអត់មានដែល ខ្ញុំអត់បាននិយាយថា បាញ់ស្លាប់បីនាក់ហ្នឹង ព្រឹកមិញដូចអត់បាននិយាយទេរឿងហ្នឹង ។

**សៈ** សូមអភ័យទោសប្រហែលជាធ្វើឲ្យលោកច្រឡំ ក្នុងករណីមួយដែលលោកថា លោកបានបញ្ជាក់ថាគឺលោកចេញពីភ្នំពេញទៅលោកឃើញមានសាកសពមនុស្សមួយចំនួន តើសាកសពមនុស្សទាំងនោះ តើជាសាកសពទាហាន ឬក៏ជនស៊ីវិល?

**ឆ៖** ជម្រាបលោកព្រះរាជអាជ្ញា! ពេលនោះ គឺថាខ្ញុំបាទអត់មានប៉ានពិនិត្យទេបញ្ហាហ្នឹង ក៏ប៉ុន្តែវាចូលទៅវាឃើញខ្មោចហើមៗអ៊ីចឹងខ្ញុំដើរយប់អ៊ីចឹងជាន់លើខ្មោហ្នឹងៗ ។ ដល់វេលាដួសទឹកបានហើយដាំបាយដាំអីហូបអ៊ីចឹង ព្រលឹមឡើងប្រហែលជាម៉ោងបួន វាដេញចេញពីកន្លែងហ្នឹងទៀត ក៏នាំគ្នាកូននាំអីទៅតាមផ្លូវៗជាតិលេខប្រាំហ្នឹង ។ ទៅគ្រាន់តែចេញ យើងចេញដើរតាមថ្នល់ហ្នឹងអាកន្លែងចិញ្ចើមត្រីគេហ្នឹង ពីព្រែកព្នៅរហូតទៅដល់វត្តគ្រួសហ្នឹង គេចិញ្ចើមត្រីតាមហ្នឹងរហូត ហើយខ្មោចងាប់មាននៅលើថ្នល់ហ្នឹងក៏មានៗ នៅក្នុងស្រះទឹកហ្នឹងក៏មាន ។ អាត្រីនោះ វាអត់ចំណីស៊ី វាស៊ីអាខ្មោចហ្នឹងវិលពេញតែនុំងទៅ ។ ទាំងគេទាំងខ្ញុំក៏មិនសូវប៉ានមើលចេះតែធ្វើដំណើរទៅមុខទៅ ។

**សៈ** សូមអរគុណ ។ តាមដែលលោក ដំណើរឆ្លងកាត់មួយដែលលោកចេញពីភ្នំពេញនោះ ហើយមាន-- តើលោកបានជួបករណីខ្លះដែលប្រជាជនអ្នកភ្នំពេញគេមិនព្រមចេញ? តើគេអាចនឹងជួបបញ្ហាអ្វីដែរឬទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកចៅក្រម-- លោកព្រះរាជអាជ្ញា អាបញ្ហាហ្នឹងដែលខ្ញុំបាននិយាយនៅផ្សារដេប៉ូហ្នឹង អាពេលខ្មែរក្រហមចូលមកហ្នឹងគឺថា ខ្ញុំហ្នឹង ទាំងគេទាំងខ្ញុំ ទាំងអស់ហ្នឹងលើកអាទង់ជ័យស រកអាក្រណាត់ស លើកទង់ជ័យស ជយោៗ នឹងគេនឹងឯងអ៊ីចឹងទៅ ។ ដល់វេលាយើងល្ងាចទៅប្រហែលជាម៉ោងប្រាំមួយ ឬក៏ម៉ោងប្រាំអីហ្នឹង វាថាឥឡូវពុកម៉ែទាំងអស់ចេញពីទីក្រុងភ្នំពេញទៅចំនួនប្រាំគីឡូ ខ្លាចអាមេរិកាំង វាទម្លាក់គ្រាប់បែក ។

ដលហើយពេលហ្នឹងគឺថា ទាំងគេទាំងខ្ញុំដូចជាមិនចង់ចេញទេ ។ ដល់ខ្ញុំនៅយូរៗទៅ ស្រាប់តែវាដេញទៀត ដេញទៀត ប្រជាជនអត់ចេញទេ ។ ដល់ហើយវាបាញ់រះរ៉ាវអ៊ីចឹងទៅ មួយរ៉ាវអ៊ីចឹងទៅដួលពីរបីនាក់ អាហ្នឹងហើយដែលធ្វើឲ្យខ្ញុំទ្រាំនៅហ្នឹងអត់បាន ខ្ញុំត្រលប់ទៅផ្ទះវិញ ខ្ញុំបបួលប្រពន្ធកូនឲ្យ

ចុះចេញទៅឲ្យលឿនៗទៅ ។

[១៣:៥១:០៣]

**ស៖** សូមអភ័យទោសដែលខ្ញុំលើកចំណុចនេះឡើងវិញ លោកបាននិយាយទៀតថា ក្រោយពីលោកត្រូវបានគេបណ្ដេញចេញពីភ្នំពេញ ហើយមានកូនប្រុសអាយុពីរឆ្នាំម្នាក់បានស្លាប់ ។ ថាតើកូនរបស់លោកឈឺមុនពេលចេញពីភ្នំពេញ ឬក៏បានឈឺក្នុងដំណើរការដែលជម្លៀស ហើយគាត់បានទទួលជំងឺហ្នឹងរហូតដល់ស្លាប់នោះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោក កូនហ្នឹងមិនមែនឈឺពីភ្នំពេញទៅទេ ។ ទៅដេកនៅត្រង់យើងត្រង់ដែលខ្ញុំនិយាយថាមានខ្មោចមានអីងាប់ហ្នឹង ទៅពីហ្នឹងទៅវារាក ឈឺរាកតាំងពីហ្នឹងទៅហើយ ។ ហើយទទួលរាកទៅ យើងទៅដល់ជិតព្រែកក្ដាមហ្នឹង យើងឆ្លងទៅត្រើយម្ខាងៗទៅពេលនុំង ថ្ងៃហ្នុងភ្លៀង ដល់ភ្លៀងអ៊ីចឹងទៅកូនហ្នឹងចេះតែរាកៗហើយ គេឲ្យទៅសុំថ្នាំពីអង្គការ ខ្ញុំដើររកអង្គការហ្នឹង មិនដឹងអង្គការមួយណា ទៅៗគេឲ្យទៅអង្គការ មួយនោះថាឲ្យសុំអង្គការទៅបានហើយ ។ ហើយដើររកអង្គការហ្នឹង ដើររករហូតកូនស្លាប់ជម្រាបប្រសាសន៍លោក ។ កូនស្លាប់ហើយនឹងទៀត អត់មានអីកប់ទៀត ទៅខ្ចីចបអ្នកស្រុកហ្នឹងជីករណ្ដៅនៅចិញ្ចើមថ្នល់ហ្នឹង កប់កូននៅហ្នឹងអីរួចហើយ បានគេដេញឲ្យធ្វើដំណើរទៅទៀត ។

**ស៖** សូមអរគុណ ។ សហព្រះរាជអាជ្ញាប្រហែលជាយើងអាចចូលទៅដល់ស-២១ នៅពេលដែលលោកទៅដល់ថ្ងៃទី២៨ ខែតុលា រហូតទៅដល់ដើមខែមករា គឺថ្ងៃទី៧ មករា ឆ្នាំ៧៩ ហើយថាតើលោកឃើញជនជាប់ចោទឈ្មោះ ឌុច នៅស-២១ នោះទេ? ហើយនិងលោកក៏បានបញ្ជាក់ថា មិនដែលបានឃើញគាត់ ហើយមិនដែលឃើញគាត់ធ្វើទារុណកម្ម ។ នៅពេលដែលលោកនៅស-២១ តើលោកបានធ្លាប់ឮឈ្មោះគាត់ដែរឬទេ? មូលហេតុដែលខ្ញុំសួរសំណួរនេះ ដោយសារក្នុងចម្លើយរបស់លោកដែលលោកឆ្លើយទៅសហព្រះរាជអាជ្ញានោះ នៅក្នុង D200146779 លេខ ERN ក្នុងភាសាអង់គ្លេសហើយភាសាខ្មែរ ។ លោកបានបញ្ជាក់ថា ខ្ញុំបានឮគេថា ឌុច គឺជាប្រធានធំនៅទីនោះ ។ អ៊ីចឹងសំណួររបស់ខ្ញុំគឺថា តើលោកបានឮពីអ្នកណាដែលថា ឌុច ជាប្រធានធំនៅពេលដែលលោកនៅក្នុងស-២១ តាំងពីឆ្នាំ១៩៧៨ ឬក៏នៅក្នុង៧៩ ឬក៏ឮថាអ៊ីចឹងក្រោយពីពេលនោះមក?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោក! គឺថាចំពោះលោក ឌុច នេះគឺថាខ្ញុំអត់ដែលបានឃើញព្រោះទុកឃើញក៏ខ្ញុំបាទក៏អត់ស្គាល់គាត់ដែរ ព្រោះបានគ្រាន់តែឮសួរថា លោក ឌុច ហ្នឹងជាប្រធានគុក

ទួលស្លែង ដោយសារតែតា ឌី ផុន ហ្នឹង គាត់ដេកនៅជាមួយខ្ញុំ គាត់និយាយប្រាប់ថា ឌុច ហ្នឹងជាប្រធានគុកទួលស្លែង ហើយខ្ញុំមិនដែលជួបមុខគាត់ទេ ។ អត់ដែលហ៊ានមើលមុខគាត់ទេ ។

**ស៖** សូមអរគុណ ។ អ៊ីចឹង គាត់ប្រាប់លោកនៅពេលដែលលោកនៅបន្ទប់ឃុំខ្លួនធំ ។ តើត្រូវឬទេ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោក ពិតមែនហើយ ។

**លោក វឺលៀម ស្មីត៖**

ខ្ញុំមានសំណួរពីរបីទាក់ទងទៅនឹងកន្លែងឃុំខ្លួនរួមធំ លោកប្រធាន ខ្ញុំសូមអនុញ្ញាតនៅក្នុងនេះ នៅក្នុងវីដេអូ D69 ហើយ 00172525 គឺថានៅក្នុងចំណុច៤២ ដែលថាជារូបថតដែលបានថតហ្នឹង គឺនិយាយអំពីកន្លែងឃុំខ្លួនរួម ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

អ៊ីចឹង សូមឲ្យលោកសហព្រះរាជអាជ្ញា លោក ស្មីត បញ្ជាក់ថា តើនេះជាវីដេអូដែលជាផ្នែកនៃឯកសារដែលផ្តល់ឡើងដោយអ្នកជំនាញមែន-- ដែលតែងតាំងដោយតុលាការ តើមែនឬទេ? ខ្ញុំបាទនឹងចាប់ផ្តើមដោយអក្សរ Z តើគាត់ឈ្មោះ *ហ្សូវ៉ាន់ ឡឺស៊ិក* មិនដឹងទេ គឺថាជាឯកសារវីដេអូមួយដោយឡែកដែលផ្តល់ឲ្យ ហើយយើងដាក់ចូលទៅក្នុងសំណុំពីឆ្នាំទៅ ប៉ុន្តែចៅក្រមមិនមែនជាឯកសារវីដេអូដែលថាផលិតដោយវៀតណាម ដែលថា កំពុងពិចារណានោះទេ?

**លោក វឺលៀម ស្មីត៖**

មិនមែនទេ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ តើអាចបញ្ចាំងបានទេ? ខាងសោតទស្សន៍អាចបញ្ចាំងនូវរូបភាព D69 ERN00172525 ។

[១៣:៥៦:៥២]

**សួរដោយលោក វឺលៀម ស្មីត៖**

**ស៖** លោក ជុំ ម៉ី តើលោកបានឃើញរូបថតនៅលើអេក្រង់នេះ រូបថតនេះដែលយើងជឿថា ជារូបថតនៃកន្លែងឃុំខ្លួនធំនៅស-២១ សូមលោកពិនិត្យមើលរូបថតនេះ ហើយលោកអាចនិយាយបានដូចម្តេចថាវាស្រដៀងទៅនឹងស្ថានភាពដែលលោកជាប់នៅកន្លែងនៅនោះទេ នៅក្នុងបន្ទប់រួមនៅពេលល្ងាច

នៅក្នុងពេលល្ងាចនោះ ឆ្នាំ១៩៧៨ ដែលលោកបាននៅទីនោះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោក បញ្ហានេះបើមនុស្សដេក ខ្ញុំជឿថានៅបន្ទប់រួម ប៉ុន្តែមនុស្សអង្គុយនេះ មិនមែន អត់មានពេលអង្គុយអ៊ីចឹងទេ ពេលដេកៗទៅតែម្តង អត់មានអង្គុយអីទេ ។ ពេលដេកៗតម្រៀបគ្នាដូចយើងពង្រាបចេកអាំងអ៊ីចឹង ។

**លោក វីលៀម ស្មីត៖**

សូមអរគុណ ។ ប្រហែលយើងអាចនឹងបង្ហាញខ្សែវីដេអូខ្លីមួយដែលចេញមកពីផ្នែកនេះដែរគឺថាប្រហែលជាសែសិបបួនសឹហ្គុង ទៅលើសហ្នឹងតិចទៀត ដែលជឿថាគឺជា-- យើងដក ដែលអាចនឹងបង្ហាញអំពី តើកន្លែងឃុំខ្លួនធំ វាមានលក្ខណៈដូចម្តេចក្នុងឆ្នាំ១៩៧៨? យើងពិនិត្យមើលខ្សែវីដេអូខ្លី ហើយនឹងជម្រាបតុលាការថា តើដូចគ្នា ឬស្រដៀងទៅនឹងអ្វីដែលគេឃុំលោកនៅក្នុងកន្លែងឃុំខ្លួនធំនោះដែរ ឬទេ? បាទ សូមអនុញ្ញាតពីតុលាការដើម្បីចាក់នូវខ្សែវីដេអូខ្លីនេះ ។

**ប្រធានអង្គជំនុំ៖**

អត់ឲ្យមានអត្តសញ្ញាណបញ្ជាក់ទេ វីដេអូនុ៎ង? មានបញ្ជាក់អត្តសញ្ញាណទេ D ប៉ុន្មាន? ហើយនិង ERN អីទេ?

**លោក វីលៀម ស្មីត៖**

សូមអរគុណលោកប្រធាន គឺលេខដដែលគឺ D69 00172525 គឺថាមានរយៈពេលពី សែសិបសឹហ្គុង ទៅហាសិបប្រាំបួនសឹហ្គុង ដែលទាក់ទងទៅនឹងកន្លែងឃុំខ្លួនធំរួមនៅក្នុងស-២១ ។

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ចាក់បញ្ចាំងនូវខ្សែវីដេអូ ដែលមានអត្តសញ្ញាណដូចតំណាងសហព្រះរាជអាជ្ញាអន្តរជាតិបានលើកឡើងអំមិញនេះ ។

[១៤:00:00]

**លោក វីលៀម ស្មីត៖**

**ស៖** លោក ដុំ ម៉ី នៅក្នុងខ្សែវីដេអូខ្លីនេះ នៅលើ*ស្គ្រីន* អម្បាញ់មិញនេះ មិនមែនចេញមកពី១៩៧៨ គឺជាការសម្តែងឡើងអ្វីដែលយើងជារបៀបទៅមើលទៅប្រហាក់ប្រហែលនឹងកន្លែងឃុំខ្លួនធំ ថាតើលោកអាចបញ្ជាក់បានទេពីបទពិសោធន៍ដែលលោកធ្លាប់ឆ្លងកាត់នៅកន្លែងនោះ ក្នុងរយៈពេលពីរខែនៅកន្លែងធំនោះ ។ មើលវីដេអូអំមិញទៅ តើលោកអាចបញ្ជាក់បានដូចម្តេច?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោក! បញ្ហាខ្សែវីដេអូនេះ គឺថាអម្បាញ់មិញនេះ គឺថាដូចគ្នាបេះបិទតែម្តង អត់មានខុសទាស់អីត្រង់ណាបន្តិចទេ ។ តែបើអារឿងមុននោះ វាខុសបន្តិចមានក្មេងម្នាក់ឡើងអង្គុយ ប៉ុន្តែធម្មតាបើកាលណាដេកៗហើយ កាលណាយើងឡើងអង្គុយ យើងទាល់តែសុំគេ បានយើងមានសិទ្ធិឡើងអង្គុយបាន ក៏ប៉ុន្តែ ពេលនុ៎ងគឺថាដេកហ្នឹងដេកតែពេលយប់ទេ អារឿងខ្ញុំដេកពេលយប់ទេ ពេលថ្ងៃគេឲ្យខ្ញុំទៅធ្វើការ ។

**ស៖** ប្រហែលជាសំណួរមួយទាក់ទងទៅនឹងកន្លែងឃុំខ្លួនធំនោះគឺថា ជាញឹកញាប់គេយកអ្នកទោសចេញអំពីបន្ទប់ធំហ្នឹង ហើយក៏មានអ្នកថ្មីចូលមក ។ តើលោកអាចប្រាប់តុលាការបានទេ ថាតើគេយកចេញមនុស្សហ្នឹងញឹកញាប់ប៉ុនណាពីបន្ទប់ហ្នឹង? គឺញឹកញាប់ប៉ុនណា?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោក! គឺថាវាមានយកចេញហ្នឹង ជួនកាលយកចេញកន្លងមកយកចេញរនងផ្សេងពីកន្លែងខ្ញុំហ្នឹង ដល់ក្រោយមកទៅបានយកចេញពីរនងជាប់ខ្នោះជាមួយខ្ញុំហ្នឹងបីនាក់ចេញទៀត គឺថាដែលខ្ញុំសម្គាល់ទៅស្ទើរតែរាល់យប់តែម្តងយកចេញហ្នឹង ។

**ស៖** នៅពេលដែលគេយកចេញទៅ តើអ្នកយាមគេចូលមកក្នុងបន្ទប់ ឬក៏គេហៅ មកដល់មាត់ទ្វារគេហៅចេញទៅ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោក! គឺថាពេលមកនេះហ្នឹង គឺថាមានគេ គេមកចាក់ ចាក់សោយកហ្នឹង តែមុននឹងចាក់សោយកចេញទៅហ្នឹងគេដាក់ខ្នោះដៃយើងសិនៗបានគេដោះរនងជាប់ជើងយើងហ្នឹងចេញ ។ គេដាក់ខ្នោះដៃមុន ។

**ស៖** សំណួរចុងក្រោយមួយទៀត តើលោកមើលE-53 ចំណុចបួនដែលជារូបថតដែលថតឡើងដោយលោក *ហ្សូរ៉ាន់ ឡឺស៊ិក* គឺមានរូបថតមួយនៅក្នុងមន្ទីរ-- កន្លែងឃុំខ្លួនតូច គឺថាកាលពីឆ្នាំទៅ ។ អ៊ីចឹងខ្ញុំនឹងមានរូបភាពបង្ហាញទៅលើអេក្រង់ និងខ្ញុំសួរសំណួរមួយ ។

[១៤:០៣:៤០]

**ប្រធានអង្គជំនុំ៖**

ផ្នែកខាងសោតទស្សន៍ បញ្ចាំងនូវរូបភាព E53.4 នៅលើកញ្ចក់ទូរទស្សន៍ ។

**សួរដោយលោក វីលៀម ស្មីត៖**

**ស៖** លោក ជុំ ម៉ី តើនេះហើយជារូបសភាពការដែលលោកជាប់នៅទីនោះដប់ពីរថ្ងៃ ហើយគេសួរ ហើយគេធ្វើទារុណកម្ម តើលោកជាន់នៅកន្លែងហ្នឹង ថាតើទទួលអារម្មណ៍ដូចម្តេចនៅពេលដែល

លោកចូលទៅដល់កន្លែងឃុំខ្លួនតូចហ្នឹង គឺថាពីថាមួយថ្ងៃទៅមួយថ្ងៃ ហើយអស់រយៈពេលដប់ពីរថ្ងៃនោះ?

**ផ៖** ខ្ញុំបាទសូមជម្រាបប្រសាសន៍ព្រះរាជអាជ្ញា! គឺថាខ្ញុំចូលទៅដល់កន្លែងហ្នឹង ខ្ញុំនឹកក្នុងខ្លួនថា ខ្ញុំអត់មានរស់រានមានជីវិតទាស់ថ្ងៃណោះទេ ។ ពេលនោះខ្ញុំដេកចាំតែថ្ងៃស្លាប់ទេ ។ ខ្ញុំតាំងពីណាពីណីមក ខ្ញុំមិនដែលដេកខ្លួនទទេនៅឥដ្ឋអ៊ីចឹងទេ ហើយគេមិនដែលជះទឹកឲ្យខ្ញុំអ៊ីចឹងដែរ ។ បើសត្វជ្រូកទៅគេឲ្យបាយស៊ី តែចំពោះខ្ញុំគេឲ្យទឹកបបរមួយវែកៗ *(សាក្សីយំ)* ។

**ប្រធានអង្គជំនុំ៖**

លោកសហព្រះរាជអាជ្ញាអស់ពេលហើយ ។ អ៊ំ ម៉ី អ៊ំធ្វើការសង្រួមនូវអារម្មណ៍ឲ្យល្អឡើងវិញអ៊ំ ។ អ៊ំពង្រឹងស្មារតីឲ្យបានល្អ អ៊ំនៅពេលនេះយើងកំពុងធ្វើដំណើរសវនាការ ។

ជាបន្តនេះ សូមជូនវេទិកាទៅមេធាវីអ្នកតំណាងដើមបណ្តឹងក្រុមមួយ ដែលមានពេលវេលាដប់នាទី ។

**លោកស្រី ស៊ីលយ៉ីស្ទត ហ្សីនស្តី៖**

សូមអរគុណ លោកប្រធាន ។ ខ្ញុំសូមជូនដំណឹងដល់អង្គសវនាការក្នុងនាមមេធាវីដើមបណ្តឹងរដ្ឋប្បវេណី និងក្រុមនេះទាំងអស់ ។ យើងសូមលើកឡើងនិងស្នើឡើងថា អង្គជំនុំជម្រះនឹងទទួលយកសំណើនេះ ។ យើងស្នើថា មេធាវីដែលតំណាងដើមបណ្តឹងរដ្ឋប្បវេណីមានអាទិភាពក្នុងការសួរសំណួរទៅគ្រប់ពេលទាំងអស់ ហើយសំណួរផ្សេង-- មេធាវីផ្សេងទៀតគឺ ឬក្រុមផ្សេងទៀតអាចសួរសំណួរនៅពេលណាមួយសមស្រប ហើយគឺយើងស្នើសុំថា សំណើនេះគឺការធ្វើដូច្នេះ គឺយើងនឹងធ្វើក្នុងចំណោមក្រុមរបស់យើង ។ ហើយលោក ហុង គឹមសួន គឺជាមេធាវីរបស់ តំណាងរបស់គាត់ ហើយនិងខ្ញុំជាមេធាវីតំណាងផងដែរ ។ ដូច្នេះហើយយើងខ្ញុំទាំងពីរសូមចាប់ផ្តើមមុននៅថ្ងៃនេះ បន្ទាប់មកមេធាវីផ្សេងទៀតនឹងសួរទៅតាមក្រោយ និងសួរបន្ថែម ។ ដូច្នេះហើយ គឺអង្គសវនាការនឹងមិនជំទាស់ទៅលើសំណើនេះ ហើយអនុញ្ញាតឲ្យយើងសួរក្នុងរយៈពេលសែសិបនាទី តាមអ្វីដែលយើងស្នើសុំនេះ បន្ទាប់មកមេធាវីនឹងសួរបន្ថែមតាមក្រោយ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញ! នេះជាការជម្រើសរបស់មេធាវី ហើយប្រហែលជាមេធាវីក្រុមមួយ និងក្រុមបី មិនជំទាស់ទេនូវការប្តូរនូវវិធីក្នុងការសួរនេះ ។

**លោក អាឡាំង វែនណឺ៖**

គឺខ្ញុំមិនជំទាស់ទេ ហើយគឺជំហរនិងការលើកឡើងនោះ គឺដូចអ្វីដែលលោកស្រី ស្ទួតហ្សីនស្តី បានលើកឡើង ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញ លោកស្រី ស្ទួតហ្សីនស្តី ឬក៏លោកមេធាវី ហុង គឹមសួន សួរដល់ទៅ អ៊ំ ជុំ ម៉ី ។

សូមអញ្ជើញ ។

**សួរដោយលោក ហុង គឹមសួន៖**

សូមអរគុណលោកប្រធាន បាទសូមគោរពលោកប្រធាន និងលោកស្រី លោកចៅក្រមក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជាជាទីគោរព ។

**ស៖** សូមជម្រាបសួរលោកពូ ជុំ ម៉ី ! ខ្ញុំជាមេធាវីរបស់លោកពូផ្ទាល់ និងសុំសួរសំណួរខ្លះៗបន្តពីលោកព្រះរាជអាជ្ញា និងអង្គជំនុំជម្រះដូចតទៅនេះ ។

ចាប់តាំងពីថ្ងៃដែលលោកពូបានទទួលដីកាកោះឲ្យចូលខ្លួនមកក្នុងថ្ងៃនេះ មានន័យថា មុនពេលនេះ ថ្ងៃដែលលោកពូទទួលបានដីកាកោះ តើលោកពូមានអារម្មណ៍យ៉ាងម៉េចដែរនៅពេលទទួលបានហើយ?

**ឆ៖** ខ្ញុំសូមជម្រាបទៅលោកមេធាវី! បារម្មណ៍របស់ខ្ញុំដែលទទួលបានដីកាកោះហៅឲ្យខ្ញុំមកបំភ្លឺនៅក្នុងសាលក្តីនេះ គឺថា ចិត្តខ្ញុំវាមានការរំភើបៗខ្លាំងមែនទែន រំភើបរីករាយច្បាស់លាស់មែនទែនគឺថាខ្ញុំនឹងបានឆ្លើយបំភ្លឺចំពោះមុខលោកប្រធានចៅក្រម សម្តែងនូវការពិត គឺថាខ្ញុំរីករាយ សប្បាយចិត្តមែនទែនបាន គឺថាខ្ញុំធូរក្នុងទ្រូងខ្ញុំ ។ បើខ្ញុំមិនបានមកសម្តែងនៅចំពោះមុខលោកប្រធានចៅក្រម ចំពោះមុខលោកមេធាវីទាំងអស់ក្នុងចិត្តរបស់ខ្ញុំដូចវាតឹងតែងខ្លាំងមែនទែនតែម្តង ។ ចង់តែឲ្យរឿងរ៉ាវហ្នឹងចង់ឲ្យវាទម្លាយចេញមកពីបេះដូងឲ្យអស់តែម្តងបានខ្ញុំធូរទ្រូង ។

[១៤:១១:០៩]

**ស៖** បាទ សូមអរគុណ ។ អ៊ីចឹងមានន័យថាលោកពូចង់បង្ហាញអំពីភាពឈឺចាប់ និងនៃផ្លូវកាយផ្លូវចិត្តរបស់ពូនៅក្នុងអង្គសវនាការឲ្យបានដឹងពីទុក្ខវេទនារបស់លោកពូ ។ ហើយខ្ញុំសូមសួរសំណួរបន្តថា លោកពូបានជម្រាបអង្គសវនាការស្តីអំពីការធ្វើទារុណកម្មលោកពូនៅក្នុងមន្ទីរស-២១ ឬយើងហៅសាមញ្ញមកថា គុកទួលស្លែងនេះ ។ ស្តីអំពីការដកក្រចកជើង ហើយលោកពូបានជម្រាបអំពីចំនួនអ្នក

ដែលធ្វើទោសនោះ តើលោកពូចាំទេថា ឈ្មោះអ្នកដែលធ្វើទារុណកម្មដកក្រចកជើងហ្នឹងម្នាក់ណា ឬក៏ឈ្មោះអី?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! គឺថា អ្នកដែលធ្វើទារុណកម្មខ្ញុំមុនដំបូងហ្នឹងគឺថាឈ្មោះ សេង ។ សេង ហ្នឹងវ៉ៃអស់ចិត្តអស់ចង់អ៊ីចឹងហើយ បានឃើញលិចមុខមិត្ត ឌុច អ៊ំ ខមាទោស មិត្តហ៊ ។ មិត្តហ៊ ហ្នឹងសម្លាកជិតភ្នែកនេះ ។ ហើយ សេង ហ្នឹងគឺថាដល់ក្រោយ សេង ហ្នឹងប្រាប់ថា បងឯងមើលវាអត់ព្រមឆ្លើយ អត់ព្រមអីទេ ។ ដល់នេះមក មិត្តហ៊ ហ្នឹងគាត់មួរដៃអាវអ៊ីចឹងតែម្តង ចូលមកទាញអារំពាត់ដាក់ផាំងៗៗបាក់អស់រំពាត់មួយហើយ វាយករំពាត់មួយមកវ៉ៃទៀត វ៉ៃអស់ចិត្តអស់ចង់វាក្រវាត់រំពាត់ហ្នឹងចោល វាថា “កណ្តួយម៉ែអ្នែង អ្នែងនៅលាក់លាមអីទៀត ប៉ុណ្ណេះហើយអ្នែងមិនឆ្លើយ” ហើយមិត្តហ៊ ហ្នឹងដើរចេញទៅ ។

**ស៖** សូមអរគុណ ។ សំណួរខ្ញុំសួរអ៊ីចេះណាលោកពូ សូមលោកពូស្តាប់ឲ្យបាន ឈ្មោះមួយណានៃអ្នកទាំងបីនាក់នេះ គឺមិត្តទិត្, មិត្តហ៊ និងមិត្តសេង បីនាក់ហ្នឹងតើឈ្មោះមួយណាដែលជាអ្នកយកដង្កាប់មកចាប់បកទាញក្រចកជើងលោកពូនេះ សួរឈ្មោះមនុស្សទេណ៎ា ។ ពូស្តាប់ទាន់ទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ដែលដកក្រចកខ្ញុំហ្នឹងគឺមិត្តសេង ហ្នឹងតែម្តង ។ មិត្តសេង ហ្នឹងគាត់ដកក្រចកខ្ញុំតែម្តង ។ តែមិត្តទិត្យហ្នឹងអត់បានដកទេ គ្រាន់តែវ៉ៃទេ ។ មិត្តសេង ជាអ្នកដក ។

**ស៖** បាទ សូមអរគុណ ។

**ឆ៖** មិត្តសេង ហ្នឹងជាអ្នកដកហើយអង្គុយលើក្បាលខ្ញុំទៀត យកវាឡើងអង្គុយលើក្បាលខ្ញុំទៀត។ សួរថាអ្នែងឆ្លើយមិនឆ្លើយៗ? ហ្នឹងមិត្តសេង ហ្នឹង ។

[១៤:១៣:៥៣]

**ស៖** សូមអរគុណពូ ។ សំណួរសួរថា ពេលដកក្រចកជើងទាំងពីរ តើឈាមហូរច្រើនឬទេ? និងភាពឈឺចាប់នៃការដកក្រចកជើងហ្នឹងរារយៈពេលប៉ុន្មានថ្ងៃ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ដកក្រចកហ្នឹងគឺថាវាដកមួយថ្ងៃមួយៗ ហើយការឈឺចាប់ហ្នឹងគឺថាវាយើងដើរមិនបានត្រង់ដូចមុនទេ គឺថាវាដើរបន្តិចៗ ហើយយើងនឹងថាក្នុងចិត្តយើងហ្នឹងថាជើងយើងវាឈឺចាប់ តែអារឿងចិត្តរបស់យើងហ្នឹងវាឈឺចាប់ជាងជើងទៀតក្មួយ ឈឺចាប់ជាងជើងទៀតរហូតមករាល់ថ្ងៃហ្នឹងតែម្តង ។

[១៤:១៥:០០]

**ស៖** សូមអរគុណលោកពូ ។ អ៊ីចឹងនៅពេលដែលវារបកក្រចកជើង វាដំបៅ វាឈឺចាប់ហ្នឹង វារយៈពេលវែង ឬខ្លីនោះ តើវាជានៅពេលណា? ចង់រយៈពេលប្អូនដប់ថ្ងៃ ឬមួយខែ ឬពីរអ៊ីចឹង ពេលណាដែលបានជាទៅវិញ?

**ឆ៖** ជម្រាបប្រសាសន៍លោក! ចំនួនជាមួយខែជាងបានជាដើរត្រង់ស្រួលបួល ។

**ស៖** សូមអរគុណ ។ លោកពូបានជម្រាបអង្គសវនាការហើយអំពីទាក់ទិននឹងការចោទប្រកាន់នៅពេលដែលក្រុមសួរចម្លើយនៅក្នុងគុកទួលស្លែង ឬមន្ទីរស-២១ ភ្នំពេញនេះ ចោទថាជា *សេអ៊ីអា* ហើយវាជារឿងមិនពិតទេនោះ តើលោកពូយល់ឃើញយ៉ាងម៉េច មានន័យថា ឈឺចាប់ ឬដែលខ្លួនមិនមែននោះ បង្ហាញពីអារម្មណ៍លោកពូមើល ថាយ៉ាងម៉េចដែរ ពេលដែលយើងមិនមែនសោះ ហើយគេនៅតែចោទឲ្យយើងឆ្លើយទៀត មកទល់ថ្ងៃនេះលោកពូគិតថាយ៉ាងម៉េច?

**ឆ៖** ចំពោះរឿងនេះ គឺថាខ្ញុំមិនអាចបំភ្លេចបានការឈឺចាប់នៅក្នុងស-២១ ហ្នឹងទេ លុះត្រាតែខ្ញុំបាត់បង់ជីវិតទៅបានខ្ញុំឈប់ឈឺចាប់ ។ បញ្ហានេះលុះត្រាតែកាលណាដូចលោកចៅក្រមអ៊ីចឹង គាត់រកយុត្តិធម៌ឲ្យខ្ញុំបាទទៅ ប្រហែលជាមានការរំសាយខ្លះ នូវបញ្ហាហ្នឹង ។

**ស៖** សូមអរគុណ ។ សំណួរខ្ញុំសួរបន្តទៀតសួរថា តាំងពីពេលដែលលោកពូបានរួចខ្លួនចាកចេញពីមន្ទីរស-២១ ឬគុកទួលស្លែងនេះ មកទល់ថ្ងៃនេះ នៅពេលលោកពូឮសួរឈ្មោះគុកទួលស្លែងឡើង តើក្នុងអារម្មណ៍ក្នុងខួរក្បាលលោកពូហ្នឹងមានអារម្មណ៍យ៉ាងម៉េចដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! បញ្ហាហ្នឹងគឺថាខ្ញុំកន្លងមកវា វាជាប់បីខែមកហើយ គឺថាខ្ញុំសម្រក់ទឹកភ្នែករហូត ឲ្យតែនិយាយពីរឿងគុកទួលស្លែងឡើងគឺថា ខ្ញុំទឹកភ្នែកហូរមកឯង ឲ្យតែគេនិយាយរឿងគុកស្លែងហ្នឹង ទឹកភ្នែកហូរមកឯង គឺអត់ដែលខាងថ្ងៃណាទេ ឲ្យតែឮសួរគេនិយាយរឿងស-២១ រឿងគេធ្វើទារុណកម្មអីហ្នឹង វាមិនដឹងជារឿងរ៉ាវអី ខ្ញុំចេះតែហូរទឹកភ្នែកមកឯកឯងតែម្តងហើយអារម្មណ៍របស់ខ្ញុំហ្នឹង ខ្ញុំនឹកថា ខ្ញុំទៅថ្ងៃមុខទៅ អារម្មណ៍របស់ខ្ញុំប្រហែលជាមិនមែនជាមនុស្សទេមិនដឹង បានជាទឹកភ្នែកហូរមកមិនចេះមិនចេះហើយ ហើយខ្ញុំក៏ទៅសួរខាង *ធីភីអូ (TPO)* គាត់តែងតែនិយាយប្រាប់ខ្ញុំ គាត់ថា “មកពីអ៊ំឯងមានការក្រេវក្រោធខឹងច្រើន អីច្រើន ក្នុងរបបខ្មែរក្រហមហ្នឹង” គាត់ថាឲ្យយើងរំសាយខ្លះទៅ ហើយខ្ញុំក៏ចេះតែយកពាក្យសម្តីគាត់ហ្នឹងទៅនេះទៅ ដូចជានៅតែដដែលទេលោកក្ដួយ វានៅតែទឹកភ្នែកហូរមករាល់តែយប់អ៊ីចឹង ។

[១៤:១៨:២២]

**ស៖** សូមលោកពូសម្រួលអារម្មណ៍បន្តិច ដើម្បីឆ្លើយនឹងសំណួរខ្ញុំ ព្រោះយើងមានពេលខ្លី ខ្ញុំបាទក៏មិនចង់សួរវំពុកឲ្យទាក់ទងនឹងអារម្មណ៍ដែលទប់មិនបាននេះដែរ ។ អ៊ីចឹងសំណួរមួយទៀតខ្ញុំសួរថា មកដល់សព្វថ្ងៃនេះ លោកពូមានសេរីភាព លោកពូអាចដើរហើរ អាចនិយាយស្តី អាចទៅណាមកបាន ។ នៅពេលដែលលោកពូត្រឡប់ទៅទួលស្លែងជាញឹកញាប់វិញនោះ តើលោកពូមានអារម្មណ៍ថាលោកពូហ្នឹងមានសេរីភាពអ៊ីចឹងដែរ ឬក៏អារម្មណ៍លោកពូថាហាក់ដូចជានៅតែជាប់ឃុំៗដដែល?

**ឆ៖** បញ្ហាហ្នឹងហើយដែលខ្ញុំខំរត់រក ស្វះស្វែងជាប់ប្រហែលជាសាមសិបឆ្នាំមកហើយ ស្វះស្វែងរកសិទ្ធិមនុស្សដើម្បីឲ្យគេជួយរកយុត្តិធម៌ឲ្យខ្ញុំ ។ ពេលនោះគឺថា ខ្ញុំអត់មានសិទ្ធិមនុស្ស អត់មាននិយាយអ្វីកើតទាំងអស់ ត្រចៀកគេញ៉ុកជិត មាត់គេបិទជិតទាំងអស់ ភ្នែកគេបិទជិតទាំងអស់ អត់ឲ្យខ្ញុំឃើញអីទេ ។ ជំនាន់បីឆ្នាំប្រាំបីខែម្ភៃថ្ងៃហ្នឹង ខ្ញុំឈឺចាប់ខ្លាំងមែនទែន ក្នុងរយៈខ្ញុំចូលទៅក្នុងទួលស្លែងហ្នឹងរយៈជិតបួនខែហ្នឹង គឺថាខ្ញុំវាអត់មានសិទ្ធិ អត់មានសេរីភាពនឹងនិយាយប្រាប់អ្នកណាឲ្យបានធូរចិត្តនោះគ្មានទេក្មួយ ។

**ស៖** សូមអរគុណ ។ សំណួរមួយទៀត ដើម្បីបន្តទៅមេធាវីអន្តរជាតិ ខ្ញុំសូមសួរសំណួរចុងក្រោយ ទៅលោកពូថា ដូចជាថយក្រោយបន្តិច ក្រោយពេលដែលខាងពួកធ្វើទារុណកម្មដកកញ្ចកលោកពូហើយ គេបញ្ជូនត្រឡប់មកដេកនៅក្នុងបន្ទប់តូចលោកពូវិញ លោកពូឈឺចាប់ លោកពូយំ ឬលោកពូចង់ស្រែក ។ សំណួរខ្ញុំសួរថា លោកពូហ៊ានយំឲ្យគេឮ ហ៊ានស្រែក ឬថ្ងូរឲ្យគេឮដែរទេ? និយាយរួមមានសិទ្ធិនិយម និងនិយាយ ឬថ្ងូរដែរឬទេ?

**ឆ៖** ជម្រាបលោកមេធាវី! ពេលនោះកុំសូម្បីដល់យំ គ្រាន់តែយើងខ្សិបខ្សៀវគ្នាអីហ្នឹង ក៏មិនបានផង គ្រាន់តែឮអីរឹងហ្នឹងក៏អត់បានដែរ ។ យើងយំក៏មិនហ៊ានយំឲ្យគេឮដែរ ។ ប៉ុន្តែ ខ្ញុំវាអស់ពេលយំ វាអស់ទឹកភ្នែកនឹងយំទៀត វាអត់មានទឹកភ្នែកសម្រក់មកទៀត អស់រលីងហើយ ។ ខ្ញុំរង់ចាំតែថ្ងៃស្លាប់ទេ រាល់ថ្ងៃហ្នឹងខ្ញុំដេកចាំតែថ្ងៃស្លាប់ទេ ។

[១៤:២០:៥៦]

**លោក ហុង គីមសួន៖**

សូមអរគុណ ។ លោកប្រធានសូមអនុញ្ញាតបន្តសំណួរទៅឲ្យខាងមេធាវីអន្តរជាតិបន្តទៀត ។

សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញមេធាវីអន្តរជាតិ ។

**សួរដោយលោកស្រី ស៊ីលឃី ស្ទូតហ្វ៊ីនស្គី៖**

សូមអរគុណលោកប្រធាន ហើយសួស្តីលោក ជុំ មី ។ ខ្ញុំមានសំណួរមួយចំនួនតូចតែប៉ុណ្ណោះ ហើយខ្ញុំចង់ចាប់ផ្តើមសួរអំពីបន្ទប់នានាដែលយើងបានឃើញពីការសម្តែងឡើងវិញ ។

**ស៖** តើលោកអ៊ំអានពន្យល់បន្ថែមអំពីចំណុចនេះដែរឬទេថា តើអ៊ំមានស្ថានភាពយ៉ាងម៉េចនៅពេលដែលនៅក្នុងបន្ទប់នោះ ថាតើទំហំបន្ទប់នោះវាមានទំហំប៉ុនណាដែរ? សូមឲ្យអ៊ំធ្វើការបកស្រាយបន្ថែមទៅលើចំណុចនេះ ។ សូមអរគុណ ។

**ឆ៖** ជម្រាបប្រសាសន៍លោកស្រីមេធាវី នៅក្នុងបន្ទប់ឃុំឃាំងនេះ គឺថាខ្ញុំចូលទៅ វាមានកែសគ្រាប់មួយ ហើយនិងប៊ីដុងបួនលីត្រមួយ ។ កែសគ្រាប់ហ្នឹងគេប្រាប់ថា ឲ្យយើងបត់ជើងធំដាក់នៅហ្នឹង ហើយប៊ីដុងជ័រហ្នឹងឲ្យនោមដាក់នៅហ្នឹង ហើយគេប្រាប់ បើកាលណាបើបត់ជើងពេញទៅ ឲ្យប្រាប់អ្នកយាម ។ ហើយបន្ទប់នុ៎ងគឺថា បណ្តោយប្រហែលជាពីរម៉ែត្រជាង ទទឹងប្រហែលជាមួយម៉ែត្រដែរ ។

**ស៖** ថាតើមានឆ្មាំយាមនៅខាងមុខបន្ទប់របស់លោកអ៊ំដែរឬទេ? ឧទាហរណ៍ថា បើសិនជាលោកអ៊ំចង់ញ៉ាំទឹក ឬក៏យកប្រអប់ក្របនោះ ថាតើយ៉ាងម៉េចដែលមានឆ្មាំយាមនៅខាងមុខបន្ទប់នោះដែរទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺថាគេនៅយាមជាប់នៅហ្នឹង គឺបើកាលណាយើងស្រេកទឹកហ្នឹង គឺថាយើងសុំគេទៅ គេឲ្យប៉ុន្មាន យើងហូបប៉ុណ្ណឹងទៅ យើងអត់មានថា អូ៎! ហូបមិនឆ្អែតហើយយើងសុំទៀត អត់ទេ អត់ហ៊ានសុំគេទេ គេឲ្យកន្លះកែវ ហូបកន្លះកែវទៅ គេឲ្យមួយកែវ ហូបមួយកែវទៅក្តួយ អត់មានហ៊ានសុំគេទៀតទេ ។

**ស៖** អ៊ីចឹងការចាប់អារម្មណ៍របស់លោកអ៊ំ គឺថា អ្នកយាមនោះនៅខាងក្រៅបន្ទប់របស់លោកអ៊ំ ឬក៏លោកអ៊ំត្រូវស្រែកឲ្យខ្លាំងៗ ដើម្បីឲ្យអ្នកយាមនោះឮ?

[១៤:២៤:១០]

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! កាលណាយើងស្រេកទឹកអ៊ីចឹង យើងស្រែកថា "បងអើយបង សូមទឹកបន្តិចមក ខ្ញុំស្រេកទឹកណាស់" អ៊ីចឹងទៅ គេដើរមក គេដួសទឹកកន្លះកែវមកឲ្យយើងអ៊ីចឹង យើងហូបទៅ ហើយហូបឆ្អែតមិនឆ្អែតអីយើងនៅតែស្ងៀមទៅ ។

**ស៖** ថាតើបន្ទប់នោះវាងងឹតគ្រប់ពេលទាំងអស់ ឬក៏នៅក្នុងបន្ទប់នោះមានពន្លឺភ្លើងដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! បន្ទប់នោះគឺថា អត់មានពន្លឺភ្លឺអ្វីទេ គឺថា ងងឹតជាប់រហូត អត់មានពន្លឺទេ ។ ព្រោះបង្អួចគេបិទជុំវិញទាំងអស់ អត់ឲ្យមានពន្លឺចេញមកក្រៅទេ យប់ក៏អ៊ីចឹង ថ្ងៃក៏អ៊ីចឹងគេបិទជិតទាំងអស់ ។

**ស៖** ថាតើលោកអ៊ំចាប់ពីថ្ងៃនេះទៅ ប្រសិនបើលោកអ៊ំត្រឡប់មើលត្រឡប់ទៅវិញ មើលត្រឡប់ទៅអតីតកាល ថាតើលោកអ៊ំដឹងថា លោកអ៊ំនៅក្នុងបន្ទប់ គេប្រាប់អ៊ំថានៅក្នុងបន្ទប់នោះរយៈពេលប៉ុន្មាន?

**ឆ៖** ដែលខ្ញុំនៅក្នុងបន្ទប់គេរៀបឥដ្ឋហ្នឹង រយៈពេលតែដប់ពីរថ្ងៃ ដប់ពីរយប់ទេ ក្រោយមកបានគេយកទៅដាក់បន្ទប់រួមនៅខាងលើរហូតទាល់តែបែកភ្នំពេញតែម្តង ។

**ស៖** ខ្ញុំមានសំណួរបន្ថែមមួយទៀត ចំពោះអ្នកសួរចម្លើយ លោកអ៊ំបានរៀបរាប់ឈ្មោះហើយ ហើយគេមកយាមពេលខុសគ្នា គឺខ្ញុំចង់ដឹងអំពីបុគ្គលម្នាក់ដែលគាត់នៅក្នុងបន្ទប់សួរចម្លើយ ថាតើមានអ្នកសួរចម្លើយម្នាក់ ឬក៏មានច្រើនម្នាក់ក្នុងពេលសួរចម្លើយនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! គឺថាមានតែម្នាក់ទេ គឺថា មិត្តសេង ហ្នឹងតែម្តង ។ មិត្តសេង ហ្នឹង សួរផង វ៉ៃអង្គុលីលេខហ្នឹងផង ។

**ស៖** នៅពេលដែលគេវ៉ៃលោកអ៊ំ ថាតើគាត់នៅម្នាក់ឯង ឬក៏គាត់នៅជាមួយអ្នកផ្សេងទៀត នៅក្នុងបន្ទប់សួរចម្លើយនោះ? គឺហ៊ា នៅពេលដែលហ៊ា នោះចូលមកសួរចម្លើយនោះ គាត់នៅម្នាក់ឯងក៏មានគេមកនៅជាមួយគាត់ដែរ នៅពេលសួរចម្លើយ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! នៅពេលនោះគឺថា ខ្ញុំនៅតែពីរនាក់មិត្តសេង ហ្នឹងទេ មិត្តសេងដែលសួរចម្លើយខ្ញុំហ្នឹង ពេលដែលឃើញមិត្ត ហ៊ា ហ្នឹងចូលមកគឺថា មិត្តសេងហ្នឹងគាត់ប្រាប់ថា បងឯងមើលអាហ្នឹងវាអត់ព្រមទេ បងឯងមើល ។ និយាយប្រាប់មិត្តហ៊ា អ៊ីចឹង មិត្តហ៊ា ហ្នឹងក៏ម្ងរដៃអាវចូលមកតែម្តង ។ ចូលមកទាញរំពាត់ហ្នឹងវ៉ៃខ្ញុំផ្ទូងៗៗតែម្តង ។ បាក់អស់ហើយរំពាត់មួយ បានទៅយករំពាត់មួយទៀត ។ ហើយរំពាត់ហ្នឹងមិនមែនតែមួយពីរអីទេ គឺថាមួយបាច់ដាក់នៅជិតតុហ្នឹងតែម្តង មួយបាច់ធំដាក់នៅជិតតុហ្នឹងតែម្តង ។

**ស៖** សូមអរគុណ។ ខ្ញុំហាក់ជាហៅវាថា គឺជាការ គឺហ៊ា ធ្វើការគ្រប់គ្រង ហើយធ្វើការចូលអន្តរាគមន៍វ៉ៃលោកអ៊ំ ដើម្បីយកចម្លើយសារភាព ដូច្នេះហ៊ាគាត់ធ្វើការគ្រប់គ្រងទៅលើការសួរចម្លើយ

នោះ ដើម្បីធ្វើយ៉ាងណាទាញយកចម្លើយសារភាព ដូចជាការវ៉ៃអ៊ំជាដើម ។

**ឆ៖** ជម្រាបប្រសាសន៍! ខ្ញុំដូចជាស្តាប់អត់ទាន់បានទេ ស្តាប់អត់បានទេចុងចម្លើយនោះ ។ សូមសំណួរម្តងទៀតមើល ។

**ស៖** តើខ្ញុំនិយាយត្រឹមត្រូវដែរឬទេ? លោកបាននិយាយថា ហ៊ី ចូលមកក្នុងបន្ទប់នោះ ហើយគាត់ធ្វើការតាមដាន និងត្រួតពិនិត្យថាតើលោកអ៊ំផ្តល់ចម្លើយសារភាពគ្រប់គ្រាន់ហើយឬនៅ? ហើយគាត់ចូលមកដើម្បីធ្វើការ ធ្វើអន្តរាគមន៍នៅពេលនោះ ដូចជាធ្វើការវ៉ៃអីជាដើម ។

[១៤:២៩:៤៥]

**ឆ៖** ចម្លើយនេះគឺថាខ្ញុំពិបាកនឹងនេះដែរ ព្រោះថាមិនដឹងគេចូលមកគេពិនិត្យចម្លើយហ្នឹង ឬក៏យ៉ាងម៉េចអីយ៉ាងម៉េច ខ្ញុំមិនសូវដឹងដែរ តែពេលនុ៎ងគឺថា មិត្តសេង គាត់និយាយប្រាប់មិត្តហ៊ី ហ្នឹងគឺថាមិត្តហ៊ីហ្នឹងគឺថា គាត់ស្ទុះមកយករំពាត់វ៉ៃខ្ញុំតែម្តង ហើយមើលមុខ មិត្តហ៊ី ហ្នឹង ក៏មិនចង់ប៉ានមើលផងមនុស្សនុ៎ងមាឌធំ ហើយនិងខ្ពស់ ហើយពេលដែលវ៉ៃហើយនឹងគាត់រៀបចេញទៅហ្នឹង គាត់ពន្យល់ប្រាប់ខ្ញុំផងទៀត គាត់ថា "អ្អែងមើល៉ អញហ្នឹងហើយឈ្មោះ អាហ៊ី អ្អែងមើល៉ឲ្យច្បាស់ តែសម្គាកនៅនែ៎ ។ ថ្ងៃក្រោយអ្អែងយ៉ាងម៉េចៗ អ្អែងមើលតែសម្គាកអញដឹងហើយ" ។ គាត់គ្រាន់តែប្រាប់តែប៉ុណ្ណឹង គាត់ដើរចេញទៅ ។

**ស៖** សូមអរគុណ ។ ថាតើវាជាពេលតែម្តងទេ ដែល ហ៊ី នោះ គឺគាត់ចូលទៅបន្ទប់តែម្តងទេក្នុងរយៈពេលដប់ពីរថ្ងៃនោះ?

**ឆ៖** បាទ, ជម្រាបប្រសាសន៍លោកស្រី គាត់ចូលទៅតែម្តងទេ ។

**ស៖** សំណួរបន្ទាប់របស់ខ្ញុំ គឺទាក់ទងទៅនឹងពេលដែលលោកអ៊ំចេញពីបន្ទប់តូចនោះ ហើយនៅពេលដែលលោកអ៊ំចាប់ផ្តើមធ្វើការងារនៅក្នុងរោងជួសជុលម៉ាស៊ីន ។ ខ្ញុំចង់ដឹងថា នៅពេលដែលលោកអ៊ំចាប់ផ្តើមធ្វើការងារជួសជុលរហូតដល់ពេលចុងក្រោយ ដែលលោកចាកចេញពីទួលស្លែងនោះ ។ ថាតើលោកអ៊ំមានទទួលការគំរាមកំហែង ឬទទួលរងការវ៉ៃតប់ និងមើលងាយដោយបុគ្គលិកផ្សេងៗ ឬក៏អ្នកយាមនៅស-២១ ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ពេលនោះ ខ្ញុំចេញធ្វើការហើយហ្នឹង គេមិនដែលមកធ្វើបាបខ្ញុំអីទៀតទេ គ្រាន់តែថា ពេលថ្ងៃអ៊ីចឹង ព្រលឹមឡើងគេបញ្ចេញឲ្យទៅធ្វើការនៅក្រោយទៅ ពេលយប់គេហៅមកដាក់ខ្នោះនៅបន្ទប់រួមខាងលើហ្នឹង ជារៀងរាល់ថ្ងៃអ៊ីចឹង ។ គេអត់មានដែលធ្វើទារុណកម្មអីខ្ញុំ

ទៀតទេ គ្រាន់ពេលដែលរៀបដាច់ហើយហ្នឹង ខ្ញុំចូលមកក្រោយគេហ្នឹង គេរកបាញ់ចោល អាពេលហ្នឹងហើយ ដែលខ្ញុំជម្រាបលោកចៅក្រមនោះ ។

**ស៖** សូមអរគុណលោក ជុំ ម៉ី ។ ខ្ញុំនៅមានសំណួរចុងក្រោយមួយទៀត ។ ខ្ញុំចង់ដឹងថាតើសំណួរមួយណាដែលលោកអ៊ំចង់សួរទៅកាន់ជនជាប់ចោទ? សូមឲ្យលោកអ៊ំជម្រាបអង្គសវនាការថា តើសំណួរមួយណាដែលជាសំណួរឈឺចាប់ ហើយលោកអ៊ំចង់សួរទៅកាន់ជនជាប់ចោទ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី សំណួរដែលចង់សូមលោកប្រធានដើម្បីសូមសួរទៅលោក ឌុច ហ្នឹង គឺថា សំណួរបញ្ហារឿង *សេអ៊ីអា* ។ ហើយព្រមទាំងអង្គការហ្នឹង គឺថា ខ្ញុំបាទមានតែពីរសំណួរនឹងសួរទៅលោក ឌុច តែពីរសំណួរហ្នឹងទេ ។

**សួរដោយប្រធានអង្គជំនុំ៖**

**ស៖** អ៊ំចង់សួរសំណួរថាម៉េច?

**ឆ៖** ឌុច ហ្នឹង តើ *សេអ៊ីអា* ហ្នឹង ដែលចោទខ្ញុំថា ខ្ញុំជា សេអ៊ីអា ហ្នឹង តើ *សេអ៊ីអា* ហ្នឹង អស់ហើយនៅ? ១៦០០០នាក់ហើយនឹង តើ *សេអ៊ីអា* ហ្នឹង អស់ហើយនៅ? ខ្ញុំចង់សួរគាត់ប៉ុណ្ណឹង ឬក៏នៅមួយលាននាក់ទៀត?ហ្នឹងទីមួយ ។ ទីពីរ ខ្ញុំចង់សួរសំណួរគាត់ថា អង្គការៗហ្នឹង អង្គការយ៉ាងម៉េច? ព្រោះតាមដែលខ្ញុំរាល់ថ្ងៃ ខ្ញុំទៅទួលស្លែងរាល់ថ្ងៃ មាននិស្សិតខ្លះគេសួរខ្ញុំថា អង្គការហ្នឹងស្អី? ហើយខ្ញុំរកឆ្លើយប្រាប់គេមិនបានទេ ។ ហើយគេសួរថា ប៉ុល ពត ហ្នឹង អ្នកណាគេ? ខ្ញុំក៏មិនបានជម្រាបក្មួយៗទាំងអស់នោះដែរ ព្រោះខ្ញុំ ប៉ុល ពត ហ្នឹង ខ្ញុំមិនកំណត់ថា ប៉ុល ពត ហ្នឹងជាខ្មែរក្រហមក៏មិនដឹង ឬក៏ប៉ុល ពត ហ្នឹងអ្នកណាក៏មិនដឹង ។ ខ្ញុំអត់ប៊ានជម្រាបក្មេងៗឲ្យដឹងជាប្រវត្តិសាស្ត្រនេះទេ ។

**ស៖** អ៊ំចង់សួរគាត់បីសំណួរ ឬក៏ពីរសំណួរ ព្រោះសំណួរមានថា ប៉ុល ពត ជាអ្នកណាគេ ។ តើអ៊ំ ចង់សួរទេ?

**ឆ៖** ទេក៏ប៉ុន្តែអារឿង កូនសិស្សវាសួរខ្ញុំ ហើយខ្ញុំរកឆ្លើយប្រាប់គាត់អត់បាន ។

**ប្រធានអង្គជំនុំ៖**

ជនជាប់ចោទ អាចឆ្លើយនឹងសំណួរនេះបានទេ? សំណួរគាត់សួរថា ការចោទប្រកាន់ទៅគាត់ថាជាភ្នាក់ងារ សេអ៊ីអា គាត់សួរថា តើ សេអ៊ីអា ហ្នឹង ដល់ពេលនេះហ្នឹង អស់ហើយឬនៅ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! ជម្រាបប្រសាសន៍បង ម៉ី ខ្ញុំសូមបញ្ជាក់ថា ពាក្យ “សេអ៊ីអា”

នេះបងមកអង្គុយខ្ញុំយូរហើយ ជាពាក្យគេដែលរៀបចំសម្រាប់តែកំណត់ទៅលើឈ្មោះណាដែលប្រឆាំងនឹងគេប៉ុនន៎ុង ។ មិនមែន សេអ៊ីអា នេះ ស៊ីប្រាក់ខែអាមេរិក មានការចាត់តាងពីសហរដ្ឋអាមេរិកអីត្រឹមត្រូវទេ ។ ក្នុងន័យថា អ្នកប្រឆាំងនឹងបក្សកុម្មុយនីស្តកម្ពុជាមកដល់ថ្ងៃ៧ មករា នេះវាអត់ចប់ទេ នៅ ។ គឺអ្នកប្រឆាំងហ្នឹងឯង ដែលឈ្មោះបក្សកុម្មុយនីស្តកម្ពុជា ។ ដូច្នេះ សេអ៊ីអា យើងនិយាយ សេអ៊ីអា វាត្រូវយកបញ្ហានេះ *សេអ៊ីអា* ពិតប្រាកដរបស់គេវាផ្សេង ។ សេអ៊ីអា ដែលបក្សកុម្មុយនីស្តកម្ពុជាកំណត់សម្រាប់ចាប់ចងនោះវាផ្សេង ។ សេអ៊ីអា ដែលបក្សកុម្មុយនីស្តកំណត់សម្រាប់ចាប់ចង មានចាប់ចងបងជាដើមនេះ គឺកំណត់អ្នកណាដែលប្រឆាំងនឹងគេ ឬមានចម្លើយឆ្លើយ ដាក់ប្រឆាំងតិចតួច ឬក៏មានចម្លើយឆ្លើយដាក់គេចាប់ហើយ ។ ដូច្នេះ សេអ៊ីអា អ្នកដែលប្រឆាំងនឹងគេនឹងហើយ ដែលឈ្មោះបក្សកុម្មុយនីស្តកម្ពុជានោះ ដូច្នេះវាអត់អស់ទេ វាឈ្មោះៗបក្ស កុម្មុយនីស្តកម្ពុជាបាត់ទៅហើយ ។ នេះខ្ញុំសូមបញ្ជាក់ជូនប៉ុណ្ណឹង សំណួរទីមួយ ។

[១៤:៣៧:៤១]

**ប្រធានអង្គជំនុំ៖**

សំណួរទីពីរ គាត់សួរថា ឲ្យលោកជនជាប់ចោទហ្នឹង ពន្យល់ពាក្យថា តើអង្គការជាអ្វីទៅ?

**ជនជាប់ចោទ៖**

សូមអរគុណលោកប្រធាន ។ ខ្ញុំសូមជម្រាបបង ម៉ី ថា អង្គការហ្នឹងសម្រេចអចិន្ត្រៃយ៍មជ្ឈិមបក្ស ។ ក្នុងអចិន្ត្រៃយ៍មជ្ឈិមបក្សគ្នាគេហ្នឹង គេហៅ ប៉ុល ពត ថាអង្គការ ។ ឯចំណែក យើងខ្ញុំដែលធ្វើការនៅស-២១ នេះ ហៅ សុន សេន ថា អង្គការ ពីព្រោះតំណាងឲ្យអចិន្ត្រៃយ៍មជ្ឈិមបក្សមកដឹកនាំស-២១ ។ នេះ ខ្ញុំសូមឆ្លើយប៉ុណ្ណេះ ។

**ប្រធានអង្គជំនុំ៖**

មេធាវី តើមានសំណួរអ្វីទៀតទេ? ស្ទួតហ្សីនស្ដី?

**លោកស្រី ស៊ីលឃីស្ទួត ហ្សីនស្ដី៖**

សូមអរគុណលោកប្រធាន ។ ចំពោះក្រុមចម្បងរបស់ខ្ញុំនេះ យើងខ្ញុំមិនមានសំណួរទៀតទេ ដូច្នេះហើយ ខ្ញុំសូមផ្ដល់វេទិកានេះជូនសហសេវិករបស់ខ្ញុំ ។ សូមអរគុណ ។

**សួរដោយលោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមគោរពលោក លោស្រីចៅក្រម និងសូមសួរស្ដីលោក ជុំ ម៉ី ។ ខ្ញុំសូមសួរសំណួរមួយចំនួនដូចតទៅ គឺទាក់ទងទៅនឹងពេលដែលលោកត្រូវបានគេឃុំខ្លួននៅស-២១ ។

**ស៖** សំណួរទីមួយ នៅពេលដែលគេឃុំលោកនៅស-២១ ថាតើលោកអ៊ំ មានអារម្មណ៍ថា អ្នកយាម អ្នកសួរចម្លើយ ឬក៏បុគ្គលិកផ្សេងៗទៀតរបស់ ស-២១ មានអារម្មណ៍ភ័យខ្លាច ឬក៏គាត់មានអារម្មណ៍តក់ស្លុតដែរឬទេ?

[១៤:៣៩:៤២]

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី នៅស-២១ រយៈជិតប្អូនខែហ្នឹង ខ្ញុំបាទមិនប៉ាន់មើលមុខគេទេ ដើរល្វោករហូត អត់ប៉ាន់មើលមុខគេទេ ។ ហើយនៅក្នុងរយៈដប់ពីរថ្ងៃដប់ពីយប់ហ្នឹង គឺថា មកពីអគារខាងត្បូងមក គេចងមុខជាប់ មកដល់បន្ទប់ហ្នឹងហើយបានគេស្រាយមុខចេញ ។ ពេលយកទៅគេចង មុខជាប់ ដាក់ខ្នោះជាប់ ហើយអាពេលឡើងជណ្ដើរទៀត គេទាញស្លឹកត្រចៀកខ្ញុំចង់រហែកស្លឹកត្រចៀក ។ ទាញឡើងលើអ៊ីចឹង ដល់អាពេលចុះមកគេស្រែក “អ្ហែងចុះក្រោម” ចុះក្រោមទាញស្លឹកត្រចៀកចុះមកក្រោមអ៊ីចឹង ។ ម្ល៉ោះហើយអារម្មណ៍របស់ខ្ញុំភ័យខ្លាចមែនទែន ខ្ញុំអត់ប៉ាន់មើលមុខគេទេបាទ ។

**ស៖** សំណួរ នៅពេលដែលគេឃុំលោកអ៊ំនៅស-២១ ថាតើលោកអ៊ំ ដែលឮអ្នកសួរចម្លើយ ឬក៏អ្នកយាមពួកគាត់ហ្នឹង គឺសើច និងសប្បាយរីករាយក្នុងចំណោមពួកគេដែរឬទេ? ឬក៏លោកអ៊ំ មានអារម្មណ៍ថា ការកើតឡើងនៃការភ័យខ្លាចគ្រប់ទាំងអស់នៅក្នុងទីន្លែងនោះ ចំពោះពួកគេទាំងអស់នោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ពេលនោះ គឺថា ខ្ញុំនៅធ្វើការខាងក្រោយហ្នឹង អ្វីៗខ្ញុំឮទាំងអស់ ពេលដែលគេសើចៗទៅ ។ ពេលដែលមានអ្នកទោសយំក៏យំទៅ ដូចតែគេសប្បាយនឹងអាគេយំហ្នឹង សប្បាយនឹងធ្វើទារុណកម្មគេនឹងយ៉ាងមើលទៅបានគេសើចក្អាកក្អាយពេញទ្រនុំងទាំងអស់ ។ ជម្រាបប្រសាសន៍ហើយ ខ្ញុំមានបានមួយចំណុចទៀត ដូចលោក ឌុច គាត់មានប្រសាសន៍គាត់ថា គាត់អត់បានឮ គឺខ្ញុំអត់ជឿទេបាទ ខ្ញុំអត់ជឿទេ ។ ព្រោះខ្ញុំនៅដល់ក្រោយ មិនមែនជិតទេ នៅក្រោយ ខ្ញុំឮយំ ឮស្រែកជេ ទ្រហឹងអឺងអាប់ពេញហ្នឹង ។ លើកលែងតែពេលថ្ងៃសម្រាក ដូចថា ចប់ម៉ោងដប់មួយទៅ គេសម្រាកដល់រហូតដល់ម៉ោង១ បានចាប់ផ្ដើមធ្វើការ ។ អាហ្នឹង ចាប់ផ្ដើមឮទៅទៀតហើយក្អួយ ។

**ស៖** សូមអរគុណ ។ សំណួររបស់ខ្ញុំបន្ទាប់ទៀត នៅពេលដែលគេឃុំលោកអ៊ំ នៅក្នុងបន្ទប់រួមជាមួយអ្នកទោសផ្សេងទៀត ថាតើលោកអ៊ំដែលឃើញអ្នកទោសត្រឡប់ចូលក្នុងបន្ទប់រួមនោះវិញដែរ

ឬទេ ក្រោយពីពួកគេត្រូវបានយកទៅសួរចម្លើយ ហើយនិងធ្វើទារុណកម្មរួចហើយនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ខ្លះក៏មានឃើញចូលមកវិញអ៊ីចឹងដែរ មិនចេញបាត់រហូត ឃើញមុខដដែលៗហ្នឹងខ្លះដែរ ខ្លះក៏បាត់មុខទៅ ។ វាមិនទៀងទេ ជួនកាលឃើញអ្នកដដែល ជួនកាលអត់ឃើញទេ ស្រាប់តែបាត់ឈឹងរហូតតែម្តង ។

[១៤:៤៣:០៩]

**ស៖** សំណួរបន្ទាប់នៅពេលដែលលោកអ៊ុំខ្លួនឯង ត្រូវបានគេឃុំខ្លួននៅក្នុងបន្ទប់រួម បន្ទាប់ពីត្រូវបានគេសួរធ្វើទារុណកម្មទៅលើលោកអ៊ុំ ថាតើលោកបានពន្យល់ទៅអ្នកទោសដែលនៅជាប់លោកអ៊ុំដែរឬទេ? ថាមានអ្វីកើតឡើងចំពោះលោកអ៊ុំ ឬក៏លោកអ៊ុំខ្សឹបអ្នកជិតអ៊ុំទេ ថាតើគេធ្វើអ្វីខ្លះចំពោះលោកអ៊ុំ និងធ្វើទារុណកម្មអ្វីខ្លះចំពោះលោកអ៊ុំនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ពេលនោះគឺថា ខ្ញុំអត់មាននិយាយអីឆ្លើយឆ្លង ទំនាក់ទំនងស្អីណានឹងអ្នកនេះទេ គឺថាពេលថ្ងៃមួយនោះ ខ្ញុំឮសួរឡានប្រហែលជាម៉ោងដប់មួយ ដប់ពីរហើយ សួរអ្នកជាប់ជាមួយគ្នាហ្នឹង ។ ខ្ញុំសួរថា "ឡានហ្នឹង គេមកធ្វើអីថ្មើរហ្នឹង" ហើយដល់ហើយគេគ្រាន់តែខ្សឹប តែគេខ្សឹបមិនឲ្យពួកយាមនឹងឮទេ អាអ្នកយាមដើរនៅក្រៅទេ តែខ្សឹបនៅយើងដេកជិតគ្នាអ៊ីចឹង យើងខ្សឹបប្រាប់គ្នា ។ ខ្ញុំសួរថា "ឡានហ្នឹងគេមកធ្វើអី" ហើយគាត់ខ្សឹបប្រាប់ខ្ញុំថា "ឡានហ្នឹង គេយកមកពួកយើងយកទៅវ៉ៃនៅបឹងជើងឯក" ហើយម៉ោងដប់ពីរយប់ អាហ្នឹងគេមកយកទៅហើយ ។ អ៊ីចឹងខ្ញុំអារម្មណ៍របស់ខ្ញុំចងចាំរហូតដល់ពេលផុតម៉ោងពេលដប់ពីរ បានខ្ញុំគេងលក់ ។ អ៊ីចឹង បើផុតម៉ោងដប់ពីរ ហ្នឹងអត់ដល់ឈ្មោះខ្ញុំ ខ្ញុំរស់បានមួយថ្ងៃទៀត ។ ស្អែកយើងដេកចាំបានអ៊ីចឹងទៀត ដល់ឈ្មោះយើងឬអត់ រហូតដល់ម៉ោងដប់ពីរហ្នឹង បើអត់ដល់ឈ្មោះយើង យើងរស់បានមួយថ្ងៃទៀត ។

**ស៖** សំណួរថាតើមានការជួយគ្នា និងការសាមគ្គីគ្នាក្នុងចំណោមអ្នកទោសដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ពេលនោះ គឺថាអត់មានអ្នកណាជួយអ្នកណាបានទេ ។ អ្វីៗគឺថាមានបញ្ហាអី គឺថាស្រេចតែខ្លួនរៀងៗខ្លួនតែម្តង ។ យើងមិនអាចទៅជួយគេបានទេ ព្រោះមិនដឹងជួយធ្វើម៉េច បើជើងយើងជាប់ខ្នោះនៅហ្នឹងហើយ ហើយយើងហ៊ានតែសួរស្អីៗ បង្រាសអីៗហ្នឹងទាល់តែយើងសុំគេ ។ យើងមិនបង្រាសស្រេចតែចិត្តទេ យើងបង្រាសអីឮសួរច្រវាក់រ៉េងរ៉ុងអីហ្នឹង វាមកវ៉ៃយើងទៀតហើយ បញ្ហាហ្នឹង គឺថាអត់បានជួយគ្នា ថាអ្នកណាមានឈឺស្អីៗអ៊ីចេះ អ៊ីចុះអី អត់មានទេ អត់មានហ៊ានសួរទេ ។

**ស៖** សំណួរបន្ទាប់ ថាតើ តែងតែមានអ្នកយាមម្នាក់ដែលគាត់នៅយាមរហូតនៅក្នុងបន្ទប់រួមនោះ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! វាដើរយាមចុះឡើងៗតាមហ្នឹងរហូតអ៊ីចឹងទៅ ពេលដែលយើងស្រេកទឹកយើងស្រែកសុំទៅ ហើយគេយកទឹកទៅឲ្យទៅ គេដើរយាមតាមហ្នឹងរហូត គេមើលយើង អាយើងឡើងអង្គុយអត់បានដែរ ។ យើងឡើងអង្គុយទាល់តែយើងសុំគេទៅបាន គេឲ្យឡើងអង្គុយយើងឡើយអង្គុយបាន ។ ដល់យើងអត់សុំគេ យើងអត់ហ៊ានឡើងអង្គុយទេ ។

**ស៖** សំណួរចុងក្រោយរបស់ខ្ញុំ តើលោកអ៊ំបានដឹងដែរឬទេថា លោកអ៊ំ និងអ្នកទាំងអស់នោះ គឺជាជនរងគ្រោះ ថាតើលោកអ៊ំមានអារម្មណ៍ភ័យខ្លាចថា អ្នកដែលនៅជិតលោកអ៊ំទាំងអស់នោះ ដែលត្រូវបានគេខ្នោះនោះ គឺជាពួកជនក្បត់ទាំងអស់ដែរឬទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! កាលណាមកដល់អ៊ីចឹងហើយ បើទុកថាយើងមិនក្បត់ក៏ចូលទៅក្នុងក្បត់ដែរ អាបញ្ហាហ្នឹង គឺថាខ្នោះជាប់ជើងទៅហើយ ។ ម្តោះហើយតែមកដល់កន្លែងហ្នឹងហើយ គឺថា ដូចជាក្បត់ហើយ ដូចលោក ឌុច គាត់មានប្រសាសន៍អ៊ីចឹង ។ ឲ្យតែថា ចូលមកដល់ទួលស្លែងអត់ឲ្យរួចមួយទេ ហ្នឹងគឺថាច្បាស់ហើយអាបញ្ហាហ្នឹង ។

**ស៖** ដូច្នេះ លោកអ៊ំជាអ្នកជាប់ឃុំនៅទួលស្លែងនោះ លោកមិនដែលមានការជឿជាក់ទៅលើអ្នកទោសផ្សេងៗទៀតដែលនៅជិតលោកអ៊ំនោះទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ជឿជាក់យ៉ាងម៉េច ខ្ញុំគ្រាន់តែខ្សឹបសួរគេរឿងឡាន រឿងអីតែប៉ុណ្ណឹងទេ ។ យើងអត់មានសិទ្ធិទៅនិយាយស្អីៗណា ពាសទឹកពាសដីតិចតួចក្តីអត់មានជឿជាក់មិនជឿជាក់ទេអាបញ្ហាអស់ហ្នឹង យើងអត់ហ៊ានសួរគេចំហអី ម៉េចមូលហេតុអីបានជាប់? គេយកមកដាក់អីនៅហ្នឹង? អត់ហ៊ានសួរគេទេ ព្រោះគេនៅជាប់នៅនឹងតែម្តង គេដើរមើលយើងរហូតអត់មានព្រិចភ្នែកទេ ។

**លោកស្រី ម៉ាទីន ហ្សាកកាំង៖**

សូមអរគុណលោក ជុំ ម៉ី ។

**ប្រធានអង្គជំនុំ៖**

ម៉ោងសម្រាប់មេធាវីការពារក្តីអស់ហើយ ចាយអស់ហើយ ។ អង្គជំនុំជម្រះប្រកាសសម្រាកម្ភៃនាទីរហូតដល់ម៉ោងបីនិងដប់នាទី សូមអញ្ជើញចូលមកវិញ ដើម្បីបន្តដំណើរការសវនាការតទៅទៀត ។

ហើយមន្ត្រីតុលាការសម្របសម្រួលរកកន្លែងសមរម្យសម្រាប់អ៊ំ ជុំ ម៉ី សម្រាប់បានសម្រាក ។

*[សវនាការសម្រាកពីម៉ោង ១៤:៥០នាទី ដល់ម៉ោង ១៥:១១នាទី]*

**ប្រធានអង្គជំនុំ៖**

សូមអញ្ជើញអង្គុយចុះ ។ អង្គជំនុំជម្រះប្រកាសបន្តកិច្ចដំណើរការនីតិវិធីសវនាការដេញដោលតទៅទៀត ។ មុនពេលសម្រាកអំមិញដូចជាឃើញមេធាវីជាតិ ខាងក្រុមមួយលើកដៃ តើចង់មានកត់សម្គាល់អ្វីទៅ?

**កញ្ញា ទី ស្រ៊ីនណា៖**

សូមគោរពលោកប្រធាន ហើយនិងសូមអរគុណលោកប្រធានដែលបានផ្តល់ឱកាសឲ្យខ្ញុំបញ្ចេញយោបល់ ការពិតទៅអ្វីដែលនាងខ្ញុំបានឡើងមកលើកដៃមុនពេលឈប់សម្រាកហ្នឹង គឺនាងខ្ញុំចង់សុំការអនុញ្ញាតលោកប្រធាន ដើម្បីសាកសួរទៅលោកពូ ជុំ ម៉ី ពីរសំណួរ ដោយនាងខ្ញុំបានដឹង ហើយថាពេលវេលារបស់ខាងដើមបណ្តឹងរដ្ឋប្បវេណីអស់ហើយ ក៏ប៉ុន្តែ គ្រាន់តែចង់សុំសួរពីរសំណួរ ព្រោះសំណួរទីមួយដែលទាក់ទងទៅនឹងព្រឹត្តិការណ៍ដែលលោកពូ ជុំ ម៉ី ហ្នឹងគាត់បានជួបនៅពេលដែលគាត់បានធ្វើដំណើរចាកចេញពីមន្ទីរស-២១ ។ ហើយនិងសំណួរទីពីរ នាងខ្ញុំមានបំណងចង់សួរទាក់ទងទៅនឹងចម្លើយសារភាពរបស់គាត់ដែលគាត់ចង់បញ្ជប់សកម្មភាពអំពើទារុណកម្មមកលើគាត់ហ្នឹង តើគាត់ខ្ញុំចង់ដឹងពីរចំណុចហ្នឹង ប្រសិនជាលោកប្រធានអនុញ្ញាតនាងខ្ញុំនឹងធ្វើការតាំងសំណួរ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

តាមការសម្រេចរបស់អង្គជំនុំជម្រះ គឺបានកំណត់ជាក់លាក់ហើយថា បួនក្រុមហ្នឹងមានឱកាសនូវពេលវេលាសែសិបមីនុត ក្នុងការតាំងសំណួរដល់សាក្សី ឬក៏អ្នករស់រានមានជីវិត ។ អ៊ីចឹង ប៉ុន្តែដោយសារអង្គជំនុំជម្រះកត់សម្គាល់ឃើញថា អម្បាញ់មិញនេះ គឺឱកាសក្នុងការសួរទៅអ៊ំ ជុំ ម៉ី ហ្នឹងគឺត្រូវបានសួរដោយមេធាវីភាគច្រើន គឺមេធាវីអន្តរជាតិ ហើយសួរច្រើន អ៊ីចឹង គឺអំមិញមេធាវីជាតិបានលើកដៃសុំ ហើយសួរតែពីរសំណួរទេ អ៊ីចឹងអង្គតុលាការ អង្គជំនុំជម្រះអនុញ្ញាតឲ្យមេធាវីក្រុមមួយហ្នឹងសួរពីរសំណួរតាមការស្នើសុំ ។ សូមអញ្ជើញលោក នាងមេធាវី ។

**សួរដោយកញ្ញា ទី ស្រ៊ុនណា៖**

សូមអរគុណលោកប្រធាន ដែលបានផ្តល់ឱកាសឲ្យនាងខ្ញុំបានសួរសំណួរទៅលោកអ៊ំ ជុំ ម៉ី ។ សូមជម្រាបសួរលោកអ៊ំ ជុំ ម៉ី នាងខ្ញុំសុំធ្វើការតាំងសំណួរតែពីរសំណួរ ដើម្បីកុំឲ្យនីតិវិធីកាន់តែខិតទៅមុខទៀត ហើយនិងសូមអរគុណចំពោះការឆ្លើយបំភ្លឺរបស់លោកអ៊ំ ជុំ ម៉ី ។

**ស៖** ទាក់ទងនឹងសំណួរទីមួយ នាងខ្ញុំចង់សួរទាក់ទងទៅនឹងព្រឹត្តិការណ៍ នូវព្រឹត្តិការណ៍ដែលលោកអ៊ំ បានចាកចេញពីមន្ទីរស-២១ គឺជាព្រឹត្តិការណ៍មួយដែលកងទ័ពវៀតណាមបានវាយលុកមកដល់មន្ទីរស-២១ ហើយ ជិតមកដល់មន្ទីរស-២១ ហើយពេលនុ៎ងកំពុងជាស្ថានភាពមួយដែលច្របូកច្របល់ ដែលនាំឲ្យមានៗសន្តិសុខរបស់មន្ទីរស-២១ រត់ៗគេច ដើម្បីរត់គេចពីមន្ទីរស-២១ ។ អ៊ីចឹងនាងខ្ញុំគ្រាន់តែចង់សួរលោកអ៊ំថា នៅមុនពេលដែលលោកអ៊ំចាកចេញពីមន្ទីរស-២១ តើលោកអ៊ំមានបានចូលទៅបរិវេណមន្ទីរស-២១ ដើម្បីមើលទៅតាមក្នុងបន្ទប់និមួយៗនៃមន្ទីរស-២១ នុ៎ង ថាតើ លោកអ៊ំបានជួបប្រទះនូវព្រឹត្តិហេតុអ្វីខ្លះ ដូចជាបានឃើញសាកសពនៅតាមបន្ទប់ ឬក៏មាន លោកអ៊ំមានឱកាសបានចូលទៅមើលដែរ ឬក៏យ៉ាងម៉េច? សូមលោកអ៊ំជួយបំភ្លឺត្រង់ចំណុចនេះ?

[១៥:១៤:៥៩]

**ស៖** ក្មួយស្រីមេធាវី! ដែលអ៊ំមុននឹងចេញទៅពី ស-២១ ហ្នឹងធ្វើដំណើរគេឲ្យឆ្ពោះទៅអមលាំងហ្នឹង គឺថាអ៊ំមិនបានពិនិត្យតាមអាបន្ទប់ទាំងអស់ហ្នឹង អ៊ំអត់បានពិនិត្យទេ បញ្ហាហ្នឹង អគារខាងត្បូងហ្នឹង ។ តែអ៊ំចេញទៅ ចេញទៅបាត់តែម្តង គឺថាអត់បានពិនិត្យទេ ហើយអ៊ំទៅរហូតអ៊ីចឹងទៅវិលត្រឡប់មកវិញ វិលត្រលប់មកវិញមានពេលមួយនោះគេហៅអ៊ំមកថតនៅហ្នឹងទួលស្លែងហ្នឹង ។ ដល់អ៊ំពិនិត្យទៅឃើញ គ្រែដែលគេដាក់នៅអគារខាងត្បូងហ្នឹងមានមនុស្សស្លាប់នៅលើគ្រែហ្នឹង តែអ៊ំអត់បានឃើញគំរូ ឃើញសាកសពហ្នឹងផ្ទាល់នឹងភ្នែកទេ តែឃើញតែរូបថតទេ អ៊ំអត់បានឃើញទេ ។ តែស៊ើបសួរទៅ ខ្ញុំបានសួរ លោក ប៊ុច, អ៊ឹង ប៊ុច ហ្នឹងសួរគាត់ទៅ គាត់ថារូបទាំងប៉ុន្មាននាក់ហ្នឹង គឺថានៅលើគ្រែហ្នឹង គឺថាពេលដែលវៀតណាមចូលមក ហើយគាត់ ពួកទួលស្លែងហ្នឹង គឺថាពេលគាត់ដើរអត់រួចហើយខាងខ្មែរក្រហមហ្នឹង គឺថាបាញ់កម្ទេចគាត់នៅលើគ្រែនឹងតែម្តង បាញ់សម្លាប់គាត់នៅលើគ្រែហ្នឹងតែម្តង ។ ហើយពេលនោះ គឺថាដល់ខ្ញុំមកស្តាប់ប្រសាសន៍លោក ឌុច គាត់ថាសម្លាប់តែប្អូននាក់ទេ តែដល់ក្រោយមកខ្ញុំ ទៅមើលអាកន្លែងហ្នឹងរាប់ទៅឃើញដប់ៗនាក់ជាង ដប់នាក់ ឃើញដប់នាក់ ។

**ស៖** សូមអរគុណ ។ តើមូលហេតុអ្វីបានជាលោកពូចាកចេញពីមន្ទីរស-២១ ដោយពុំបានដើរទៅមើលតាមបន្ទប់ហ្នឹង? លោកពូទៅដោយគ្នាឯងរត់ប្រទ្រុះប្រទ្រះ ឬមួយក៏ទៅតាមមានគេបង្ខំឲ្យចាកចេញ?

**ឆ៖** ព្រោះ-- ជម្រាបប្រសាសន៍ក្មួយស្រី ពេលដែលរត់ចេញទៅហ្នឹង គឺថាខ្ញុំអត់បានពិនិត្យតាមអាបន្ទប់ហ្នឹងទេ អត់បានពិនិត្យតាមបន្ទប់ហ្នឹងទេ គឺថាពេលចេញហ្នឹង គឺថាគេភ្ជង់យើងជាប់ឲ្យដើរទៅមុខដើរឲ្យត្រង់ ឲ្យដើរត្រង់ទៅមុខ តែដើរមិនត្រង់គេបាញ់ចោលហើយ ។ ហើយម្នាក់ៗសុទ្ធតែប្រឹងតម្រង់ខ្លួន តម្រង់ជួរ ដើរឲ្យត្រង់ជួរទៅ អត់ប៉ានងាកក្រោយ ងាកឆ្វេងស្ដាំអី អត់ប៉ានទេ ។

**ស៖** សូមអរគុណលោកពូ ។ ខ្ញុំសូមសួរសំណួរទីពីរ សំណួរទីពីររបស់ខ្ញុំហ្នឹង គឺនៅពេលដែលលោកពូ គេធ្វើទារុណកម្មលោកពូដើម្បីយកចម្លើយសារភាព នៅពេលនោះ តើគេសួរលោកខាងសន្តិសុខអ្នកសួរចម្លើយហ្នឹង គេសួរមកពូ ដោយគេផ្ដល់ឈ្មោះអ្នកដែលជាខ្មាំងនៅពីក្រោយខ្នងពូដែល គេចោទថាជាខ្មាំងដែលនៅពីក្រោយពូនោះ គេផ្ដល់ឈ្មោះឲ្យលោកពូឆ្លើយ ឬមួយក៏លោកពូផ្ដល់ឈ្មោះ ដោយខ្លួនឯងថា បុគ្គល “ក” ឬក៏ “ខ” ជាខ្មាំង ទៅឲ្យសន្តិសុខ អ្នកដែលសួរចម្លើយនោះដោយខ្លួនឯង ដើម្បីបញ្ឈប់ការធ្វើទារុណកម្មមកលើលោកពូ?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! ពេលនុ៎ងគឺថា យើងនៅចាំមើលអីចឹង-- ភ្លេចសំណួរហ្នឹង ហើយលោកស្រី ភ្លេចសំណួរហើយ សុំសំណួរម្ដងទៀត ។

**ស៖** អរគុណលោកពូ ។ ចាំខ្ញុំជួយសម្របសម្រួលសំណួរម្ដងទៀត សុំឲ្យខ្លី ។ ខ្ញុំគ្រាន់តែចង់សួរថា ពេលដែលគេសួរមកលើលោក ពេលដែលពូ-- ខ្ញុំចង់សួរថា ពេលដែលលោកពូ គេសួរសំណួរគេសួរ មកលើលោកពូដើម្បីឲ្យឆ្លើយថា អ្នកណាដែលនៅពីក្រោយខ្នង ដើម្បីរក-- បានន័យថាដើម្បីរុករកអ្នកដទៃទៀត គេសួរមកលើលោកពូថា អ្នកណាឈ្មោះអី ដែលជាអ្នកបញ្ជាលោកពូកអីចឹងណ៎ា ហើយអ្នកណា ជាអ្នកបញ្ជាថាឲ្យលោកពូហ្នឹងចូល *សេអ៊ីអា* អីអីចឹងលោកពូ? ហើយលោកពូជាអ្នកផ្ដល់ឈ្មោះអ្នកនុ៎ងឲ្យ គេ ឬមួយក៏គេ បានន័យថា អ្នកដែលសួរពូហ្នឹង គេផ្ដល់ឈ្មោះឲ្យលោកពូ ដើម្បីឲ្យពូឆ្លើយ?

**ឆ៖** គេមិនបានផ្ដល់ឈ្មោះឲ្យខ្ញុំទេ គឺថា គេឲ្យខ្ញុំរកនឹកឆ្លើយ ថា “គ្នាអែ្ហងមានប៉ុន្មាននាក់ចូល *សេអ៊ីអា, កាហ្សេបេ* ហ្នឹង” គឺថាគេរើសម្ដុតឲ្យនិយាយតែពីរឿង *សេអ៊ីអា, កាហ្សេបេ* ហ្នឹង បើយើងនិយាយអី ក្រៅពី *សេអ៊ីអា* គឺថាអត់បាន គឺថាគេវ៉ៃយើងទៀត ។ សួរអីឆ្លើយហ្នឹង អត់មានឲ្យឆ្លើយ

ខុសអាពីរឿងគេសួរទេ ហើយមិនឲ្យដំអក់យូរទៀត សួរភ្លាមឲ្យឆ្លើយភ្លាម ។ អាបញ្ហាហ្នឹង គឺថាពេលនុ៎ង គឺថាខ្ញុំនឹកឃើញថា ប្រហែលជាគេឆ្លើយដាក់ខ្ញុំក៏មិនដឹងអីមិនដឹងយ៉ាងម៉េច? បានជាគេចាប់ខ្ញុំ ខ្ញុំនឹកក្នុងខ្លួនខ្ញុំ ខ្ញុំអត់ធ្វើអីខុស រឿងអីគេមកចាប់ខ្ញុំស្រស់ៗអ៊ីចឹង ។ រឿងហ្នឹងហើយដែលខ្ញុំចង់ដឹងថាអារឿងៗហេតុហ្នឹងហើយ រឿង *សេអ៊ីអា, កាហ្សេបេ* ហ្នឹងវានៅប៉ុន្មានម៉ឺននាក់ ប៉ុន្មានលាននាក់ទៀតដែលខ្ញុំចង់សួរលោក ឌុច ហ្នឹង អាបញ្ហាហ្នឹង ព្រោះចាប់មនុស្ស អាមនុស្សត្រង់ទៅ សួរយកចម្លើយជំរិតឲ្យគេចូល *សេអ៊ីអា, កាហ្សេបេ* សំឡុតគេ ឲ្យឆក់ខ្សែភ្លើង ហើយនរណាទ្រាំបាន អ្នកណាក៏ត្រូវតែឆ្លើយអ៊ីចឹងដែរ ដើម្បីរករស់ ហើយបើយើងមិនឆ្លើយអ៊ីចឹងវាងាប់ ។ អាបញ្ហាហ្នឹងហើយដែលខ្ញុំចង់សួរលោកឌុច ថាឥឡូវមានប៉ុន្មានលាននាក់ ទៀតដែលចូល *សេអ៊ីអា, កាហ្សេបេ* ហ្នឹង ។ ខ្ញុំបញ្ជាក់សួរគាត់អំមិញរួចគាត់ថា អារឿងហ្នឹង រឿងខ្លាំងព្រោះ ខាងអី អង្គការលើអីឯណាគេចោទថាខ្មាំង ថាអី អាខ្មាំងហ្នឹងនៅប៉ុន្មាននាក់ *សេអ៊ីអា* ហ្នឹងមានប៉ុន្មាននាក់ វាអស់ហើយឬនៅៗ ប៉ុន្មានម៉ឺន ប៉ុន្មានលានហ្នឹង វាអស់ហើយឬនៅ ខ្មាំងហ្នឹង ។ ហើយអ្នកណាបង្កើតអារឿងៗឲ្យសួរចម្លើយរឿង *សេអ៊ីអា, កាហ្សេបេ* ហ្នឹងអាខុសអីមកពីណាក៏សួរតែរឿង *សេអ៊ីអា* ខុសអីមកពីណាក៏រឿង *សេអ៊ីអា* ហ្នឹងដែរ ។ តាមខ្ញុំឮសំឡេងប្រជាជនគាត់និយាយខ្លះសូម្បីតែបាក់អាពន្លួញនង្គ័លក៏អាហ្នឹង *សេអ៊ីអា, កាហ្សេបេ* ដែរ ។ អាខ្លះគ្រាន់តែលួចម្ទេសមួយគ្រាប់ក៏ *សេអ៊ីអា* ដំឡូងមួយមើម ក៏ *សេអ៊ីអា* ដែរសុទ្ធតែខ្មាំងហើយ អស់ហ្នឹងសុទ្ធខ្មាំងហើយ អង្គការត្រូវការកម្ទេច អ៊ីចឹងវាមិនអស់ហើយខ្មែរ ។

**ស៖** នៅពេលដែលលោកពូបានឆ្លើយហើយ តើលោកពូមានបានដឹងថា មានព្រឹត្តិការណ៍អ្វីកើតឡើងចំពោះអ្នកដែលលោកពូឆ្លើយដាក់នោះដែរឬទេ?

**ឆ៖** បញ្ហាកន្លងមកបើតាមខ្ញុំពិនិត្យទៅ គឺដូចមិនដែលមានពេលដែលខ្ញុំឆ្លើយដាក់ហ្នឹងវាដូចជាអត់មានឃើញអ្នកនេះមកទេ គឺថាវាស៊ីពេលតិចពេក អាពេលហ្នឹងគឺថារយៈពេលជិតតែបួនខែតែប៉ុណ្ណឹងទេ។

**កញ្ញា ទី ស្រ៊ុនណា៖**

សូមអរគុណលោកពូដែលបានឆ្លើយនឹងសំណួររបស់នាងខ្ញុំ ហើយនិងសូមអរគុណលោកប្រធានហើយខ្ញុំសូមអស់សំណួរប៉ុណ្ណេះ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

ជាកិច្ចបន្តនេះ សូមប្រគល់វេទិការសួរដល់លោកអ៉ំ ជុំ ម៉ី អ្នករស់រានមានជីវិតពីមន្ទីរស-២១ ដោយមេធាវីការពារក្តី បើសិនជាមានសំណួរ សូមអញ្ជើញលោកមេធាវី ។

**សួរដោយលោក ការ សាវុត្ថ៖**

សូមអរគុណលោកប្រធាន សូមគោរពក្រុមប្រឹក្សាជំនុំជម្រះ ។

**ស៖** ខ្ញុំសូមសួរ សូមលោកបញ្ជាក់មើល តើកូនក្មេងពីរនាក់ដែលលោកថា ម៉ោងប្រាំបីវាទៅរកបបរតើក្មេងនោះវាប្រុស ឬស្រី? សូមលោកបញ្ជាក់?

[១៥:២៣:២៨]

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! គឺថាក្មេងនុ៎ងមិនមែនក្មេងស្រីទេ ក្មេងប្រុសៗទេ តាមខ្ញុំបាទប៉ាន់ស្មាន អាតូចជាងគេប្រហែលជា មួយឆ្នាំជាង អាបងប្រហែលជាជាប់បីឆ្នាំហើយ ទៅរកបបររាល់ព្រឹកនៅកន្លែងនុ៎ង ។

**ស៖** សូមអរគុណ ពីព្រោះលោកមានប្រសាសន៍ថា សួរអ្នកដាំបបរទៅគេថា កូនលោក ចេង អន ពីព្រោះបើតាម បើកូនលោក ចេង អន តាមខ្ញុំដឹងកូនលោក ចេង អន ឈ្មោះ អាប៉ុច ម្នាក់ ស្រីដែលរស់សព្វថ្ងៃ នៅរស់ គឺរកស៊ីសម្អាងការនៅវាលវិញ ។ អ៊ីចឹងខ្ញុំសូមសួរសំណួរទីពីរទៀត តើអ្នកដាំបបរភេទស្រី ឈ្មោះ សុះ ដែលលោកជម្រាបពីព្រឹកមិញហ្នឹង បច្ចុប្បន្ននៅទីណា? តើលោកមានអាចដឹងបានទេ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី ខ្ញុំមិនអាចដឹងបានទេ រាល់ថ្ងៃហ្នឹង ខ្ញុំកំពុងតែតាមដានអារឿងមិត្តសុះ ហ្នឹងដែរ ព្រោះមិត្តសុះ ហើយនិងខ្ញុំ វានៅជាប់ហ្នឹងគ្នា អាធ្វើការខាងក្រោយហ្នឹងអាចង្ក្រានបាយខាងក្រោយហ្នឹង ខ្ញុំកំពុងតាមដានគាត់ដែរហ្នឹង ។

[១៥:២៤:៤៨]

**ស៖** សូមអរគុណ ។ សំណួរទីបី នៅរោងជាង ដែលលោកធ្វើការ នៅហ្នឹងរោងជាងហ្នឹង តើលោកមានដែលចងអង្រឹងនៅហ្នឹងរោងជាងហ្នឹងដែរ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! កន្លែងខ្ញុំអត់មានចងអង្រឹងនៅកន្លែងហ្នឹងទេ ។

**ស៖** សូមអរគុណ ។ បានជាខ្ញុំសួរ មានខ្លះគេថាក្មេងពីរនាក់ហ្នឹង វាដេកចងអង្រឹងនៅហ្នឹងដេកនៅហ្នឹងអ៊ីចេះ ។ ចំណុចទីបួន សំណួរទីបួន របស់របរនៅក្នុងរោងជាង កន្លែងលោកធ្វើការហ្នឹងតើលោកបានរៀបរយល្អ ឬក៏វារោងជាង តើវានៅរាយបាយពេញហ្នឹង ឬយ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! រោងជាងនោះមិនបានជារៀបរយអីឲ្យបានមានរបៀបរាបសាអី អត់ទេ គឺថានៅអារាត់អារាយ ពាសវាលពាសកាល ពេញនុ៎ងទាំងអស់តែម្តង ។ អាខ្ទះបបរ

ហ្នឹង នៅដោយអាខ្ទះបបរទៅ អារឿងតុទូអីហ្នឹងនៅផ្សេងទៅ ហើយនិងម៉ាស៊ីនដេរ ដែលខ្ញុំធ្វើហើយហ្នឹងក៏នៅមួយម្ដុំអ៊ីចឹងទៅ អត់មានរៀបអីឲ្យស្រួលបួលអី អត់មានទេ ។

**ស៖** សូមអរគុណ ។ សំណួរទីប្រាំ ពេលពួកទាហានខ្មែរក្រហមបាញ់សម្លាប់ប្រពន្ធលោកកូនលោកអាយុ២ខែ តើលោកច្បាស់ថា កូនលោកពេលនោះស្លាប់នៅនឹងដៃប្រពន្ធរបស់លោក ឬក៏យ៉ាងម៉េច?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ពេលហ្នឹង គឺថាកូនហ្នឹងនៅនឹងដៃម្ដាយហ្នឹង បើម្ដាយស្លាប់ហើយ ខ្ញុំដឹងថា គំនិតពួកអស់ហ្នឹង អត់មានទុកទេ រឿងកូនក្មេងប៉ុណ្ណឹង អត់ទុកទេ ទោះបីនៅរស់ក៏វាកម្ទេចចោលដែរ ។ ហ្នឹងបើតាមទឹកចិត្តរបស់ពួកខ្មែរក្រហមហ្នឹង ។

**ស៖** សូមអរគុណ ។ នៅសំណួរចុងក្រោយ ។ នៅពេលដែលសកម្មភាពឡើងវិញនៅស-២១ពេល តាឌុច ធ្វើសេចក្ដីប្រកាសសុំទោសជនរងគ្រោះទាំងអស់ ។ ខ្ញុំចាំ ខ្ញុំឃើញថា លោករបូតមាត់ថាលោករង់ចាំពាក្យនេះ អស់សាមសិបឆ្នាំហើយ ។ លោកមាននឹកឃើញទេ ពាក្យនេះ?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! ខ្ញុំនឹកឃើញហើយ ។

**ស៖** សូមអរគុណដែលលោកនឹកឃើញ បើលោកនឹកឃើញ សូមលោកបញ្ជាក់មើល៉ តើពាក្យថារង់ចាំពាក្យនេះអស់សាមសិបឆ្នាំក្នុងចិត្តរបស់លោក លោកមានន័យយ៉ាងម៉េច សូមលោកជួយបញ្ជាក់ផង?

**ឆ៖** ជម្រាបប្រសាសន៍លោកមេធាវី! អាបញ្ហាហ្នឹង ដែលខ្ញុំរង់ចាំជាយូរឆ្នាំមកហើយ ខ្ញុំចង់ឮសូរសម្ដីលោកឌុច គាត់មានប្រសាសន៍ គាត់ថា គាត់ជាអ្នកចេះដឹងម្នាក់ គាត់ជាគ្រូបង្រៀនម្នាក់ គាត់អ្នកចេះដឹងម្នាក់ គាត់ថាមិនគួរណាឲ្យអាប៉ុន្មាននាក់ហ្នឹង មកបង្វិលខួរក្បាលគាត់ទេ គាត់នឹកឃើញអាកន្លែងហ្នឹង ។ ហើយខ្ញុំពិចារណាទៅ គឺថាអាបញ្ហាហ្នឹង ខ្ញុំនឹកឃើញថា គាត់ភ្ញាក់រឮកដែរ ភ្ញាក់រឮកថាកាប់សម្លាប់ប្រជាជនខ្មែរគ្នាឯងដែរ ។ អាបញ្ហាហ្នឹង ខ្ញុំនឹកស្មានថា គាត់មិនបញ្ចេញអារម្មណ៍ហ្នឹងឲ្យប្រជាជនដឹងទេ ខ្ញុំមិននឹកស្មានទេ តែដល់គាត់បញ្ចេញអារម្មណ៍ហ្នឹងទៅ គឺថាខ្ញុំ គឺខ្ញុំនឹកឃើញ ខ្ញុំក៏សប្បាយចិត្ត ។ ក៏ប៉ុន្តែ មានគំនិតមួយ គាត់សម្រក់ទឹកភ្នែក សម្រក់ទឹកភ្នែកចំពោះមុខខ្ញុំនៅទួលស្លែងហ្នឹង គាត់សម្រក់ទឹកភ្នែក ។ ខ្ញុំជម្រាបគាត់ថា ខ្ញុំមិនបានយកទឹកភ្នែកគាត់ប៉ុន្មានដំណក់មកលុបលាងប្រជាជនខ្ញុំរាប់លាននាក់ដែរ អស់ជិតជាងពីរលាននាក់ ទឹកភ្នែកប្រជាជនខ្មែរអស់ជិតពីរលាននាក់ ។ ម្ល៉ោះហើយទឹកភ្នែកគាត់ប៉ុន្មានហ្នឹង មិនអាចយកមកលុបលាងបានទេ អាបញ្ហាហ្នឹងទាល់តែតុលាការបានលុបលាង

បាន១ ប៉ុន្តែចំពោះខ្ញុំលុបលាងអត់បានទេ ទាល់តែតុលាការ ហើយនិងប្រជាជនអាហ្នឹងបានលុបលាងបាន ។

**លោក ការ សាវុត្ថ៖**

សូមអរគុណ ខ្ញុំអស់សំណួរហើយ ។ សូមគោរពជូនលោកប្រធាន ខ្ញុំអស់សំណួរហើយ ។

[១៥:៣០:០៩]

**ប្រធានអង្គជំនុំ៖**

តើលោកស្រីមេធាវីការពារក្តីអន្តរជាតិ តើមានសំណួរអ្វីត្រូវសួរដល់អ៊ំ ជុំ ម៉ី ទេ? បើមានសូមអញ្ជើញ ។

**លោកស្រី ម៉ារីប៉ូល កានីហ្សារ៖**

សូមអរគុណលោកប្រធាន! ខ្ញុំមិនមានសំណួរអ្វីសួរទៅលោកជុំ ម៉ី ទេ ។

**ប្រធានអង្គជំនុំ៖**

អស់លោក លោកស្រីចៅក្រម តើមានសំណួរអ្វីសួរដល់អ៊ំ ជុំ ម៉ី ទៀតទេ?

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោកប្រធាន ខ្ញុំសូមអនុញ្ញាតឲ្យកំណត់រូបភាពថតពីខាងលើ នៅរូបស-២១ ឲ្យបានជាក់ច្បាស់ដែលលោក ជុំ ម៉ី គាត់នៅកន្លែងណា? កន្លែងរោងជាងនោះ ដែលជាកន្លែងដែលគាត់ធ្វើការជាជាងនោះ។ ខ្ញុំគិតថា ខាងសហព្រះរាជអាជ្ញា មានលេខយោង ហើយនិងឯកសាររូបថតពីខាងលើនោះ ។

**លោក វីលៀម ស្មីត៖**

លោកស្រីចៅក្រម គឺថាយើងមាន គឺថាអាចនឹងសុំស្នើឲ្យខាង *អេវី* (AV) គាត់ផ្ទេរការភ្ជាប់ទៅខាងកុំព្យូទ័ររបស់សហព្រះរាជអាជ្ញា ។

**ប្រធានអង្គជំនុំ៖**

មន្ត្រីសោតទស្សន៍សូមបង្វែរប្រព័ន្ធរូបភាពទៅភ្ជាប់ជាមួយនឹងកុំព្យូទ័ររបស់សហព្រះរាជអាជ្ញា។

**សួរដោយចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។ លោក ជុំ ម៉ី លោកបានបញ្ជាក់ថា លោកបានធ្វើការនៅកន្លែងរោងជាងមួយជាជាងជួសជុល ហើយនៅក្បែរផ្ទះបាយ ហើយជាផ្នែកមួយនៃផ្ទះបាយនោះ ។

**សៈ** តើលោកអាចប្រាប់យើងបានទេ ថាតើទីតាំងរោងជាងនោះនៅកន្លែងណា ដោយលោកពិនិត្យមើលរូបភាពដែលថតពីលើអាកាសនៅទីតាំងនោះ? ហើយជាបឋម តើលោកនៅចាំអគារនោះទេ របៀបដែលទីតាំងអគារនៅក្នុងរូបភាពនេះ?

**ឆៈ** ជម្រាបប្រសាសន៍លោកស្រី! អគារទាំងអស់នេះ ខ្ញុំមើលឃើញថា វាមានការពិតជាក់ស្តែងហើយ ក៏ប៉ុន្តែ ផ្លូវចូលទៅក្រោយនេះ ចូលទៅក្រោយហ្នឹង គឺថាវាមានផ្ទះថ្មអី អាដិបអាដុបអី អត់ជាប់គ្នាអ៊ីចឹង ធម្មតាដែលខ្ញុំចេញពីអាមាត់ទ្វារទៅហ្នឹង គឺថាមានរោងប្រក់ស័ង្កសីវែងអ៊ីចេះ អត់មានរដិបរដុបអ៊ីចឹងទេ វែងប្រក់ស័ង្កសីវែងអ៊ីចឹងមក ។ ទីមួយ គឺថាគាត់ដាក់ មិត្តសុះ ហ្នឹង គាត់ដាក់អីវ៉ាន់គាត់ ដូចជាអង្ករ ជាត្រី ហ្នឹង មួយកន្លែងទៅ ហើយបន្ទាប់មកទៀតហ្នឹង គាត់មានម៉ាស៊ីនដេរមួយនៅកន្លែងហ្នឹង ។ ហើយនៅកន្លែងហ្នឹងមានអាគំនរខោអាវច្រើននៅកន្លែងហ្នឹង បន្ទាប់ពីហ្នឹងមក តាមរោងហ្នឹងរហូតទេ ។ បន្ទាប់ពីហ្នឹងមកមានរោងបបរ ចង្ក្រានបបរបាយ អាខ្ទះធំៗហ្នឹង បានមកដល់កន្លែងខ្ញុំធ្វើម៉ាស៊ីនដេរ ។ ហើយចេញពីហ្នឹងទៅ មានកន្លែង តាគង់ គាត់ធ្វើគុធ្វើទូ នៅត្រង់ហ្នឹងដែរ ។ ទៅពីហ្នឹងទៅទៀតមានកន្លែងគេចិញ្ចឹមទន្សាយៗ ចិញ្ចឹមជ្រូក នៅខាងត្បូង ចិញ្ចឹមទន្សាយ ចិញ្ចឹមជ្រូកនៅខាងត្បូង ហើយងាកមកខាងលិចបន្តិច មានដើមអម្ពិលបារាំងមួយធំៗ អាដើមអម្ពិលបារាំងហ្នឹងហើយ ដែលគេសែងខ្មោចពីក្រោយខ្នងខ្ញុំទៅ គេយកទៅកប់ក្រោមដើមអម្ពិលបារាំងហ្នឹងៗ ។ ហើយខ្ញុំធ្វើការបែរទៅរកអាដើមអម្ពិលបារាំងហ្នឹង ហើយលោក ប៊ុច ក៏គាត់នៅជិតហ្នឹងដែរ លោកប៊ុច អីហ្នឹង គាត់មិនប៊ានមើលទេគេធ្វើម៉េច ធ្វើទៅ ប៉ុន្តែខ្ញុំបែរមុខទៅរកដើមអម្ពិលបារាំង គេកំពុងតែជីកកប់នៅក្រោមដើមអម្ពិលបារាំងហ្នឹង ក៏ប៉ុន្តែមិនដឹងកប់ប៉ុន្មាននាក់ៗ ប៉ុន្តែ ខ្ញុំដឹងតែបីនាក់ហើយ តែប៉ុន្មានដង ប៉ុន្មានដឹង ខ្ញុំអត់ដឹងទេ ដឹងតែថាយកទៅបីនាក់ ។ យកទៅបីនាក់ហ្នឹង មិនមែនដាក់*ប្រង់ការ* សែងទៅទេ គេដាក់អាស័ង្កសីអ៊ីចឹង គេវៃជាប់អាឈើសងខាងអ៊ីចឹង គេសែងដូច*ប្រង់ការ* អ៊ីចឹង ។ ពីរនាក់សែងយកទៅៗ យកទៅកប់នៅក្រោមដើមអម្ពិលបារាំងហ្នឹង ។ តែឥឡូវដើមអម្ពិលបារាំងហ្នឹង គេឈូសឆាយអស់រលីងហើយ ។

[១៥:៣៥:១៩]

**សៈ** អរគុណ ។ តើអគារដែលលោកដែលបានរៀបរាប់នោះ បង្ហាញនៅលើរូបថតនេះ មានទេមានអគារនោះទេ?

**ឆៈ** ជម្រាបប្រសាសន៍លោកស្រី! បើយើងមើលអ៊ីចឹង វាអត់មាននេះតែម្តង ដូចអត់មានជាប់គ្នារហូតទេ ។ តាមខ្ញុំដឹង គឺថាគេអត់មានធ្វើជញ្ជាំងធ្វើអីទេ មានប្រក់តែដំបូលទេ ហើយអានេះវាឡើង

រដុបៗអ៊ីចេះ វាអត់បណ្ដោយអ៊ីចេះៗ ។

**ស៖** លោកពេលដែលលោកនិយាយ អំពីច្រកខាងក្រោយនោះ ជាកន្លែងដែលថា មានដំបូលជាជួរៗនៅកន្លែងនោះ តើនៅខាងក្រោយអគារ “B” អគារ “C” និងអគារ “B” នេះឬ?

**ឆ៖** ខ្ញុំដឹងតែថា អគារ “B” មួយ ហើយនិងអគារអី “C” អី ខ្ញុំអត់ស្គាល់ដែរ នៅខាងក្រោយហ្នឹង អាហ្នឹងបើថា ឯលិច ឯកើត ខ្ញុំច្បាស់តែម្ដង បើថាឯលិច ឯកើត អារោងហ្នឹងវានៅក្រោយអគារហ្នឹង នៅខាងលិចអគារហ្នឹង នៅខាងលិចអគារហ្នឹង អារោងបបរបាយហ្នឹង ។

**ស៖** ពេលដែលលោកមើលនៅខាងស្ដាំដៃខាងលើនៃរូបនេះ នៅពេលដែលមានរង្វង់មួយ ដែលគេបញ្ជាក់ហ្នឹង គឺថាឃើញមានខាងជើងនៅខាងស្ដាំ ហើយគឺនៅខាងលិច នៅខាងលើហ្នឹង តើលោកមើលឃើញសញ្ញានោះទេ?

**ឆ៖** បាទ, មើលឃើញលោកស្រី ប៉ុន្តែអានេះហ្នឹង គឺថានៅខាងលិចៗអគារហ្នឹង ។

**ស៖** ដូច្នេះអគារដែលលោកបានរៀបរាប់នោះ គឺមានតែដំបូលដែលភ្ជាប់លើរបងនោះ គឺថានៅក្រោយអគារ “ខ” និង “គ” តើមែនទេ? នៅខាងព្រំខាងលិច “B”, “C” ហ្នឹង?

**ឆ៖** ជម្រាបប្រសាសន៍លោកស្រី! មិននៅជាប់របងទេ អាកន្លែងបបរបាយហ្នឹង មិនមែននៅជាប់របងទេ ។ ចេញពីរបងហ្នឹងទៅ មានអាវាលមួយរហូតអ៊ីចេះទៅ អាវាលហ្នឹងរាងត្រដក់ ដូចជាត្រដក់ទឹកបន្តិច ។ វាលរហូតអ៊ីចឹងទៅ បានទៅដល់អាកន្លែងបបរបាយ បានទៅដល់កន្លែងខ្ញុំធ្វើការហ្នឹង រហូតតាមអាបណ្ដោយអគារ ទទឹងអគារហ្នឹងមកហ្នឹង គឺថាវាអត់មាននេះទេ អត់មានមកភ្ជាប់នៅក្នុងអគារវែងៗហ្នឹងទេ នៅដាច់ដោយឡែកពីគ្នាទាន។

**ស៖** ប៉ុន្តែអគារនោះ គឺថានៅខាងក្រោយអគារ “B” និង “C” ឬក៏ថា “ខ” និង “គ” គឺនៅខាងលិចហ្នឹង តើមែនដែរឬទេ?

**ឆ៖** បាទ, ជម្រាបលោកស្រី! បើថានៅខាងលិច ច្បាស់ជានៅខាងលិចហ្នឹងហើយ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

សូមអរគុណ ។ សហព្រះរាជអាជ្ញា ។

**លោក វីលៀម ស្មីត៖**

សូមអរគុណ ។ គឺថាអាចនឹងបំភ្លឺនូវបញ្ហានេះ-- មើលនៅលើអេក្រង់នេះ គឺD4511 យើងអាចឃើញចំណុចខៀវ អ៊ីចឹងហើយ គឺអាចនឹងទំនងជានឹងចំណុចដែលគាត់បានបំភ្លឺ ហើយលោកចៅក្រម

គឺទាក់ទងទៅនឹងខ្សែវីដេអូរបស់វៀតណាម គឺថាតើអាចទទួលយកបានទេ? ថាវីដេអូនេះ ខ្ញុំជឿថាអាចនឹងបង្ហាញពីទីកន្លែងនៃរោងជាងហ្នឹង ដែលមានគំនរខោអាវ ដែលជាចំណុចដែលលោក ជុំ ម៉ី យោងទៅរក គឺថាអាចនឹងបង្ហាញពេលនេះ ឬក៏ម្យ៉ាងទៀត គឺថា សូមឲ្យអង្គជំនុំជម្រះកត់សម្គាល់ថានឹងប្រើពេលណាមួយ ដើម្បីបង្ហាញចំណុចដែលលោក សាក្សីបានបង្ហាញ ។

**ចៅក្រម ស៊ីលយ៉ា ខាតវ៉ាយថ៍៖**

លោកប្រធានបានប្រាប់ លោកពីម្សិលមិញហើយ គឺថាយើងនឹងឆ្លើយតបនៅលើកក្រោយ ។ ហើយខ្ញុំមិនមានសំណួរអ្វីទៅសាក្សីទៀតទេ ។ សូមអរគុណ ។

**ប្រធានអង្គជំនុំ៖**

អញ្ជើញលោកចៅក្រម ហ្សង់ម៉ាក ។

លោក កាំង ហ្គេកអ៊ាវ អ្វីដែលអ៊ំ ជុំ ម៉ី បានលើកឡើង អំពីទីតាំងនៃរោងជាង ឬក៏កន្លែងរោងបាយសម្រាប់នៅក្នុងស-២១ ដែលចង្អុលអំមិញហ្នឹង គឺផ្នែកខាងលើ មានន័យថា វាផ្នែកខាងលិចនៃអគារ “B” ហើយនិង “C” ហើយមានចម្ងាយឃ្លាតឆ្ងាយ ។ បានន័យថា បើជាបរិវេណសាលាវិញ ជាមានសាលាពីរជាប់គ្នា គឺវាមានបរិវេណមួយនៅខាងលិច ហើយនិងបរិវេណនៃមន្ទីរស-២១ ដែលមានអគារ ។ ការដែលគាត់និយាយអ៊ីចឹង រៀបរាប់ហ្នឹងគឺជាការចង្អុលបង្ហាញ ផ្ទុះបញ្ជាំងភាពត្រឹមត្រូវនៃទីតាំងរោងបាយនិងរោងជាងដែរឬទេ?

**ជនជាប់ចោទ៖**

ជម្រាបប្រសាសន៍លោកប្រធាន! សេចក្ដីអធិប្បាយរបស់បង ម៉ី ត្រឹមត្រូវហើយ ។ អគាររោងជាងនេះដែល បងម៉ី នៅធ្វើការនុ៎ង គឺជាអតីតបឋមសិក្សាទួលស្លែង ។ ខ្ញុំចូលទៅម្ដងនៅហ្នឹង ចូលទៅប្រហែលជាពីរមីនុត ទៅជាមិត្តហ៊ិ ទៅមើលគេធ្វើកែសគ្រាប់ ។ ខ្ញុំឃើញ ហើយនៅពេលដែលបង្ហាញរូបនេះមកឲ្យខ្ញុំមើលមុនគេបំផុត លោកព្រះរាជអាជ្ញា តាន់ សេណារ៉ុង លោកថា ពីដើមវាជាអគារមែន ប៉ុន្តែ ឥឡូវវាទៅជាផ្ទះល្វែងអស់ហើយ ។ ដូច្នេះ ទីតាំងហ្នឹង ច្បាស់ណាស់ទីតាំងហ្នឹង យើងខ្ញុំស្គាល់ទាំងអស់គ្នាហើយ ។

**ប្រធានអង្គជំនុំ៖**

បញ្ជាក់សាជាថ្មីម្ដងទៀត ចំពោះការលើកឡើងរបស់តំណាងសហព្រះរាជអាជ្ញាអន្តរជាតិថា អ្វីដែលជាការសុំនេះ គឺសុំដោយលោកសហព្រះរាជអាជ្ញាអន្តរជាតិ ។ ពីម្សិលមិញលោក ពេទីត យើង

បានបញ្ចោក់រួចហើយ គឺការព្យួរនៅក្នុងការសម្រេចនេះ ហើយរហូតដល់កាលៈទេសៈមួយ ណាមួយនោះ យើងនឹងលើកយកមកពិចារណា និងសម្រេចតែម្តង ដោយហេតុថា កិច្ចប្រជុំពិភាក្សារវាងអង្គជំនុំជម្រះសាលាដំបូងកាលពីថ្ងៃសុក្រ ។ ព្រឹកថ្ងៃសុក្រហ្នឹង យើងបានធ្វើការហ្មត់ចត់នូវបញ្ហាដែលសេសសល់ ហើយក្នុងចំណោមបញ្ហាទាំងអស់នោះ យើងបានដោះស្រាយបញ្ហាជាក់លាក់ហើយ លើកលែងតែបញ្ហាហ្នឹងមួយ ហើយនិងបញ្ហាមួយចំនួនតិចតួចទេដែលនៅសេសសល់ ។ ប៉ុន្តែ យើងរក្សាសិទ្ធក្នុងការព្យួរក្នុងការសម្រេចលើបញ្ហានេះ ។

ហើយដោយសារឥឡូវនេះ ឃើញថាការដំណើរការសវនាការនៃការស្តាប់សក្ខីកម្មរបស់អ៊ំ ជុំ ម៉ី ដែលជាអ្នករស់រានមានជីវិតពីមន្ទីរសន្តិសុខស-២១ ឃើញថា ដល់ទីបញ្ចប់ហើយ ។

ឥឡូវនេះ អង្គជំនុំជម្រះប្រកាសផ្អាកដំណើរការសវនាការ សម្រាប់ថ្ងៃនេះត្រឹមនេះ ។ ហើយដំណើរការសវនាការលើកទៅបន្តនៅថ្ងៃស្អែក ចាប់ពីវេលាម៉ោងប្រាំបួនព្រឹក ដោយស្តាប់នូវការសក្ខីកម្មរបស់អ្នករស់រានមានជីវិតមួយរូបទៀត តាមកាលវិភាគដែលបានជម្រាបជូនដល់ភាគី និងសាធារណជនរួចហើយ ។

មន្ត្រីតុលាការសម្របសម្រួលឲ្យអ៊ំ ជុំ ម៉ី បានវិលត្រលប់ទៅកាន់លំនៅដ្ឋានរបស់គាត់វិញ បានស្រួល ។ ហើយអនុរក្សមន្ទីរឃុំឃាំង នាំជនជាប់ចោទទៅកាន់មន្ទីរឃុំឃាំងវិញ ។ ហើយសុំឲ្យនាំគាត់មកកាន់សាលសវនាការវិញនៅថ្ងៃ ព្រឹកថ្ងៃស្អែកឲ្យបានមុនម៉ោងប្រាំបួន ៕

*[សវនាការផ្អាកនៅម៉ោង ១៥:៤៥ នាទី]*